ព្រះរាជាណាចក្រកម្ពុជា

KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ

NATION RELIGION KING

ធនាគារជាតិ នៃ កម្ពុជា

NATIONAL BANK OF CAMBODIA

# របាយការណ៍ប្រចាំឆ្នាំ២០០៨

# និង

# ទិសដៅការងារឆ្នាំ២០០៩

# អារម្ភកថា

ចាប់តាំងពីពាក់កណ្តាលឆ្នាំ ២០០៧ មកទល់បច្ចុប្បន្ន សេដ្ឋកិច្ចពិភពលោកកំពុងឆ្លងកាត់ដំណាក់កាលដ៏លំបាកមួយ ដោយត្រូវតទល់នឹងបញ្ហាប្រឈមនៃវិបត្តិឥណទានជាសកល ដែលបង្កើតឱ្យមានភាពរឹតវរក្នុងវិស័យហិរញ្ញវត្ថុចាប់ពីដើមខែតុលា ឆ្នាំ២០០៨ មក ហានិភ័យពីការធ្លាក់ចុះយ៉ាងគំហុកនៃសេដ្ឋកិច្ចពិភពលោកដោយសារវិបត្តិហិរញ្ញវត្ថុនេះ និងការកើនឡើងនៃសម្ពាធអតិផរណា ។ "ទស្សនៈវិស័យសេដ្ឋកិច្ចពិភពលោក" បានព្យាករថ្មីៗនេះថា កំណើនសេដ្ឋកិច្ចមានកម្រិតយឺតជាងមុន ទាំងចំពោះអរិយប្រទេសក៏ដូចជាប្រទេសដែលមានសេដ្ឋកិច្ចកំពុងងើបឡើងដោយផលិតផលពិភពលោកត្រូវបានរំពឹងថានឹងធ្លាក់ចុះពី ៥% នៅឆ្នាំ២០០៧ មក ៣,៩% នាឆ្នាំ២០០៨ ។ កំណើនសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកត្រូវបានរំពឹងថានឹងថយចុះពី ២% មក ១,៦% ក្នុងឆ្នាំនេះ ខណៈដែលកំណើនសេដ្ឋកិច្ចតំបន់អឺរ៉ុបត្រូវបានរំពឹងថា នឹងថយចុះច្រើនជាងការគ្រោងទុកគឺពី ២,៦% ក្នុងឆ្នាំ២០០៧ ដល់ ១,៣% នៅឆ្នាំ២០០៨ ។ ទន្ទឹមនឹងនោះ កំណើន ផ.ស.ស នៃប្រទេសតំបន់អាស៊ីក៏ត្រូវបានរំពឹងថាស្រកស្រុតចុះផងដែរ ក្នុងនោះ កំណើននៃប្រទេសជប៉ុនត្រូវបានប៉ាន់ស្មានថា ធ្លាក់ចុះដល់ ០,៥% នាឆ្នាំនេះ ធៀបទៅនឹង ២,២% នៅឆ្នាំ២០០៧ ប្រទេសចិន ៩,៧% ធៀបនឹង ១១,៩% ពីឆ្នាំមុន ហើយប្រទេសអាស៊ាន+៣ ជារួម អាចនឹងមានកំណើន ៥,៩% ធៀបនឹង ៧,៦% កាលពីឆ្នាំកន្លងទៅ ។

ចំពោះស្ថានភាពប្រទេសកម្ពុជាវិញ ដោយសារសេដ្ឋកិច្ចមានទំហំតូចនិងបើកចំហផងនោះ កម្ពុជាងាយទទួលរងឥទ្ធិពលនៃការវិវឌ្ឍថ្លៃទំនិញលើទីផ្សារសកលលោក ។ ទន្ទឹមនោះដោយសារការពឹងផ្អែកទាំងស្រុងលើការផ្គត់ផ្គង់ប្រភពថាមពលពីក្រៅប្រទេស ការឡើងថ្លៃប្រេងជាសកលកាលពីឆ្នាំមុន និងក្នុងបីត្រីមាសដើមឆ្នាំ២០០៨ នេះ មានសម្ពាធយ៉ាងខ្លាំងលើអតិផរណានៅកម្ពុជា ។ ការកើនឡើងនៃថ្លៃម្ហូបអាហារក្នុងទីផ្សារអន្តរជាតិក៏ជំរុញឱ្យថ្លៃទំនិញក្នុងស្រុកកើនឡើងផងដែរ ដែលជាកត្តាចម្បងមួយទៀតជំរុញឱ្យអត្រាអតិផរណានៅកម្ពុជាកើនដល់ ២៥,៧% នៅខែឧសភា និងថយចុះមកនៅត្រឹម ១៣,៥% ក្នុងខែធ្នូ ឆ្នាំ២០០៨ ។ ដូច្នេះ ក្នុងខណៈដែលអត្រាអតិផរណាកើនឡើងធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើយ៉ាងណាឱ្យមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងស្ថិរភាពហិរញ្ញវត្ថុ ។ ដើម្បីសម្រេចគោលដៅនេះ ធនាគារជាតិនៃកម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តឱ្យទាន់ពេលវេលានូវវិធានការគោលនយោបាយជាកញ្ចប់ សំដៅកាត់បន្ថយសម្ពាធអតិផរណាពោលគឺការដាក់ឱ្យអនុវត្តនូវគោលនយោបាយសារពើពន្ធរឹតត្បិត ការបង្កើនអត្រាទុនបម្រុងកាតព្វកិច្ចពី ៨% ទៅ ១៦% នៅក្នុងប្រព័ន្ធធនាគារ និងការដាក់ពិដានឥណទានលើវិស័យជួញដូរអចលនទ្រព្យត្រឹម ១៥% និងការឃ្លាំមើលនិងត្រួតពិនិត្យជាប្រចាំជាដើម ។ ក្រៅពីនោះរដ្ឋាភិបាលក៏បានដាក់ចុះនូវវិធានការចំពោះមុខផ្សេងទៀត ដូចជាការទប់ស្កាត់មួយរយៈមិនឱ្យមានការនាំស្រូវចេញ ការលក់ចែកចាយអង្ករក្នុងតម្លៃសមរម្យ និងការបើកទូលាយឱ្យនាំចូលនូវជ្រូករស់ដើម្បីបំពេញតម្រូវការក្នុងស្រុកជាដើម ។ ជាលទ្ធផល ទោះបីជាជួបនឹងបញ្ហាប្រឈមខ្លះក្តី ក៏យើងទទួលបាននូវលទ្ធផលជាវិជ្ជមានមួយចំនួនផងដែរ ពោលគឺអត្រាអតិផរណាបានថយចុះជាបន្តបន្ទាប់នៅត្រីមាសទី ៤ ឆ្នាំ ២០០៨ ។ ចំពោះកំណើនសេដ្ឋកិច្ចវិញ តួលេខដំបូងនិងស្ថានភាពបច្ចុប្បន្នបានផ្តល់សញ្ញាឱ្យឃើញថា ប្រទេសកម្ពុជាមានលទ្ធភាពរក្សាកំណើនវិជ្ជមាននៃ ផ.ស.ស ជាបន្តទៀតក្នុងរង្វង់ប្រមាណ ៧% ក្នុងឆ្នាំ ២០០៨ នេះ ទោះបីជាទាបជាងឆ្នាំកន្លង

ទៅក្តី ដោយសារវិស័យជាសសរទ្រូងនៃសេដ្ឋកិច្ច ដូចជា វិស័យទេសចរណ៍ កម្មន្តសាល សំណង់ មិនទាន់ទទួលរងឥទ្ធិពលធ្ងន់ធ្ងរ ខណៈដែលវិស័យកសិកម្មមានកំណើនល្អបង្គួរ ។ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក នៅបន្តមានស្ថិរភាពក្នុងអំឡុងឆ្នាំ២០០៨ នេះ ដោយប្រែប្រួលក្នុងចន្លោះពី ៤.០០០រៀល ទៅ ៤.១២៥ រៀល ប៉ុណ្ណោះ ក្នុងមួយដុល្លារអាមេរិក ។ ទន្ទឹមនោះ ការអនុវត្តយ៉ាងហ្មត់ចត់ និងត្រឹមត្រូវនូវគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ជំនឿទុកចិត្តលើប្រព័ន្ធធនាគារ និងលើប្រាក់រៀល ជាកត្តាដ៏សំខាន់ក្នុងការបង្កើនទុនបម្រុងអន្តរជាតិដុលរបស់ប្រទេសដែលបានពូនគរដល់ ២.២ ពាន់លានដុល្លារអាមេរិកនាដំណាច់ឆ្នាំនេះ និងអាចធានាបាន ៣.៨ ខែនៃការនាំចូលទំនិញ ។

ចំពោះផ្នែករូបិយវត្ថុវិញ កំណើនដ៏ខ្លាំងនៃអតិផរណាដែលកើតមានចាប់តាំងពីត្រីមាសទី ៤ ឆ្នាំ២០០៧ មកបានញ៉ាំងឱ្យមានការគ្រប់គ្រងដ៏ប្រុងប្រយ័ត្នបន្ថែមទៀតទៅលើលក្ខខណ្ឌរូបិយវត្ថុ ដើម្បីមានលទ្ធភាពក្នុងការឆ្លើយតបនឹងហានិភ័យនៃកំណើនដ៏ខ្ពស់នៃអតិផរណា ។ ទន្ទឹមនឹងនោះ លំហូរដើមទុនជាបន្តដ៏គួរកត់សម្គាល់ក្នុងបណ្តាឆ្នាំថ្មីៗនេះ បានធ្វើឱ្យមានសំណល់សាច់ប្រាក់ងាយស្រួលក្នុងប្រព័ន្ធធនាគារ ក៏ដូចជាការវិនិយោគយ៉ាងច្រើនទៅលើវិស័យអចលនទ្រព្យ ទេសចរណ៍ និងវិស័យផ្សេងទៀត ។ ដូច្នេះ ការអនុវត្តគោលនយោបាយរូបិយវត្ថុត្រូវបានផ្តោតលើការគ្រប់គ្រងស្ថានភាពសាច់ប្រាក់ងាយស្រួលដែលលើស និងដើម្បីជៀសវាងការពាក់ព័ន្ធហួសប្រមាណរបស់បណ្តាធនាគារទៅក្នុងវិស័យអចលនទ្រព្យ ដែលអាចជាហានិភ័យយ៉ាងសំខាន់ចំពោះប្រព័ន្ធធនាគារទាំងមូល នៅពេលដែលវិស័យនេះធ្លាក់ចុះ ។ សំណុំនៃកញ្ចប់គោលនយោបាយរូបិយវត្ថុរឹតត្បិតត្រូវបានដាក់ឱ្យអនុវត្តដើម្បីទប់ស្កាត់ការរីកសាយសកម្មភាពឥណទាន និងកាត់បន្ថយកំណើននៃរូបិយវត្ថុមូលដ្ឋានដែលរួមមានជាអាទិ៍ ការបង្កើនអត្រាទុនបម្រុងកាតព្វកិច្ច និងការណែនាំដល់ធនាគារឱ្យប្រុងប្រយ័ត្នលើការផ្តល់ឥណទានចំពោះវិស័យអចលនទ្រព្យ ។

ចំពោះវិស័យធនាគារនិងហិរញ្ញវត្ថុ ក្នុងកាលៈទេសៈដែលកំពុងតែមានវិបត្តិហិរញ្ញវត្ថុជាសកល ធនាគារជាតិនៃកម្ពុជាបានបង្កើនការយកចិត្តទុកដាក់ឃ្លាំមើលជាប្រចាំ ដោយដាក់វិធានការប្រុងប្រយ័ត្នអនុវត្តការត្រួតពិនិត្យដល់ទីកន្លែងជាញឹកញាប់ និងការត្រួតពិនិត្យលើឯកសារយ៉ាងហ្មត់ចត់លើស្ថានភាពធនាគារ ក្នុងគោលបំណងវាយតម្លៃលើភាពរឹងមាំរបស់គ្រឹះស្ថានធនាគារ ដើម្បីជៀសវាងឱ្យបានជាអតិបរមានូវការរងឥទ្ធិពលពីវិបត្តិហិរញ្ញវត្ថុ ដែលកំពុងតែញាំញីនៅក្នុងប្រទេសជាច្រើនលើសកលលោក ។ នៅក្នុងបរិការណ៍នៃការពង្រឹងបទប្បញ្ញត្តិប្រុងប្រយ័ត្នសម្រាប់ប្រព័ន្ធធនាគារនេះដែរ យើងបានកែលំអការធ្វើចំណាត់ថ្នាក់ឥណទានតាមវិស័យ រៀបចំចំណាត់ថ្នាក់ទ្រព្យសកម្មប្រុងប្រយ័ត្ន ដោយផ្អែកលើលក្ខណវិនិច្ឆ័យច្បាស់លាស់ ដាក់ឱ្យអនុវត្តនូវកម្រិតសំវិធានធនសមស្របចំពោះឥណទានតាមចំណាត់ថ្នាក់ផ្សេងៗ ព្រមទាំងពង្រឹងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។ ក្រៅពីនេះ យើងក៏បានតម្រូវឱ្យធនាគារអនុវត្តតាមបែបប្រព័ន្ធសហគ្រាសទំនើបមួយផងដែរ តាមរយៈការលើកកម្ពស់ក្រុមប្រតិបត្តិនិងអភិបាលកិច្ចល្អ ព្រមទាំងការណែនាំឱ្យមានប្រព័ន្ធគ្រប់គ្រងហានិភ័យត្រឹមត្រូវ ។

ជាទូទៅ ធនាគារជាតិនៃកម្ពុជាមានសេចក្តីសោមនស្សនឹងបញ្ជាក់ថា ប្រព័ន្ធធនាគារនៅកម្ពុជាមិនទទួលរងនូវឥទ្ធិពលនៃវិបត្តិឥណទាននិក្ខេបដោយផ្ទាល់ទេ ។ កត្តាចម្បងមួយគឺ ដោយសារធនាគាររបស់យើងមានអាជីវកម្មបែបប្រពៃណី ដោយផ្អែកជាមូលដ្ឋានលើទំនាក់ទំនងផ្ទាល់រវាងសាជីវកម្មនិងអតិថិជន ។ ទន្ទឹមនោះ ការអនុវត្តកំណែទម្រង់

និងការពង្រឹងរចនាសម្ព័ន្ធស្ថាប័ននៃវិស័យធនាគារនៅកម្ពុជា ក៏មានឥទ្ធិពលល្អទៅលើសុខភាពហិរញ្ញវត្ថុនៃប្រព័ន្ធធនាគារយើង ដែលបានស្តែងជាភស្តុតាងតាមរយៈភាពប្រសើរឡើងគួរឱ្យកត់សម្គាល់នៅក្នុងសូចនាករប្រុងប្រយ័ត្នមួយចំនួនរបស់ធនាគារ ។ អនុបាតនៃភាពគ្រប់គ្រាន់នៃដើមទុនជាមធ្យមសម្រាប់ធនាគារពាណិជ្ជក្នុងខែធ្នូ ឆ្នាំ២០០៨ គឺ ២៨% ធៀបនឹងកម្រិតគោល ១៥% ទោះបីជាមានការកើនឡើងគួរឱ្យកត់សម្គាល់នៃទ្រព្យសកម្មសរុបរបស់ប្រព័ន្ធធនាគារក៏ដោយ ។ ចំពោះគុណភាពទ្រព្យសកម្មវិញ អនុបាតឥណទានមិនដំណើរការ (Non-performing loan (NPL)) ដែលមានកម្រិតខ្ពស់ដល់ទៅ ១៤,៨% នៅចុងឆ្នាំ២០០២ និង ៩,៩% នៅចុងឆ្នាំ២០០៦ បានថយចុះគួរឱ្យកត់សម្គាល់មកនៅត្រឹម ៣,៧% នៅចុងខែធ្នូ ឆ្នាំ២០០៨ ។ វឌ្ឍនភាពទាំងនេះអាចទទួលបានតាមរយៈការលើកកម្ពស់ការអនុវត្តសវិធានធនសម្រាប់ការខាតបង់លើប្រាក់កម្ចីរបស់ធនាគារ ក៏ដូចជាតាមរយៈសក្តានុពលដ៏ប្រសើរឡើងជាងមុនក្នុងការទទួលសំណងឥណទានដែលអំណោយផលដោយសារការរីកចម្រើននៃវប្បធម៌ឥណទាន ខណៈដែលបរិស្ថានបទប្បញ្ញត្តិមានការទ្រទ្រង់ច្រើនជាងមុន ។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជាបានខិតខំលើកកម្ពស់គុណភាពធនាគារតាមរយៈការពង្រឹងការផ្តល់អាជ្ញាប័ណ្ណដោយបានកែលំអនូវលក្ខណវិនិច្ឆ័យត្រឹមត្រូវនិងសមស្របចំពោះអ្នកគ្រប់គ្រងធនាគារ ហើយក្នុងពេលថ្មីៗនេះ ក៏មានការតម្រូវឱ្យបង្កើនដើមទុនអប្បបរមាជាមូលដ្ឋានផងដែរ ។

ទំហំប្រតិបត្តិការអាជីវកម្មរបស់ធនាគារបានកើនឡើងជាលំដាប់ ឯកម្រិតនៃភាពស៊ីជម្រៅនៃវិស័យហិរញ្ញវត្ថុក៏មានការកើនឡើងយ៉ាងលឿន ដោយកំណើនសេវាហិរញ្ញវត្ថុត្រូវបានជំរុញតាមរយៈការធ្វើកំណែទម្រង់ជាបន្តបន្ទាប់ក្រោមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ។ ការផ្គត់ផ្គង់រូបិយវត្ថុទូទៅ (M2) ធៀបនឹង ផ.ស.ស បានកើនឡើងដល់ ២៨,៦% នាដំណាច់ឆ្នាំ២០០៨ ។ ឥណទានចំពោះផ្នែកឯកជនមានកំណើនប្រមាណ ២៣% នៃ ផ.ស.ស ខណៈដែលប្រាក់បញ្ញើសរុបធៀបនឹង ផ.ស.ស បានកើនដល់ប្រហែល ២២,២% ក្នុងអំឡុងពេលដូចគ្នានេះ ។

កំណែទម្រង់ក្នុងវិស័យផ្សេងទៀតនៃសកម្មភាពធនាគារក៏ត្រូវបានអនុវត្តជាបន្តបន្ទាប់ផងដែរ ។ វិស័យទាំងនោះ រួមមានជាពិសេស ការពង្រឹងនិងទ្រទ្រង់វឌ្ឍនភាពនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ។ ការងារមីក្រូហិរញ្ញវត្ថុកាន់តែរីកដុះដាលច្រើនឡើងនៅក្នុងរង្វង់សកម្មភាពរបស់ធនាគារជាតិនៃកម្ពុជា ហើយភាគីពាក់ព័ន្ធក្នុងស្រុក និងដៃគូក្រៅប្រទេសក៏បានចូលរួមយ៉ាងសកម្មផងដែរ ក្នុងការស្វែងរកមធ្យោបាយផ្សារភ្ជាប់សេវាធនាគារឱ្យដល់ជនបទ ។

លើសពីនេះទៀត ដោយសារការរីកលូតលាស់ដ៏លឿន និងភាពស្មុគស្មាញច្រើនឡើងនៃប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជាបានសម្រេចពិនិត្យកែលំអឡើងវិញនូវច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សំដៅលើកកម្ពស់ក្របខ័ណ្ឌច្បាប់ឱ្យកាន់តែប្រសើរស្របតាមបម្រែបម្រួលនៃទីផ្សារ ។

ធនាគារជាតិនៃកម្ពុជាក៏បានផ្តោតផងដែរនូវកិច្ចប្រឹងប្រែងធានាឱ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលត្រូវបានអនុម័តនៅឆ្នាំ២០០៧ តាមរយៈការបង្កើតឡើងនូវអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ហើយនឹងការបន្តទ្រទ្រង់សម្រាប់អភិវឌ្ឍសមត្ថភាពរបស់អង្គភាពនេះថែមទៀត ។

ក្នុងអំឡុងពេលកន្លងមកនេះ ប្រព័ន្ធទូទាត់សងប្រាក់ក៏បានបង្ហាញនូវការរីកចម្រើនជាច្រើនដែរ ជាមួយនឹងការដាក់ឱ្យអនុវត្តនូវស្តង់ដារមូលប្បទានប័ត្រថ្មីមួយ ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធផ្ទេរមូលនិធិអន្តរធនាគារ និងការសម្រួលដល់ការបើកគណនីប្រាក់បៀវត្សមន្ត្រីរាជការនៅតាមធនាគារ ។

ទន្ទឹមនេះដែរ ចំពោះការរៀបចំផ្ទៃក្នុងនៃធនាគារជាតិនៃកម្ពុជាវិញ សកម្មភាពសវនកម្មផ្ទៃក្នុងត្រូវបានពង្រឹងបន្ថែម ខណៈដែលបច្ចេកទេសព័ត៌មានវិទ្យាកំពុងត្រូវបានអភិវឌ្ឍដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងការគ្រប់គ្រងប្រតិបត្តិការស្នូលរបស់ធនាគារកណ្តាល ។ ធនាគារជាតិនៃកម្ពុជាក៏បានបន្តលើកទឹកចិត្ត និងអភិវឌ្ឍជំនាញរបស់មន្ត្រីបុគ្គលិកផងដែរ ហើយដើម្បីគោលដៅនេះ យើងបានធ្វើការជ្រើសរើសបុគ្គលិកដែលមានសមត្ថភាពសមរម្យ និងអនុវត្តយុទ្ធសាស្ត្រផ្តល់ការលើកទឹកចិត្ត និងផ្តល់ឱកាសដល់បុគ្គលិកឱ្យទទួលបាននូវការបណ្តុះបណ្តាលនិងអភិវឌ្ឍន៍ជាបន្ថែមទៀត ដែលនឹងជំរុញឱ្យមន្ត្រីបុគ្គលិកមានលទ្ធភាពបំពេញភារកិច្ចកាន់តែមានប្រសិទ្ធភាពថែមឡើង ។

ក្នុងអំឡុងឆ្នាំនេះដែរ ធនាគារជាតិនៃកម្ពុជាបានបន្តសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយបណ្តាធនាគារកណ្តាលផ្សេងៗដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការវិស័យធនាគារនិងហិរញ្ញវត្ថុ ។ អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារអភិវឌ្ឍន៍អាស៊ីនៅតែជាស្ថាប័នសំខាន់ក្នុងការផ្តល់ការទ្រទ្រង់បច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា ដែលក្រសោបទៅលើផ្នែកសំខាន់ៗដូចជា ការត្រួតពិនិត្យធនាគារ និងប្រព័ន្ធទូទាត់ជាដើម ។ ក្រៅពីនេះ ធនាគារពិភពលោកក៏កំពុងតែជួយទ្រទ្រង់ផ្នែកបច្ចេកទេស ដើម្បីសិក្សាអំពីលទ្ធភាពបង្កើតឱ្យមានការិយាល័យព័ត៌មានឥណទាននៅកម្ពុជានៅពេលអនាគតដ៏ខ្លីខាងមុខ ដើម្បីជួយឱ្យប្រព័ន្ធធនាគារកាត់បន្ថយហានិភ័យនៅក្នុងការផ្តល់ឥណទានរបស់ខ្លួន ។

នៅទីបញ្ចប់ ខ្ញុំសូមឆ្លៀតឱកាសនេះសម្តែងនូវអំណរគុណដល់ក្រុមប្រឹក្សាភិបាល និងរាជរដ្ឋាភិបាលកម្ពុជាចំពោះការគាំទ្រដល់ធនាគារជាតិនៃកម្ពុជាក្នុងកិច្ចខិតខំប្រឹងប្រែងសំដៅរៀបចំប្រព័ន្ធធនាគារមួយប្រកបដោយប្រសិទ្ធភាព និងភាពរឹងមាំ ដែលអាចឆ្លើយតបទៅនឹងតម្រូវការរបស់សេដ្ឋកិច្ចជាតិទាំងមូល ។ ខ្ញុំក៏សូមទទួលស្គាល់នូវកម្ពស់នៃកិច្ចសហប្រតិបត្តិការដែលបានបង្ហាញដោយសមាគមធនាគារក្នុងអំឡុងឆ្នាំនេះ ព្រមទាំងទទួលស្គាល់នូវកិច្ចខិតខំប្រឹងប្រែងបម្រើការងារ និងការលះបង់គ្រប់បែបយ៉ាងរបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាផងដែរ ។ ដូចដែលយើងទាំងអស់គ្នាបានដឹងយ៉ាងច្បាស់ហើយ នៅចំពោះមុខស្ថានភាពតានតឹងនៃវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិភពលោកបច្ចុប្បន្ន យើងក៏ជួបបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចនិងសង្គមជាច្រើនទៀតដែលទាមទារឱ្យយើងទាំងអស់គ្នាត្រូវជំនះ ដើម្បីជំរុញកម្ពុជាឆ្ពោះទៅមុខ ។

ទេសាភិបាល

ជា ចាន់តូ

# មាតិកា


ទំព័រ

ក. របាយការណ៍ប្រចាំឆ្នាំ២០០៨ ១

សេចក្តីផ្តើម ២

I. ការវិវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា ៤

១. ស្ថានភាពតម្លៃប្រាក់រៀល ៤

១.១. ការវិវត្តសន្ទស្សន៍ថ្លៃទំនិញ និងសេវា ៤

១.២. ស្ថានភាពអត្រាប្តូរប្រាក់ ៨

១.២.១. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ៨

១.២.២. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណផ្សេងៗ ៩

២. ការវិវត្តរូបិយវត្ថុ ១០

២.១. ការផ្គត់ផ្គង់រូបិយវត្ថុ ១១

២.២. កត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ ១៣

២.២.១. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា ១៣

២.២.២. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារពាណិជ្ជ ១៥

២.៣. អត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើ របស់ធនាគារពាណិជ្ជ ១៥

៣. ជញ្ជីងទូទាត់ ១៦

៣.១. គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) ១៧

៣.២. គណនីដើមទុន និងហិរញ្ញវត្ថុ ១៩

៤. ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ២០

៤.១. ការវិនិយោគទុនបម្រុងអន្តរជាតិ ២០

៤.២. អន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ ២១

៤.៣. ការគ្រប់គ្រងអាជីវកម្មមាស និងប្តូរប្រាក់ ២១

៥. សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ២១

៥.១. ការត្រួតពិនិត្យលើឯកសារ ២៣

៥.២. ការត្រួតពិនិត្យដល់ទីកន្លែង ២៣

៥.៣. ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ២៤

៥.៤. ការជម្រះបញ្ជីធនាគារ ការងាររៀបចំបទបញ្ញា ២៥

៥.៥. ការងាររៀបចំបទបញ្ញា ២៥
៥.៦. អាជ្ញាប័ណ្ណ និងការចុះបញ្ជី ២៦
៦. ការផ្គត់ផ្គង់សេវាធនាគារកណ្តាល ២៦
៦.១. សេវាផ្នែកគណនី ២៦
៦.១.១. សេវាផ្នែកគណនីចំពោះស្ថាប័នរដ្ឋ ២៦
៦.១.២. សេវាផ្នែកគណនីចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ២៧
៦.២. សេវាផាត់ទាត់ ២៧
៦.២.១. ការផាត់ទាត់មូលប្បទានប័ត្រចរឹកជាប្រាក់រៀល ២៧
៦.២.២. ការផាត់ទាត់មូលប្បទានប័ត្រចរឹកជាប្រាក់ដុល្លារអាមេរិក ២៧
៦.៣. ការងារឥណទាន ២៨
៦.៤. ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីរដ្ឋាភិបាល ២៨
៧. ការគ្រប់គ្រងចរាចរណ៍ធនប័ត្រ ៣០
៨. ការអភិវឌ្ឍប្រព័ន្ធទូទាត់ជាតិ ៣១
៩. ការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ៣១
៩.១. ការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ ៣១
៩.២. យន្តការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ៣២
៩.៣. ការបណ្តុះបណ្តាល និងការបង្កើនការយល់ដឹង ៣២

II. ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា ៣៣
១. សកម្មភាពក្រុមប្រឹក្សាភិបាល ៣៣
២. ការអភិវឌ្ឍធនធានមនុស្ស ៣៤
២.១. ស្ថិតិមន្ត្រីបុគ្គលិក ៣៤
២.២. ការងារបណ្តុះបណ្តាល ៣៤
៣. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ៣៥
៤. ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា ៣៦
III. ទំនាក់ទំនងអន្តរជាតិ ៣៦
១. ទំនាក់ទំនងពហុភាគី ៣៦
១.១. ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ ៣៦
១.២. ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ៣៧

១.៣. ទំនាក់ទំនងជាមួយអាស៊ាន ៣៨
១.៤. ទំនាក់ទំនងជាមួយ SEACEN ៣៩
២. ទំនាក់ទំនងទ្វេភាគី ៤០
សន្និដ្ឋាន ៤២

## ខ. ទិសដៅការងារឆ្នាំ២០០៩ ៤៤

ទិសដៅការងារឆ្នាំ២០០៩ ៤៥
១. ការងាររូបិយវត្ថុ ៤៥
២. ការងារប្តូរប្រាក់ ៤៥
៣. ការងារអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ ៤៦
៤. ការងារត្រួតពិនិត្យ ៤៦
៥. ការងារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ៤៦
៦. ការងារគណនេយ្យ ៤៧
៧. ការងារប្រតិបត្តិការ ៤៧
៨. ការងារបោះផ្សាយ - ឃ្លាំងបេឡា ៤៧
៩. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ៤៨
១០. ការបណ្តុះបណ្តាល ៤៨

## ឧបសម្ព័ន្ធ ៤៩

ឧបសម្ព័ន្ធ ១ : ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញ និងសេវា ប្រចាំខែ ៥០
ឧបសម្ព័ន្ធ ២ : សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ឆ្នាំ២០០៤-២០០៨ ៥១
ឧបសម្ព័ន្ធ ៣ : ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ ៥២
ឧបសម្ព័ន្ធ ៤ : ស្ថានភាពរូបិយវត្ថុ (គិតជាពាន់លានរៀល) ៥៣
ឧបសម្ព័ន្ធ ៥ : ស្ថានភាពរូបិយវត្ថុ (បម្រែបម្រួលប្រចាំខែជាភាគរយ) ៥៤
ឧបសម្ព័ន្ធ ៦ : តារាងគណនីវិភាគធនាគារជាតិនៃកម្ពុជា ៥៥
ឧបសម្ព័ន្ធ ៧ : តារាងគណនីវិភាគធនាគារពាណិជ្ជ ៥៦
ឧបសម្ព័ន្ធ ៨ : ឥណទានចំណាត់ថ្នាក់តាមមុខរបរ និងសរុបប្រតិបត្តិការប្រាក់បញ្ញើធនាគារពាណិជ្ជ ៥៧
ឧបសម្ព័ន្ធ ៩ : ជញ្ជីងទូទាត់ប្រទេសកម្ពុជា ឆ្នាំ២០០៥-២០០៨ ៥៨

# ក. របាយការណ៍ប្រចាំឆ្នាំ២០០៨

## សេចក្តីផ្តើម

ឆ្នាំ ២០០៨ ត្រូវបានកត់សម្គាល់ដោយស្ថិរភាពនយោបាយដ៏ប្រសើរ ដែលឆ្លុះបញ្ចាំងតាមរយៈការបោះឆ្នោតជាតិនៅខែកក្កដាប្រកបដោយភាពរលូននិងជោគជ័យ និងការបង្កើតរាជរដ្ឋាភិបាលថ្មីអាណត្តិទីបួននៅខែកញ្ញា ។ ស្ថិរភាពនយោបាយដ៏ខ្ជាប់ខ្ជួនជាកត្តាដ៏សំខាន់ក្នុងការទ្រទ្រង់ចំពោះដំណើរការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា ។

ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចក្នុងឆ្នាំ២០០៨ បានបង្ហាញថា សេដ្ឋកិច្ចកម្ពុជានៅតែរក្សាបានស្ថិរភាពដ៏ល្អប្រសើរមួយ ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចពិភពលោកមានភាពទន់ខ្សោយ និងទោះបីជាប្រទេសកម្ពុជាបានទទួលរងផលប៉ះពាល់ពីការឡើងថ្លៃប្រេង និងម្ហូបអាហារលើទីផ្សារពិភពលោកក្តី ។ សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថា មានកំណើនពិតប្រមាណ ៧% ធៀបនឹងកំណើន ១០,១% ក្នុងឆ្នាំ២០០៧ និង ១០,៨% ក្នុងឆ្នាំ២០០៦ ។ ការថយចុះនៃកំណើន ផ.ស.ស នេះ ជាចម្បងបណ្តាលមកពីកំណើនក្នុងវិស័យកម្មន្តសាល និងសេវាកម្ម មានកម្រិតទាបជាងមុន ដែលឆ្លុះបញ្ចាំងដោយការធ្លាក់ចុះនៃតម្រូវការប្រើប្រាស់នៅក្រៅប្រទេស ការថយចុះនៃទុនវិនិយោគ និងភ្ញៀវទេសចរណ៍បរទេស ខណៈដែលវិស័យកសិកម្មបានទទួលលទ្ធផលល្អ ។

អតិផរណាដែលស្ថិតក្នុងកម្រិតមួយដ៏ទាបជាបន្តបន្ទាប់ បានចាប់ផ្តើមរងនូវសម្ពាធកើនឡើងនាចុងឆ្នាំ២០០៧ និងបន្តរហូតដល់ឆ្នាំ២០០៨ ដែលជាចម្បងបណ្តាលមកពីឥទ្ធិពលក្រៅប្រទេស ។ អត្រាអតិផរណាប្រចាំឆ្នាំកើនពី ១០,៨% នៅខែធ្នូ ឆ្នាំ២០០៧ ដល់កម្រិតខ្ពស់បំផុត ២៥,៧% នៅខែឧសភា ឆ្នាំ ២០០៨ និងបានថយចុះមកវិញដល់ ១៣,៥% នៅខែធ្នូ ឆ្នាំ២០០៨ ។

ទោះបីជាលំហូរចូលដើមទុនក្នុងអំឡុងឆ្នាំនេះមានការថយចុះគួរឱ្យកត់សម្គាល់ក្តី ក៏សមតុល្យជញ្ជីងទូទាត់នៅតែមានអតិរេក ហើយទុនបម្រុងអន្តរជាតិដុលបានបន្តកើនឡើងថែមទៀតដល់ ២,២ពាន់លានដុល្លារអាមេរិក នៅដំណាច់ឆ្នាំ២០០៨ ។ ប្រការទាំងនេះបានឆ្លុះបញ្ចាំងឱ្យឃើញនូវស្ថិរភាពនៃអត្រាប្តូរប្រាក់រៀល ក្នុងពេលដែលប្រាក់ដុល្លារអាមេរិកបានឡើងថ្លៃធៀបនឹងរូបិយប័ណ្ណមួយចំនួន ។

ដើម្បីគ្រប់គ្រងលើសម្ពាធអតិផរណា ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវវិធានការកាត់បន្ថយសាច់ប្រាក់ងាយស្រួលដែលលើសនៅក្នុងប្រព័ន្ធធនាគារ សំដៅបន្ធូរបន្ថយមួយចំណែកនូវសម្ពាធនៃតម្រូវការក្នុងស្រុកទៅលើសេដ្ឋកិច្ច ។

ការអនុវត្តជំហានទីពីរនៃកំណែទម្រង់វិស័យហិរញ្ញវត្ថុដូចមានចែងនៅក្នុង "ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥" ដែលបានទទួលការអនុម័តកាលពីថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៧ បានដំណើរការយ៉ាងរលូនស្របតាមគោលដៅសម្រាប់ឆ្នាំ២០០៨ ។ គោលបំណងរួម គឺជំរុញការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុមួយរឹងមាំ ផ្អែកលើទីផ្សារដើម្បីជួយដល់ការកេណ្ឌប្រមូលប្រភពធនធាន និងការទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ។ លទ្ធផល

ដែលរំពឹងទុកពីកំណែទម្រង់នេះគឺ ប្រព័ន្ធហិរញ្ញវត្ថុមួយមានភាពរឹងមាំអាចធន់បាននឹងវិបត្តិផ្សេងៗ និងប្រកបដោយប្រសិទ្ធភាព ។

ក្នុងអំឡុងឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាសម្រេចបានសមិទ្ធផលថ្មីៗជាច្រើនក្នុងការអភិវឌ្ឍវិស័យធនាគារ ។ វិស័យហិរញ្ញវត្ថុទទួលបាននូវវឌ្ឍនភាពដ៏លឿន ដោយបានប្រែក្លាយទៅជាវិស័យឯកជនមានដំណើរការតាមលក្ខណៈទីផ្សារ និងធ្វើសកម្មភាពអន្តរការិយកម្មប្រកបដោយប្រសិទ្ធភាព ។ ជាមួយគ្នានេះ មុខងារផ្នែកបញ្ញត្តិកម្ម និងផ្នែកត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជាក៏ត្រូវបានពង្រឹងគួរឱ្យកត់សម្គាល់ ហើយការពង្រឹងគុណភាពវិស័យធនាគារបានធ្វើឱ្យដើមទុនធនាគារត្រូវបានបង្កើនឡើងយ៉ាងខ្ពស់មួយកម្រិតទៀត ។ ទន្ទឹមនោះ ធនាគារជាតិនៃកម្ពុជាបានចាត់វិធានការមួយចំនួនដើម្បីគ្រប់គ្រងហានិភ័យផ្សេងៗដែលអាចបណ្តាលមកពីការពាក់ព័ន្ធរបស់ធនាគារនៅក្នុងវិស័យអចលនទ្រព្យ ។

ជារួម ទោះបីជាមានភាពចលាចលលើទីផ្សារហិរញ្ញវត្ថុ និងវិបត្តិឥណទានដ៏ធ្ងន់ធ្ងរនាពេលថ្មីៗនេះ នៅក្នុងប្រទេសឧស្សាហកម្មមួយចំនួនដូចជា អាមេរិក អឺរ៉ុប និងអាស៊ីខ្លះក៏ដោយ ក៏ប្រព័ន្ធធនាគារនៅកម្ពុជាមិនទទួលរងផលប៉ះពាល់ពីព្រឹត្តិការណ៍ក្រៅប្រទេសនោះគួរឱ្យកត់សម្គាល់ឡើយ ។ ក៏ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏ធនាគារជាតិនៃកម្ពុជាបានលើកឡើងនូវវិធានការប្រុងប្រយ័ត្នមួយចំនួន ដើម្បីទប់ទល់នូវការរងឥទ្ធិពលដោយប្រយោលនោះដោយហ្មត់ចត់ផងដែរ ។

# I. ការវិវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា

## ១. ស្ថានភាពតម្លៃប្រាក់រៀល

### ១.១. ការវិវត្តសន្ទស្សន៍ថ្លៃទំនិញ និងសេវា

ក្នុងអំឡុងឆ្នាំ២០០៨ នេះ ថ្លៃទំនិញទូទៅនៅលើទីផ្សារអន្តរជាតិមានការកើនឡើងខ្ពស់ ក្នុងរយៈបីត្រីមាសដំបូងនៃឆ្នាំ ជាពិសេសថ្លៃស្បៀងអាហារ និងប្រេងឥន្ធនៈបានកើនឡើងយ៉ាងខ្លាំង ។ កត្តានេះបានជះឥទ្ធិពលដល់ថ្លៃទំនិញក្នុងស្រុកនៃប្រទេសកម្ពុជា ។ ជាក់ស្តែងការវិវត្តសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) បានបង្ហាញនិន្នាការកើនឡើងជាបន្តបន្ទាប់ចាប់តាំងពីដើមឆ្នាំរហូតដល់ខែសីហា ហើយបានថយចុះបន្តិចវិញនៅក្នុងអំឡុងពេលបួនខែចុងក្រោយនៃឆ្នាំ បន្ទាប់ពីមានការចុះថ្លៃប្រេងឥន្ធនៈជាសកលចាប់តាំងពីពាក់កណ្តាលឆ្នាំ រួមទាំងការទទួលបានទិន្នផលល្អក្នុងអំឡុងរដូវប្រមូលកសិផលនិងផលនេសាទនាឆ្នាំនេះមក ។ បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៧ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ក្នុងឆ្នាំនេះមានការកើនឡើងខ្ពស់ ដែលជាចម្បងបណ្តាលមកពីកំណើនថ្លៃគ្រឿងឧបភោគបរិភោគ គ្រឿងសង្ហារឹម និងសម្ភារៈប្រើប្រាស់មួយចំនួន ។




អតិផរណាមានការកើនឡើងជាបន្តបន្ទាប់ចាប់តាំងពីចុងឆ្នាំ ២០០៧ រហូតដល់កម្រិតខ្ពស់បំផុត ស្មើនឹង ២៥,៧% នៅខែឧសភា ឆ្នាំ២០០៨ តែសម្ពាធនេះមានការថយចុះជាបណ្តើរៗមកវិញចាប់តាំងពីខែមិថុនារហូតដល់ដំណាច់ឆ្នាំនេះ ពោលគឺ អតិផរណាឆ្នាំលើឆ្នាំមានកម្រិតត្រឹម ១៨% នៅខែតុលា ១៥,៧% នៅខែវិច្ឆិកា និង ១៣,៥% នៅខែធ្នូ ឆ្នាំ២០០៨ ធៀបនឹងអត្រាអតិផរណា ១០,៨% នៅខែធ្នូ ឆ្នាំ២០០៧ និង ២,៨% នៅខែធ្នូ ឆ្នាំ២០០៦ ។

ការកើនឡើងនៃអតិផរណាក្នុងឆ្នាំ ២០០៨ នេះ បណ្តាលមកពីការកើនឡើងយ៉ាងខ្លាំងនៃសន្ទស្សន៍ក្រុមធំ ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ចំនួន ២៣,៣% រួមជាមួយនឹងការកើនឡើងនៃសន្ទស្សន៍ក្រុមធំ គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់ចំនួន ២៦,១% សន្ទស្សន៍ក្រុមធំ ការថែរក្សាសុខភាពចំនួន ១០,៦% សន្ទស្សន៍ក្រុមធំ ផ្ទះសម្បែងនិងការប្រើប្រាស់ចំនួន ៥,៨% សន្ទស្សន៍ក្រុមធំ ការថែទាំខ្លួននិងសេវាផ្ទាល់ខ្លួនចំនួន ៥,៣% និងសន្ទស្សន៍ក្រុមធំដឹកជញ្ជូននិងទូរគមនាគមន៍ចំនួន ១,១% ខណៈដែលសន្ទស្សន៍ក្រុមធំ ការកំសាន្តនិងការអប់រំ និងសន្ទស្សន៍ក្រុមធំ សម្លៀកបំពាក់និងស្បែកជើងកើនឡើងតែចំនួន ០,៩% និង ០,៥% រៀងគ្នា ។ គួរកត់សម្គាល់ដែរថា ថ្លៃប្រេងសាំងនិងថ្លៃប្រេងម៉ាស៊ូតបានថយចុះប្រមាណ ២៥,១% និង ១៣,៥% ធៀបនឹងចុងឆ្នាំ២០០៧ រៀងគ្នា ។




អតិផរណាប្រចាំឆ្នាំដោយមិនរាប់បញ្ចូលក្រុមម្ហូបអាហារមានកម្រិតត្រឹម ៤,៧% ប៉ុន្តែអតិផរណាប្រចាំឆ្នាំដោយមិនរាប់បញ្ចូលក្រុមដឹកជញ្ជូននិងទូរគមនាគមន៍បានឡើងខ្ពស់ដល់កម្រិត ២០,៧% ដែលជាការឆ្លុះបញ្ចាំងឱ្យឃើញថា អតិផរណាក្នុងឆ្នាំនេះជាចម្បងបណ្តាលមកពីកំណើនថ្លៃម្ហូបអាហារ ខណៈដែលថ្លៃប្រេងឥន្ធនៈមានការចុះទាបជាងឆ្នាំមុន ។

ថ្លៃម្ហូបអាហារបានឡើងខ្ពស់ ពោលគឺមានចំណែកក្នុងអតិផរណាប្រចាំឆ្នាំ ៩,៦% ត្រូវនឹងសមាមាត្រ ៧១,៣% ខណៈដែលថ្លៃប្រេងឥន្ធនៈមានចំណែកក្នុងអតិផរណាប្រចាំឆ្នាំត្រឹម ០,១% ត្រូវនឹងសមាមាត្រ ០,៧% ក្នុងចំណោមអតិផរណា សរុបប្រចាំឆ្នាំ ១៣,៥% ។ ការកើនឡើងនៃថ្លៃម្ហូបអាហារ គឺបណ្តាលមកពីការកើនឡើងថ្លៃប្រេងឥន្ធនៈនៅលើទីផ្សារពិភពលោក ដែលមានចំណែកក្នុងកំណើនថ្លៃដើមនៃការដឹកជញ្ជូន ។




ម្យ៉ាងទៀត ការកើនឡើងនៃថ្លៃម្ហូបអាហារជាអន្តរជាតិកាលពីដើមឆ្នាំ ក៏ជាកត្តារួមចំណែកចម្បងក្នុងកំណើននេះផងដែរ ។ គួរកត់សម្គាល់ដែរថា ថ្លៃប្រេងសាំងក្នុងស្រុកបានកើន ឡើងពី ៤.៤០៣ រៀលក្នុងមួយលីត្រ នៅខែធ្នូ ឆ្នាំ ២០០៧ រហូតដល់ចំណុចខ្ពស់បំផុតគឺ ៥.៧៥០ រៀលក្នុងមួយលីត្រ នៅខែកក្កដា ឆ្នាំ ២០០៨ ត្រូវនឹងសមាមាត្រកំណើនជិត ៣១% បន្ទាប់មកក៏បានចុះថ្លៃជាបន្តបន្ទាប់មកវិញរហូតដល់ដំណាច់ឆ្នាំ ដោយមានតម្លៃស្មើ ៣.០៣៣ រៀលក្នុងមួយលីត្រ នៅខែធ្នូ ឆ្នាំ២០០៨ ។



## ក្រាហ្វិកទី ៥ : ការប្រៀបធៀបចលនាអតិផរណា ផ្អែកលើរង្វាស់ផ្សេងៗ

(ឆ្នាំ២០០៥-ឆ្នាំ២០០៨)




## ក្រាហ្វិកទី ៦ : បម្រែបម្រួលសន្ទស្សន៍រងថ្លៃទំនិញប្រើប្រាស់ និងសេវា

(បម្រែបម្រួលជាភាគរយ ខែលើខែ)



## ១.២. ស្ថានភាពអត្រាប្តូរប្រាក់

### ១.២.១. ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក

នៅក្នុងឆ្នាំ ២០០៨ នេះ ប្រាក់រៀលធៀបជាមួយប្រាក់ដុល្លារអាមេរិកនៅតែរក្សាស្ថិរភាពជាទូទៅ ។ អត្រាប្តូរប្រាក់រៀលមធ្យមប្រចាំឆ្នាំគឺ ៤.០៦៥ រៀល ក្នុងមួយដុល្លារអាមេរិក នៅឆ្នាំ២០០៨ នេះ ធៀបនឹងអត្រាមធ្យមនាឆ្នាំកន្លងទៅដែលមានកម្រិត ៤.០៦២ រៀល ក្នុងមួយដុល្លារអាមេរិក ឃើញថាមានការថយចុះបន្តិចបន្តួច ។

ក្នុងឆ្នាំ ២០០៨ នេះ តាមការគណនាដោយផ្អែកលើអត្រាទិញទីផ្សារ អត្រាប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបានកើនឡើងប្រមាណ ២,៧% គឺពី ៤.០០០ រៀល ក្នុងខែធ្នូ ឆ្នាំ២០០៧ ទៅ ៤.១០៨ រៀល ក្នុង ១ ដុល្លារអាមេរិក ក្នុងខែធ្នូ ឆ្នាំ២០០៨ ។ ការចុះថ្លៃនៃប្រាក់រៀលក្នុងឆ្នាំនេះ ឆ្លុះបញ្ចាំងនូវការឡើងថ្លៃប្រាក់ដុល្លារជាទូទៅ នៅលើទីផ្សាររូបិយប័ណ្ណអន្តរជាតិ ខណៈដែលវិបត្តិហិរញ្ញវត្ថុដែលបានចាប់ផ្តើមនៅសហរដ្ឋអាមេរិកបានឆ្លងរាលដាលជាបន្តបន្ទាប់ដល់ទីផ្សារហិរញ្ញវត្ថុនៃប្រទេសជាច្រើនទៀត ។

**ក្រាហ្វិកទី ៧ : ការវិវត្តនៃអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក**

(ឆ្នាំ២០០៥-ឆ្នាំ២០០៨)



## តារាងអត្រាប្តូរប្រាក់រៀល ធៀបនឹងប្រាក់ដុល្លារអាមេរិក

(រៀលក្នុងមួយដុល្លារអាមេរិក)

| | អត្រាប្តូរប្រាក់ប្រចាំខែ ( ចុងខែ) | | | | | |
|---|---|---|---|---|---|---|
| | អត្រាទីផ្សារ | | | អត្រាផ្លូវការ | | |
| | ទិញ | លក់ | មធ្យម | ទិញ | លក់ | មធ្យម |
| ធ្នូ-០៧ | ៤.០០០ | ៤.០០៨ | ៤.០០៤ | ៣.៩៩៩ | ៤.០០៧ | ៤.០០៣ |
| មករា-០៨ | ៣.៩៩៧ | ៤.០០៥ | ៤.០០១ | ៣.៩៩៦ | ៤.០០៤ | ៤.០០០ |
| កុម្ភៈ-០៨ | ៣.៩៩៤ | ៤.០០១ | ៣.៩៩៨ | ៣.៩៩១ | ៣.៩៩៩ | ៣.៩៩៥ |
| មីនា-០៨ | ៣.៩៩៧ | ៤.០០៥ | ៤.០០១ | ៣.៩៩៥ | ៤.០០៣ | ៣.៩៩៩ |
| មេសា-០៨ | ៤.០០៦ | ៤.០១៥ | ៤.០១១ | ៣.៩៩៧ | ៤.០០៥ | ៤.០០១ |
| ឧសភា-០៨ | ៤.០៩៧ | ៤.១០៩ | ៤.១០៣ | ៤.០២២ | ៤.០៣០ | ៤.០២៦ |
| មិថុនា-០៨ | ៤.១២៤ | ៤.១៣៨ | ៤.១៣១ | ៤.០៩២ | ៤.១០០ | ៤.០៩៦ |
| កក្កដា-០៨ | ៤.១១៦ | ៤.១២៨ | ៤.១២២ | ៤.១០៧ | ៤.១១៥ | ៤.១១១ |
| សីហា-០៨ | ៤.១២៥ | ៤.១៣៦ | ៤.១៣១ | ៤.១០៧ | ៤.១១៥ | ៤.១១១ |
| កញ្ញា-០៨ | ៤.១២៣ | ៤.១៤០ | ៤.១៣២ | ៤.១១២ | ៤.១២០ | ៤.១១៦ |
| តុលា-០៨ | ៤.១១៩ | ៤.១៣១ | ៤.១២៥ | ៤.១១០ | ៤.១១៨ | ៤.១១៤ |
| វិច្ឆិកា-០៨ | ៤.០៦៩ | ៤.០៧៩ | ៤.០៧៤ | ៤.០៦៦ | ៤.០៧៤ | ៤.០៧០ |
| ធ្នូ-០៨ | ៤.១០៨ | ៤.១៣៣ | ៤.១២១ | ៤.០៧៧ | ៤.០៨៥ | ៤.០៨១ |

### ១.២.២- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណផ្សេងៗ

ការប្រៀបធៀបអត្រាប្តូរប្រាក់រៀលជាមួយរូបិយប័ណ្ណផ្សេងៗមួយចំនួន ជាពិសេសរូបិយប័ណ្ណនៃប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជា ដោយផ្អែកលើអត្រាប្តូរប្រាក់ខ្វែងបានបង្ហាញថា ក្នុងឆ្នាំ២០០៨ ប្រាក់រៀលបានឡើងថ្លៃធៀបនឹងរូបិយប័ណ្ណមួយចំនួនដូចជា ប្រាក់វ៉ុនកូរ៉េ ២៩.៥% រូបពីឥណ្ឌូណេស៊ី ១៣.៤% ប៉េសូហ្វីលីពីន ១១.៣% ប្រាក់បាតថៃ ១០.៧% ដុងវៀតណាម ៦.៤% និងប្រាក់អឺរ៉ូ ២.២% ។ ទន្ទឹមនឹងនេះដែរ ប្រាក់រៀលបានចុះថ្លៃធៀបនឹងប្រាក់យ៉េនជប៉ុន ២៦.៦% ប្រាក់យ៉ន់ចិន ៩.១% ប្រាក់ដុល្លារហុងកុង ២.៥% និងប្រាក់ដុល្លារសិង្ហបុរី ២.២% ។ គួរកត់សម្គាល់ដែរថា ក្នុងអំឡុងពេលដូចគ្នានេះ ប្រាក់ដុល្លារអាមេរិកបានរងសម្ពាធចុះថ្លៃបន្តដែរ ក្នុងនោះមានជាអាទិ៍ការចុះថ្លៃធៀបនឹង ប្រាក់យ៉េនជប៉ុន និងប្រាក់យ៉ន់ចិន។

**ក្រាហ្វិកស្ថិតិ ៨ : ការវិវត្តន៍នៃតម្លៃប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួន**




* ខ្សែគំនូសឡើងលើបង្ហាញអំពីការចុះថ្លៃនៃប្រាក់រៀល

## ២. ការវិវត្តរូបិយវត្ថុ

គោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជាមានទិសដៅរក្សាស្ថិរភាពថ្លៃ តាមរយៈការអនុវត្តរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង ដែលអំណោយផលដល់ស្ថិរភាពអត្រាប្តូរប្រាក់ ការគរពូនទុនបម្រុងអន្តរជាតិ និងការពង្រឹងជំនឿទុកចិត្តរបស់សាធារណជន ។ នៅក្នុងឆ្នាំ២០០៨ នេះ នៅចំពោះមុខអតិផរណាដ៏ខ្ពស់ ធនាគារជាតិនៃកម្ពុជាបានសម្រេចរឹតត្បិតស្ថានភាពរូបិយវត្ថុ ដោយបានបង្កើនអត្រាទុនបម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើជារូបិយប័ណ្ណពី ៨% ទៅ ១៦% មានប្រសិទ្ធភាពចាប់ពីថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០០៨ ។ ចំណុចដែលចាំបាច់ត្រូវកត់សម្គាល់មួយទៀតក្នុងឆ្នាំ ២០០៨ នេះគឺ ទោះបីជាមានព្រឹត្តិការណ៍ជ្រួលច្របល់ផ្នែកហិរញ្ញវត្ថុលើទីផ្សារសកលក្តី ជាពិសេសវិបត្តិហិរញ្ញវត្ថុនៅអាមេរិកនិងអឺរ៉ុប ក៏ប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជានៅតែរក្សាបានស្ថិរភាពនិងមានការរីកចម្រើនជាបង្គួរផងដែរ ។ ជាអាទិ៍ ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ប្រព័ន្ធធនាគារក្នុងអំឡុងឆ្នាំ២០០៨ នេះ បានបន្តនូវកំណើនខ្ពស់ជាងឆ្នាំមុន ដែលឆ្លុះបញ្ចាំងជាចម្បងនូវកំណើនដ៏ខ្ពស់នៃឥណទានចំពោះវិស័យឯកជន ។ កំណើនរូបិយវត្ថុទូទៅ (M2) មានល្បឿនទាបជាងអត្រាកំណើននាឆ្នាំកន្លងទៅ ខណៈដែលទ្រព្យសកម្មបរទេសសុទ្ធមានការថយចុះបន្តិចបន្តួចធៀបនឹងឆ្នាំមុនដែរ ។

ជាមួយគ្នានេះ អត្រាកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណ និងទ្រព្យសកម្មបរទេសរបស់ធនាគារជាតិនៃកម្ពុជាក៏បានបង្ហាញនូវកំណើនផងដែរ តែក្នុងកម្រិតមួយទាបជាងឆ្នាំ២០០៧ ។




## ២.១~ ការផ្គត់ផ្គង់រូបិយវត្ថុ

ក្នុងឆ្នាំ ២00៨ នេះ រូបិយវត្ថុទូទៅ (M2) បានកើនឡើងចំនួន ៥៤៨,២ ពាន់លានរៀល (៤,៨%) ពោលគឺកើនពី ១១.៣១0,៧ ពាន់លានរៀលក្នុងខែធ្នូ ឆ្នាំ ២00៧ ទៅ ១១.៨៥៨,៩ ពាន់លានរៀលក្នុងខែធ្នូ ឆ្នាំ ២00៨ ។ ការកើនឡើងនៃរូបិយវត្ថុទូទៅ ជាចម្បងបណ្តាលមកពីកំណើននៃរូបិយវត្ថុក្នុងចរាចរណ៍ចំនួន ៣0៥ ពាន់លានរៀល (១៥,៣%) គួបផ្សំជាមួយនឹងការកើនឡើងនៃប្រាក់បញ្ញើជារូបិយប័ណ្ណរបស់និវាសជនចំនួន ១៣៦,៨ ពាន់លានរៀល (១,៥%) ខណៈដែលប្រាក់បញ្ញើមានកាលកំណត់និងសន្សំ និងប្រាក់បញ្ញើចរន្តមានការកើនឡើងតែចំនួន ៦៨,៣ ពាន់លានរៀល (៥២,៧%) និង ៤២,៥ ពាន់លានរៀល (៦៨,៣%) រៀងគ្នា ។ កំណើននៃប្រាក់បញ្ញើជារូបិយប័ណ្ណនេះ ឆ្លុះបញ្ចាំងនូវការកើនឡើងនៃប្រាក់បញ្ញើមានកាលកំណត់ចំនួន ១.១៥៩,២ ពាន់លានរៀល (៤១,៤%) និងប្រាក់បញ្ញើចរន្តចំនួន ១៤៥,៥ ពាន់លានរៀល (៦,៥%) ខណៈដែលប្រាក់បញ្ញើសន្សំថយចុះចំនួន ១.0៤៩,១ ពាន់លានរៀល (២៣,២%) ។ ការវិវត្តរូបិយវត្ថុក្នុងឆ្នាំនេះ បានឆ្លុះបញ្ចាំងឱ្យឃើញនូវកំណើនគួរឱ្យកត់សម្គាល់នៃការប្រើប្រាស់សេវាកម្មធនាគារ បន្ទាប់ពីមានធនាគារចំណូលថ្មី ការបន្តធ្វើទំនើបកម្មប្រព័ន្ធទូទាត់របស់ធនាគារពាណិជ្ជធំៗមួយចំនួន និងការជំរុញឱ្យប្រើប្រាស់សេវាកម្មធនាគារដោយរាជរដ្ឋាភិបាលក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមក ។

## ក្រាហ្វិកទី ១០ ៖ សមាសធាតុនៃការផ្គត់ផ្គង់រូបិយវត្ថុ




## តារាងបម្រែបម្រួលជាភាគរយនៃស្ថិតិរូបិយវត្ថុសំខាន់ៗ និងសន្ទស្សន៍ថ្លៃទំនិញនិងសេវា

( បម្រែបម្រួលប្រចាំឆ្នាំជាភាគរយ )

| | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|---|
| **ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល** | -៧,៤% | -៦៣,១% | -១០១,៨% | -១២៦,៤% | -៩០,៥% | -៦៤,៥% |
| **ឥណទានចំពោះផ្នែកឯកជន** | ២៦,២% | ៣៥,៩% | ៣១,៨% | ៥១,៦% | ៧៦,០% | ៥៥,០% |
| **រូបិយវត្ថុទូទៅ (M2)** | ១៥,៣% | ៣០,០% | ១៦,១% | ៣៨,២% | ៦២,៩% | ៤,៨% |
| **រូបិយវត្ថុក្នុងចរាចរណ៍** | ១៨,៦% | ២២,៧% | ១៥,០% | ២៤,៨% | ២៤,៤% | ១៥,៣% |
| **អតិផរណាប្រចាំឆ្នាំ** | ០,៤៦% | ៥,៦២% | ៦,៦៦% | ២,៨១% | ១០,៧៩% | ១៣,៥% |

## ២.២. តួនាទីនៃបរិមាណរូបិយវត្ថុ

ក្នុងឆ្នាំ ២០០៨ រូបិយវត្ថុទូទៅមានកំណើនទាបជាងឆ្នាំមុន ការកើនឡើងនេះគឺដោយសារការកើនឡើងគួរឱ្យកត់សម្គាល់នៃទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ប្រព័ន្ធធនាគារ ខណៈដែលទ្រព្យសកម្មបរទេសសុទ្ធរបស់ប្រព័ន្ធធនាគារមានការថយចុះ ។ ទ្រព្យសកម្មក្នុងស្រុកសុទ្ធបានកើនឡើងចំនួន ៩៣៧,៤ ពាន់លានរៀល (១៦២,៧%) ខណៈដែលទ្រព្យសកម្មបរទេសសុទ្ធបានថយចុះចំនួន ៣៨៩,១ ពាន់លានរៀល (៣,៦%) ។ កំណើននៃទ្រព្យសកម្មក្នុងស្រុកសុទ្ធបណ្ដាលមកពីកំណើនគួរឱ្យកត់សម្គាល់នៃឥណទានចំពោះផ្នែកឯកជនចំនួន ៣.៥០៨,៧ ពាន់លានរៀល (៥៥,០%) ដែលជាកំណើនខ្ពស់ជាងឆ្នាំមុន ។ ប៉ុន្តែ កំណើននៃឥណទានចំពោះផ្នែកឯកជននេះ នៅក្នុងទ្រព្យសកម្មក្នុងស្រុកសុទ្ធត្រូវបានផាត់ទាត់មកវិញខ្លះដោយការថយចុះយ៉ាងខ្លាំងនៃឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលចំនួន ១.១៧១,១ ពាន់លានរៀល (៦៤,៥%) រួមទាំងការកើនឡើងនៃដើមទុនរបស់ប្រព័ន្ធធនាគារចំនួន ១.៤៦៤,៣ ពាន់លានរៀល (៣៤,០%) ។ កត្តាសំខាន់ៗនៃកំណើនឥណទានចំពោះផ្នែកឯកជនគឺ : ឥណទានចំពោះវិស័យលក់ដុំមានសមាមាត្រចំនួន ១៦,៥% សណ្ឋាគារនិងភោជនីយដ្ឋានមានសមាមាត្រចំនួន ១៣,០% វិស័យលក់រាយមានសមាមាត្រចំនួន ១២,៧% វិស័យកម្មន្តសាលមានសមាមាត្រចំនួន ១០,០% វិស័យសំណង់មានសមាមាត្រចំនួន ៧,៩% វិស័យសកម្មភាពអចលនវត្ថុមានសមាមាត្រចំនួន ៧,៥% វិស័យសេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗមានសមាមាត្រចំនួន ៦,៧% និងវិស័យកសិកម្មរុក្ខាប្រមាញ់និងនេសាទ មានសមាមាត្រចំនួន ៥,៣% នៃឥណទានសរុប ។

### ២.២.១. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា

ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជាបានថយចុះចំនួន ១.១១៥,១ ពាន់លានរៀល (៣១,៣%) ពោលគឺថយចុះពី -៣.៥៦០,៩ ពាន់លានរៀល ក្នុងខែ ធ្នូ ឆ្នាំ ២០០៧ មក -៤.៦៧៦,២ ពាន់លានរៀល ក្នុងខែ ធ្នូ ឆ្នាំ ២០០៨ នេះ បន្ទាប់ពីបានថយចុះចំនួន ១.២១៥ ពាន់លានរៀល (៥១,៨%) ក្នុងឆ្នាំ ២០០៧ ។ ការថយចុះនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ ជាចម្បងគឺបណ្ដាលមកពីការថយចុះនៃឥណទេយ្យសុទ្ធរាជរដ្ឋាភិបាលចំនួន ១.០៦៤,១ ពាន់លានរៀល (៦៥,២%) និងខ្ទង់ផ្សេងៗសុទ្ធថយចុះបន្តិចបន្តួច ។ ការថយចុះនៃឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលបណ្ដាលមកពីការកើនឡើងនៃប្រាក់បញ្ញើរាជរដ្ឋាភិបាលចំនួន ១.០៣៧ ពាន់លានរៀល (៥៣,៨%) និងការថយចុះនៃឥណទានចំពោះរាជរដ្ឋាភិបាលចំនួន ២៦,៥ ពាន់លានរៀល (៨,៩%) ។

ក្នុងអំឡុងឆ្នាំ ២០០៨ នេះដែរ ទ្រព្យសកម្មបរទេសសុទ្ធបានកើនឡើងខ្ពស់ចំនួន ២.១៩៧ ពាន់លានរៀល (២៥,៦%) ។ កំណើនទាំងអស់នេះបណ្ដាលមកពីការកើនឡើងទាំងស្រុងនៃទ្រព្យសកម្មបរទេសចំនួន ២.១៩៧ ពាន់លានរៀល (២៥,៦%) ខណៈដែលទ្រព្យអកម្មបរទេសពុំមានការប្រែប្រួល ។ គួរកត់សម្គាល់ថា ថ្លៃមាសដែលជាធាតុផ្សំមួយនៃទ្រព្យសកម្មបរទេសបានបន្តកើនឡើងបន្តិចបន្តួចទៀតក្នុងឆ្នាំ ២០០៨ នេះ ។

# តារាងតុល្យការធនាគារជាតិនៃកម្ពុជា

ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៨

## ទ្រព្យសកម្ម

(ឯកតាលានរៀល)

| អត្ថាធិប្បាយ | ចំនួនទឹកប្រាក់<br>ថ្ងៃ ៣១ ខែធ្នូ ឆ្នាំ២០០៧ | ចំនួនទឹកប្រាក់<br>ថ្ងៃ ៣១ ខែធ្នូ ឆ្នាំ២០០៨ |
|---|---|---|
| សាច់ប្រាក់ជារៀល និងជារូបិយប័ណ្ណ | ២៩៤.៦៦៦ | ១.២៧០.៥១២ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ នៅធនាគារបរទេស | ៥.៧៩១.២២១ | ៥.៧៦៦.៧៧៤ |
| ប្រាក់ SDR នៅមូលនិធិរូបិយវត្ថុអន្តរជាតិ | ៨៩៣ | ៤៥៦ |
| ប្រាក់រៀលបង់ចូលជាសមាជិកមូលនិធិរូបិយវត្ថុអន្តរជាតិ | ៥៤២.២៦៦ | ៥៦៨.៤៦៦ |
| វិនិយោគលើមូលប័ត្របរទេស | ១.៣២០.៩៩០ | ២.៧៣២.២៣០ |
| លោហធាតុមានតម្លៃ ផ្ញើនៅបរទេស | ១.៣៤៨.៨៨២ | ១.៤២៧.១៦២ |
| ឱ្យខ្ចី និងបុរេប្រទាន | | |
| - ចំពោះធនាគារពាណិជ្ជ | ៧១.៨០០ | ៨៨.១២០ |
| - ចំពោះរដ្ឋាភិបាល | ២៩៦.៥៨៧ | ២៧០.២៥៣ |
| អចលនទ្រព្យ | ៤៩១.១៣៦ | ៦១១.២៦៧ |
| ផ្សេង ៗ | ៣.០៤៩.០៤៧ | ៣.៩៣៣.០៧៧ |
| **សរុប** | **១៣.២០៧.៤៩៤** | **១៦.៥៦៩.៤១៧** |

## ទ្រព្យអកម្ម

(ឯកតាលានរៀល)

| អត្ថាធិប្បាយ | ចំនួនទឹកប្រាក់ | ចំនួនទឹកប្រាក់ |
|---|---|---|
| រូបិយវត្ថុបោះផ្សាយ | ២.២១១.៨៨៤ | ២.៨១៣.៤០២ |
| ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ | ៣.១១៨.៩០៨ | ៣.៩៣៤.៤៣២ |
| បំណុលចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ | ៦៤៦.៤៨៣ | ៦៧០.៨៦៧ |
| ប្រាក់បញ្ញើរបស់រដ្ឋាភិបាល | ១.៩២១.៧៨៦ | ២.៩៥៦.៧២៨ |
| ដើមទុន | ១០០.០០០ | ១០០.០០០ |
| ទុនបម្រុង | ១.៧២៣.៩២៦ | ១.៧៩៦.១៣៨ |
| រំលស់បង្គរទុក | ៩៦.១៩៨ | ១១៧.៩៧៥ |
| សវិធានធន | ២០៩.៦៧៩ | ២៦២.៩០៩ |
| ផ្សេង ៗ | ៣.១៧៨.៦៣៤ | ៤.០១៦.៧៧០ |
| **សរុប** | **១៣.២០៧.៤៩៤** | **១៦.៥៦៩.៤១៧** |

### ២.២.២- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារពាណិជ្ជ

ក្នុងឆ្នាំ២០០៨ ទ្រព្យសកម្មសរុបរបស់បណ្តាធនាគារពាណិជ្ជបានកើនឡើងចំនួន ៣.៧៦៥,៦ ពាន់លានរៀល (២៧,៨%) ខណៈទ្រព្យអកម្មក្នុងស្រុកក្រោមរូបភាពជាប្រាក់បញ្ញើបានកើនឡើងចំនួន ២២៨,៤ ពាន់លានរៀល (២,៥%) ដែលជាកត្តាសំខាន់មួយគាំទ្រដល់សកម្មភាពឥណទានរបស់ធនាគារ ហើយនឹងរួមចំណែកដល់ការវិនិយោគនៅក្នុងសេដ្ឋកិច្ច ។

ទ្រព្យសកម្មក្នុងស្រុកសុទ្ធបានកើនឡើងចំនួន ១.៩៤២,១ ពាន់លានរៀល (៤៨,៣%) ក្នុងឆ្នាំ២០០៨ នេះ ។ កំណើននេះជាចម្បងបណ្តាលមកពីការកើនឡើងនៃឥណទានចំពោះផ្នែកឯកជនចំនួន ៣.៥០៨,៨ ពាន់លានរៀល (៥៥,0%) ខណៈដែលទ្រព្យសកម្មផ្សេងៗសុទ្ធបានថយចុះចំនួន ១.៤៥៨,៦ ពាន់លានរៀល (៦៨,២%) និងឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលបានថយចុះចំនួន ១០៧,៦ ពាន់លានរៀល (៥៨,៥%) រីឯប្រាក់បញ្ញើរបស់បណ្តាធនាគារពាណិជ្ជនៅធនាគារជាតិនៃកម្ពុជាមិនមានការប្រែប្រួល ។ ការថយចុះនៃខ្ទង់ផ្សេងៗសុទ្ធឆ្លុះបញ្ចាំងមួយផ្នែកពីការបង្កើនដើមទុនរបស់ធនាគារពាណិជ្ជមួយចំនួន រួមទាំងដើមទុនរបស់ធនាគារទើបបើកថ្មីចំនួនប្រាំពីរ ដែលជារួមកើនឡើងចំនួន ១.៣៣៤ពាន់លានរៀល (៦១,៨%) ។ ប្រាក់បញ្ញើជារូបិយប័ណ្ណរបស់និវាសជន ដែលជាធាតុផ្សំចម្បងនៃទ្រព្យអកម្មក្នុងស្រុកបានកើនឡើងចំនួន ១៣៦,៨ ពាន់លានរៀល (១,៥%) ខណៈដែលប្រាក់បញ្ញើមានកាលកំណត់និងសន្សំបានកើនឡើងចំនួន ៦៣,៨ ពាន់លានរៀល (៥២,៧%) និងប្រាក់បញ្ញើចរន្តបានកើនឡើងចំនួន ២៧,៨ពាន់លានរៀល (៥៦,១%) ។

ទ្រព្យសកម្មបរទេសសុទ្ធរបស់បណ្តាធនាគារពាណិជ្ជបានថយចុះចំនួន ២.៥៨៦,១ ពាន់លានរៀល (១២០%) ពោលគឺថយពី ២.១៥៥,៦ ពាន់លានរៀល នៅខែធ្នូ ឆ្នាំ២០០៧ មក -៤៣០,៦ ពាន់លានរៀល ក្នុងខែធ្នូ ឆ្នាំ២០០៨ ។ ការថយចុះនេះបណ្តាលមកពីការថយចុះនៃទ្រព្យសកម្មបរទេសចំនួន ១.២០១,៤ ពាន់លានរៀល (៣៦,៣%) និងការកើនឡើងនៃទ្រព្យអកម្មបរទេសចំនួន ១.៣៨៤,៧ ពាន់លានរៀល (១១៩,៨%) ។

### ២.៣- អត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ

វិបត្តិហិរញ្ញវត្ថុជាសកលបានបង្ខំឱ្យធនាគារសហព័ន្ធអាមេរិក ធនាគារកណ្តាលអឺរ៉ុប និងធនាគារកណ្តាលជាច្រើនអនុវត្តគោលនយោបាយរូបិយវត្ថុបន្ធូរបន្ថយ តាមរយៈការទម្លាក់អត្រាការប្រាក់គោលរបស់ខ្លួន ដើម្បីជួយស្តារស្ថានភាពកង្វះសាច់ប្រាក់ងាយស្រួលក្នុងប្រព័ន្ធហិរញ្ញវត្ថុ ។

ដោយឡែក វិស័យធនាគារនៅកម្ពុជាក្នុងរយៈពេលកន្លងមកប៉ុន្មានឆ្នាំនេះ មានកំណើនសំណល់សាច់ប្រាក់ងាយស្រួលជាលំដាប់ ខណៈដែលឥណទានវិស័យធនាគារក៏បង្ហាញនូវកំណើនដ៏គួរឱ្យកត់សម្គាល់ ។ កំណើនឥណទាននេះ ត្រូវបានចាត់ទុកថាជាប្រភពមួយនៃកំណើនតម្រូវការក្នុងស្រុក ។

អត្រាការប្រាក់បញ្ញើរយៈពេល ៦ខែដែលវាស់ដោយកម្រិតមធ្យមថ្លឹងតាមទំហំនៃប្រតិបត្តិការធនាគារ មាននិន្នាការកើនឡើងបន្តិចម្តងៗចាប់តាំងដើមឆ្នាំ២០០៨ មក និងត្រូវបានបង្កើនថែមមួយកម្រិតទៀតចាប់ពីខែសីហា ។ អត្រាការប្រាក់បញ្ញើជារៀល និងជាដុល្លារអាមេរិក បានកើនឡើងពី ៦% និង ៤,២៣% ក្នុងខែធ្នូ ឆ្នាំ២០០៧ ដល់ ៦,៤៦% និង ៥,៤៨% ក្នុងខែធ្នូ ឆ្នាំ២០០៨ រៀងគ្នា ។

ទន្ទឹមគ្នានោះដែរ ក្នុងឆ្នាំ២០០៨ នេះ អត្រាការប្រាក់ឥណទានដែលវាស់ដោយកម្រិតមធ្យមថ្លឹងតាមទំហំនៃប្រតិបត្តិការធនាគារសម្រាប់រយៈពេល ៦ខែ ក៏មានកម្រិតទាបជាងឆ្នាំកន្លងទៅដែរ ប៉ុន្តែការប្រែប្រួលមិនមានទំហំធំគួរឱ្យកត់សម្គាល់ខ្លាំងដូចបម្រែបម្រួលនៃអត្រាការប្រាក់បញ្ញើនោះទេ ។ អត្រាការប្រាក់កម្ចីជាប្រាក់រៀលបានថយចុះពី ១៩% នាដំណាច់ឆ្នាំ ២០០៧ មក ១៨,៧៧% នាដំណាច់ឆ្នាំ ២០០៨ ។ ក្នុងរយៈពេលដដែលនេះ អត្រាការប្រាក់កម្ចីជាប្រាក់ដុល្លារអាមេរិកត្រូវបានកាត់បន្ថយពី ១៦,៧៧% មក ១៦,៣០% ។

ក្នុងរវាងមួយឆ្នាំកន្លងមកនេះ គម្លាតអត្រាការប្រាក់ជាប្រាក់រៀលបានថយចុះពី ១៣,០១% មក ១២,៣១% ចំណែកឯគម្លាតអត្រាការប្រាក់ជាប្រាក់ដុល្លារបានថយចុះពី ១២,៤៥% មក ១០,៨២% ។

## តារាងអត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើ ឆ្នាំ២០០៨
## (អត្រាមធ្យម ៦ខែ)

| | ធ្នូ-០៧ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ-០៨ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| អត្រាការប្រាក់បញ្ញើជារៀល | ៦,០០% | ៦,០៥% | ៦,០៣% | ៦,២៨% | ៦,២៨% | ៦,៣១% | ៦,៣៦% | ៦,៣៦% | ៦,៤២% | ៦,៤៤% | ៦,៤៤% | ៦,៤៤% | ៦,៤៦% |
| អត្រាការប្រាក់កម្ចីជារៀល | ១៩,០១% | ១៨,៩៩% | ១៩,១២% | ១៩,១២% | ១៩,២០% | ១៩,០៦% | ១៩,០០% | ១៩,០០% | ១៨,៩០% | ១៨,៨៩% | ១៨,៨៩% | ១៨,៨០% | ១៨,៧៧% |
| គម្លាត | ១៣,០១% | ១២,៩៤% | ១៣,០៩% | ១២,៨៤% | ១២,៩២% | ១២,៧៥% | ១២,៦៤% | ១២,៦៤% | ១២,៤៨% | ១២,៤៥% | ១២,៤៥% | ១២,៤៥% | ១២,៤៥% |
| | | | | | | | | | | | | | |
| អត្រាការប្រាក់បញ្ញើជាដុល្លារ | ៤,២៣% | ៤,២២% | ៤,២៧% | ៤,២៧% | ៤,៣០% | ៤,២៩% | ៤,៣៣% | ៤,៥៣% | ៤,៨៩% | ៤,៩៣% | ៥,២៦% | ៥,៤៧% | ៥,៤៨% |
| អត្រាការប្រាក់កម្ចីជាដុល្លារ | ១៦,៧៧% | ១៦,៦៩% | ១៦,៥២% | ១៦,៥២% | ១៦,៤២% | ១៦,៣៥% | ១៦,៤៥% | ១៦,៤៤% | ១៦,៤៤% | ១៦,៤០% | ១៦,៤០% | ១៦,៣០% | ១៦,៣០% |
| គម្លាត | ១២,៥៤% | ១២,៤៧% | ១២,២៥% | ១២,២៥% | ១២,១២% | ១២,០៦% | ១២,១២% | ១១,៩១% | ១១,៥៥% | ១១,៤៧% | ១១,១៤% | ១០,៨៣% | ១០,៨២% |

## ៣_ជញ្ជីងទូទាត់

ការប៉ាន់ស្មានដំបូងសម្រាប់ឆ្នាំ២០០៨ នេះ ប្រតិបត្តិការជញ្ជីងទូទាត់របស់ប្រទេសកម្ពុជា បានបង្ហាញថា សមតុល្យរួមមានអតិរេកចំនួន ៥៨៣,៩ លានដុល្លារអាមេរិក គឺបានកើនឡើង ១៧១,១ លានដុល្លារអាមេរិក (៤១,៤%) ធៀបនឹងឆ្នាំ២០០៧ ។ កំណើនអតិរេកសមតុល្យរួមនេះ បណ្តាលមកពីកំណើនសមតុល្យគណនីដើមទុន និងហិរញ្ញវត្ថុចំនួន ៦៧៥,៩ លានដុល្លារអាមេរិក (៥៨,២%) ស្របពេលដែលឱនភាពគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរ

ផ្លូវការ) បានកើនឡើង ៤៧៧,៩ លានដុល្លារអាមេរិក (៦៨,១%) ។ ក្នុងឆ្នាំ២០០៨ នេះ ផលធៀបនៃឱនភាពគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) និងផលិតផលក្នុងស្រុកសរុបមានកម្រិត ១១,៨% ធៀបនឹងកម្រិត ៨,១% ក្នុងឆ្នាំ២០០៧ ។

## ៣.១. គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ)

ក្នុងឆ្នាំ២០០៨ នេះ សមតុល្យគណនីចរន្តមានឱនភាពចំនួនប្រមាណ ១.១៧៩,២ លានដុល្លារអាមេរិក គឺបានកើនឡើង ៦៨,១% ធៀបនឹងឆ្នាំ២០០៧ ។ កំណើននៃឱនភាពជញ្ជីងពាណិជ្ជកម្មប្រមាណ ៣៩,២% និងឱនភាពគណនីប្រាក់ចំណូលប្រមាណ ១០,៧% គឺជាមូលហេតុសំខាន់នៃកំណើនឱនភាពសមតុល្យគណនីចរន្ត ។ ក្នុងឆ្នាំ២០០៨ នេះ អតិរេកគណនីសេវាសុទ្ធមានកំណើនប្រមាណ ១៦,៣% ក្នុងខណៈដែលគណនីបង្វែរឯកជនសុទ្ធមានការថយចុះប្រមាណ ៥,៣% ។

ក្រាហ្វស្ថិតិ ១១ : ជញ្ជីងពាណិជ្ជកម្ម (ឆ្នាំ២០០០ - ២០០៨)




ទិន្នន័យបឋម

តម្លៃនៃការនាំចេញផលិតផលក្នុងស្រុកក្នុងឆ្នាំ២០០៨ នេះ មានចំនួនប្រមាណ ៤.៤៨៩ លានដុល្លារអាមេរិក គឺបានកើនឡើង ៦១៥,១ លានដុល្លារអាមេរិក (១៥,៩%) ធៀបនឹងឆ្នាំ២០០៧ ។ កត្តារួមចំណែកយ៉ាងសំខាន់ក្នុងកំណើននេះ គឺការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌប្រមាណ ៨៧,៥ លានដុល្លារអាមេរិក និងការនាំចេញផលិតផលក្នុងស្រុកផ្សេងទៀតប្រមាណ ៥២៧,៦ លានដុល្លារអាមេរិក ។ ក្នុងឆ្នាំ២០០៨ នេះ ការនាំចេញសម្លៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌមានកំណើនប្រមាណ ៣% ធៀបនឹង ឆ្នាំ២០០៧ ដែលមានកំណើនចំនួន ៧,៩% ។ មូលហេតុចម្បងនៃកំណើនដ៏ទាបក្នុងឆ្នាំនេះធៀបនឹងឆ្នាំកន្លងទៅ គឺដោយសារវិបត្តិហិរញ្ញវត្ថុពិភពលោក ដែលធ្វើឱ្យ

តម្រូវការប្រើប្រាស់នៅបរទេសមានការថយចុះ ជាពិសេសតម្រូវការនាំចូលសម្លៀកបំពាក់របស់សហរដ្ឋអាមេរិក ។ កត្តារួមផ្សំផ្សេងទៀតគឺ សហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប គ្រោងនឹងបញ្ឈប់ការរឹតបន្តឹងការនាំចូលផលិតផលវាយនភ័ណ្ឌពីប្រទេសចិននៅដើមឆ្នាំ២០០៩ ដែលបង្កើនការប្រកួតប្រជែងដល់ឧស្សាហកម្មកាត់ដេរនៅកម្ពុជា ។ ក្នុងអំឡុងពេលដដែលនេះ ការនាំចេញផលិតផលក្នុងស្រុកផ្សេងទៀតបានកើនឡើង ៥២៧,៦ លានដុល្លារអាមេរិក (៥៦,៦%) ។ កំណើនថ្លៃនៃផលិតផលស្រូវ គ្រឿងសង្ហារឹម ត្រី កៅស៊ូ និងផលិតផលកសិកម្មផ្សេងទៀត បានរួមចំណែកក្នុងកំណើនតម្លៃនៃការនាំចេញផលិតផលក្នុងស្រុក ។

តម្លៃនៃការនាំចូលទំនិញសម្រាប់ប្រើប្រាស់ក្នុងស្រុកក្នុងឆ្នាំ២០០៨ នេះ មានចំនួនប្រមាណ ៦.៣៩៨,៩ លានដុល្លារអាមេរិក គឺបានកើនឡើង ១.១៦១,៣ លានដុល្លារអាមេរិក (២២,២%) ធៀបនឹងឆ្នាំ២០០៧ ។ កត្តាចម្បងរួមចំណែកក្នុងកំណើននេះ គឺការនាំចូលប្រេងឥន្ធនៈចំនួន ៦២៥,៣ លានដុល្លារអាមេរិក (៤៦,៤%) ។ តម្លៃនៃការនាំចូលប្រេងឥន្ធនៈក្នុងឆ្នាំនេះ មានសមាមាត្រ ៣០,៨% នៃការនាំចូលសម្រាប់ប្រើប្រាស់ក្នុងស្រុកសរុប ។ ចំណែកការនាំចូលទំនិញប្រើប្រាស់ក្នុងស្រុកផ្សេងទៀត ដូចជាការនាំចូលវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់មានកំណើន ២,៥% និងការនាំចូលទំនិញផ្សេងៗមានកំណើន ១៩,៩% ។

ក្នុងអំឡុងពេលដដែលនេះ អតិរេកគណនីសេវាសុទ្ធមានចំនួនប្រមាណ ៧៤៧,៦ លានដុល្លារអាមេរិក គឺបានកើនឡើង ១០៤,៧ លានដុល្លារអាមេរិក (១៦,៣%) ធៀបនឹងឆ្នាំ២០០៧ ។ កំណើនអតិរេកនេះ ជាលទ្ធផលនៃកំណើនប្រាក់ចំណូលពីផ្នែកសេវាប្រមាណ ២២២,៧ លានដុល្លារអាមេរិក ខណៈពេលដែលចំណាយទូទាត់ទៅឱ្យអនិវាសជនមានកំណើនប្រមាណ ១១៧,៩ លានដុល្លារអាមេរិក ។ ចំណូលពីសេវាធ្វើដំណើរ និងសេវាដឹកជញ្ជូនបានរួមចំណែកយ៉ាងសំខាន់ក្នុងកំណើននៃប្រាក់ចំណូលនេះ ។ ដោយសាររាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញគោលនយោបាយសមស្រប ដែលអនុញ្ញាតឱ្យមានការហោះហើរត្រង់ពីបណ្តាប្រទេសមួយចំនួនមកកាន់ខេត្តសៀមរាប ចំនួនភ្ញៀវទេសចរណ៍បរទេស ដែលចូលមកទស្សនាប្រទេសកម្ពុជាក្នុងឆ្នាំ២០០៨ បានកើនឡើងដល់ប្រមាណ ២.១៩៩.៧៧១ នាក់ ដែលក្នុងឆ្នាំ២០០៧ មានត្រឹមតែ ២.០១៥.១២៨ នាក់ ។ ភ្ញៀវទេសចរណ៍នៃប្រទេសកូរ៉េខាងត្បូង នៅតែជាប្រទេសនាំមុខលើចំនួនភ្ញៀវទេសចរណ៍បរទេសមកទស្សនាប្រទេសកម្ពុជា ដែលមានសមាមាត្រ ១៤% បន្ទាប់មកគឺ ប្រទេសវៀតណាម ១០% ជប៉ុន ៨% អាមេរិក ៧% និងចិន ៦% ។ ចំពោះគណនីប្រាក់ចំណូលសុទ្ធមានឱនភាពចំនួនប្រមាណ ៤២៩,៥ លានដុល្លារអាមេរិក គឺបានកើនឡើង ៤១,៤ លានដុល្លារអាមេរិក (១០,៧%) ។ កំណើនឱនភាពនេះ គឺដោយសារកំណើននៃការផ្ទេរចេញប្រាក់ចំណូលពីការវិនិយោគទៅឱ្យអនិវាសជន ។ ចំណែកគណនីបង្វែរឯកជនសុទ្ធមានអតិរេកប្រមាណ ៣៥៤,៧ លានដុល្លារអាមេរិក គឺបានថយចុះ ១៩,៧ លានដុល្លារអាមេរិក (៥,៣%) ។ ការថយចុះនៃអតិរេកនេះ គឺដោយសារមានការថយចុះការផ្ទេរប្រាក់ចូលមកប្រទេសកម្ពុជាដោយជនជាតិកម្ពុជាកំពុងធ្វើការនិងរស់នៅក្រៅប្រទេស ។

## ៣.២_ គណនីដើមទុន និងហិរញ្ញវត្ថុ

ក្នុងឆ្នាំ២០០៨ នេះ សមតុល្យគណនីចរន្ត និងបង្វែរដើមទុនមានឱនភាព ៦៩៣,២ លានដុល្លារអាមេរិក ធៀប នឹងឱនភាព ២១៦,៨ លានដុល្លារអាមេរិក នាឆ្នាំកន្លងទៅ ។ គណនីបង្វែរផ្លូវការសុទ្ធមានលំហូរចូលចំនួនប្រមាណ ៤៨៦ លានដុល្លារអាមេរិក ធៀបនឹងលំហូរចូល ៤៨៤,៥ លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៧ គឺបានកើនឡើង ១,៥ លាន ដុល្លារអាមេរិក (០,៣%) ។ គណនីបង្វែរផ្លូវការនេះបង្ហាញពីលំហូរហិរញ្ញប្បទានសហប្រតិបត្តិការ ដែលរាជរដ្ឋាភិបាល កម្ពុជាទទួលបានពីសហគមន៍អន្តរជាតិទាំងពហុភាគី និងទ្វេភាគី ក្នុងនោះរួមមាន ហិរញ្ញប្បទានសម្រាប់ទ្រទ្រង់ថវិកា ៤៤,៤ លានដុល្លារអាមេរិក ហិរញ្ញប្បទានសម្រាប់ស្បៀងអាហារ ១៩,៣ លានដុល្លារអាមេរិក ហិរញ្ញប្បទានសម្រាប់ គម្រោង ១៧៦,៩ លានដុល្លារអាមេរិក និងហិរញ្ញប្បទានសម្រាប់ជំនួយបច្ចេកទេស ២៤៥,៧ លានដុល្លារអាមេរិក ។ ទន្ទឹមនឹងនេះ លំហូរហិរញ្ញប្បទានជាប្រាក់កម្ចីផ្លូវការសុទ្ធ (មិនរាប់បញ្ចូលប្រាក់កម្ចីពីមូលនិធិរូបិយវត្ថុអន្តរជាតិ) មានចំនួនប្រមាណ ១៦៦ លានដុល្លារអាមេរិក គឺថយចុះ ១៦,៩% ធៀបនឹងឆ្នាំ២០០៧ ។ ក្នុងឆ្នាំ២០០៨ នេះ លំហូរ វិនិយោគផ្ទាល់បរទេសសុទ្ធមានចំនួនប្រមាណ ៧៨៦,៥ លានដុល្លារអាមេរិក ធៀបនឹងលំហូរចូលចំនួន ៨៦៦,៥ លាន ដុល្លារអាមេរិក ក្នុងឆ្នាំ២០០៧ គឺបានថយចុះ ៩,២% ក្នុងនោះ លំហូរចូលនៃវិនិយោគផ្ទាល់ផ្នែកធនាគារមានប្រមាណ ២៨៨,១ លានដុល្លារអាមេរិក និងផ្នែកសហគ្រាសមានប្រមាណ ៤៩៨,៤ លានដុល្លារអាមេរិក ។



ទិន្នន័យបាន់ស្មាន

កំណើននៃគណនីដើមទុន និងហិរញ្ញវត្ថុ បានបង្ហាញពីលទ្ធភាពទ្រទ្រង់ដើម្បីផាត់ទាត់ឱ្យឱនភាពគណនីចរន្ត បានទាំងស្រុង ។ ជាលទ្ធផលនៃប្រតិបត្តិការជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាក្នុងឆ្នាំ២០០៨ នេះ សមតុល្យរួមមាន អតិរេក ៥៨៣,៩ លានដុល្លារអាមេរិក ។ គិតដល់ចុងឆ្នាំ២០០៨ ទុនបម្រុងអន្តរជាតិអាចធានាទូទាត់ឱ្យការនាំចូលទំនិញ បានប្រមាណ ៣,៨ខែ ។



ទិន្នន័យប៉ាន់ស្មាន

## ៤. ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

### ៤.១. ការងារវិនិយោគទុនបម្រុងអន្តរជាតិ

ទុនវិនិយោគជារូបិយប័ណ្ណនៅបរទេសត្រូវបានវិនិយោគក្រោមរូបភាពជា Overnight ជាការទិញប័ណ្ណរតនាគារអាមេរិក ជាប្រាក់បញ្ញើរយៈកាលខ្លី ជាឧបករណ៍រយៈកាលមធ្យម (MTI) និងជាសញ្ញាប័ណ្ណរយៈកាលវែង នៅប្រទេសបារាំង លុចហ្សំបួរ ស្វីស សហរដ្ឋអាមេរិក ហុងកុង ជប៉ុន ថៃ និងសិង្ហបុរី ។ គិតត្រឹមដំណាច់ឆ្នាំ២០០៨ ទុនវិនិយោគគិតជាប្រាក់ដុល្លារអាមេរិក (ដោយមិនរាប់បញ្ចូលមាស និង SDR) មានចំនួនសរុប ២.២៥២ លានដុល្លារអាមេរិក កើនឡើង ២៧.៥% បើប្រៀបធៀបនឹងចុងខែធ្នូ ឆ្នាំ២០០៧ ដែលមានចំនួន ១.៧៦៦ លានដុល្លារអាមេរិក ។

ចំពោះប្រតិបត្តិការជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) វិញ ក្នុងឆ្នាំ២០០៨ នេះ ធនាគារជាតិនៃកម្ពុជាមានកាតព្វកិច្ចចំណាយសងលើ Net charge SDR និង Assessment SDR ចំនួន ៤៦០.២៥០ SDR ហើយកាតព្វកិច្ចនេះត្រូវបានផ្ទេរសងគ្រប់ចំនួនហើយ ។

ក្នុងឆ្នាំ២០០៨ ស្ថានភាពទីផ្សារហិរញ្ញវត្ថុពិភពលោក ជាពិសេសនៅអាមេរិកមានភាពច្របូកច្របល់ជាខ្លាំងជាមួយនឹងវិបត្តិសាច់ប្រាក់ងាយស្រួល ដែលធ្វើឱ្យអត្រាការប្រាក់រូបិយប័ណ្ណផ្សេងៗត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ខុសពីការរំពឹងទុក ។ អត្រាការប្រាក់ដុល្លារអាមេរិកត្រូវបានកាត់បន្ថយចំនួន ៨ ដង ពីកម្រិត ៣,៥% មក ០,២៥% ។ អត្រាការប្រាក់អឺរ៉ូបានកើនពី ៤% ទៅ ៤,២៥% នៅឆមាសទី១ តែត្រូវបានកាត់បន្ថយជាបន្តបន្ទាប់មកត្រឹម ២,៥០% ។ អត្រាការប្រាក់ផោនបានធ្លាក់ចុះពី ៥,៥០% មក ២% រីឯអត្រាការប្រាក់ដុល្លារអូស្ត្រាលីបានថយពី ៧% មក ៤,២៥% ។ ស្ថានភាពនេះធ្វើឱ្យអត្រាការប្រាក់ Overnight ប្រែប្រួលក្នុងរង្វង់ ៤,១៥% ទៅ ០,០១% អត្រាការប្រាក់ប័ណ្ណ

រតនាគារអាមេរិកប្រែប្រួលក្នុងរង្វង់ ៤,៨៧% ទៅ ១,០១% អត្រាការប្រាក់បញ្ញើរយៈកាលខ្លីជាប្រាក់ដុល្លារអាមេរិកប្រែប្រួលក្នុងរង្វង់ ៤,៥០% ទៅ ០,១៣% អត្រាការប្រាក់អឺរ៉ូប្រែប្រួលក្នុងរង្វង់ ៥,៣០% ទៅ ១,៩៦% អត្រាការប្រាក់ផោនប្រែប្រួលក្នុងរង្វង់ ៥,៨១% ទៅ ២,២៥% និងអត្រាការប្រាក់ដុល្លារអូស្ត្រាលីប្រែប្រួលក្នុងរង្វង់ ៧,៧៥% ទៅ ៣,៥០% ។ ឥទ្ធិពលនៃការកាត់បន្ថយអត្រាការប្រាក់ជាបន្តបន្ទាប់របស់បណ្តាធនាគារកណ្តាលនានា បានធ្វើឱ្យលទ្ធផលនៃការវិនិយោគទុនបម្រុងក្នុងឆ្នាំ២០០៨ នេះ ធ្លាក់ចុះគួរឱ្យកត់សម្គាល់ ពោលគឺបានថយចុះប្រមាណ ១២,៤៩% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០០៧ កន្លងមក ។

### ៤.២. អន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់

ដើម្បីបំពេញតម្រូវការនៅលើទីផ្សារ ជាមួយនឹងគោលដៅរក្សាស្ថិរភាពតម្លៃប្រាក់រៀល ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍ទិញនិងលក់ប្រាក់ដុល្លារអាមេរិកតាមសភាពការណ៍ជាក់ស្តែង ។

ក្នុងឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានទិញប្រាក់ដុល្លារអាមេរិកពីអាជីវករប្តូរប្រាក់ចំនួន ៨៧ លើក មានទឹកប្រាក់សរុប ២៦១,១៨ លានដុល្លារអាមេរិក ដោយចំណាយប្រាក់រៀលអស់ចំនួន ១.០៤៨,៣ ពាន់លានរៀល ។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានដាក់លក់ដេញថ្លៃប្រាក់ដុល្លារអាមេរិកចំនួន ១៦ លើក ដែលមានទឹកប្រាក់ចំនួន ៩,១ លានដុល្លារអាមេរិក ដោយបានស្រូបយកសាច់ប្រាក់រៀលពីទីផ្សារចំនួន ៣៧,៥ ពាន់លានរៀល ។

ក្នុងឆ្នាំ២០០៨ នេះដែរ ធនាគារជាតិនៃកម្ពុជាបានលក់ប្រាក់ដុល្លារឱ្យអគ្គិសនីកម្ពុជាចំនួន ៨៩,៤៥ លានដុល្លារអាមេរិក ដោយស្រូបយកប្រាក់រៀលចំនួន ៣៦៩,២៧ ពាន់លានរៀល ។

### ៤.៣. ការគ្រប់គ្រងអាជីវកម្មមាស និងប្តូរប្រាក់

ធនាគារជាតិនៃកម្ពុជាយកចិត្តទុកដាក់ជាប្រចាំ ក្នុងការពង្រឹងការគ្រប់គ្រងអាជីវកម្មមាស-ប្តូរប្រាក់ រយៈកាលកន្លងមក ដោយមានកិច្ចសហការពីអាជ្ញាធរដែនដី បានរួមចំណែកយ៉ាងសកម្មក្នុងការងារពង្រឹងសកម្មភាពនេះ ។

ក្នុងឆ្នាំ២០០៨ នេះ នៅរាជធានីភ្នំពេញ ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មលក់មាសមានចំនួន ៣៨៩ ច្បាប់ និងអាជីវកម្មប្តូរប្រាក់មានចំនួន ៣៩ ច្បាប់ ។ នៅតាមសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុងចំនួន ១៧ ការផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្មប្តូរប្រាក់ និងលក់មាសមានចំនួនសរុប ៣.៥៧១ ។

## ៥. សម្ព័ន្ធការងារជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

ប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជាបានអភិវឌ្ឍយ៉ាងឆាប់រហ័ស ដោយមានការចូលរួមយ៉ាងផុលផុសពីវិស័យឯកជន និងជាពិសេសបន្ទាប់ពីប្រទេសមានស្ថិរភាពខាងសេដ្ឋកិច្ច នយោបាយ និងមានក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិនានា ដើម្បីគាំទ្រដល់ដំណើរការនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ។ គិតមកដល់ឆ្នាំ២០០៨ នេះ ប្រព័ន្ធធនាគារនៅកម្ពុជារួមមានធនាគារពាណិជ្ជចំនួន ២៤ ធនាគារឯកទេសចំនួន ៦ ការិយាល័យតំណាងធនាគារបរទេសចំនួន ២ គ្រឹះស្ថានមីក្រូ

ហិរញ្ញវត្ថុចំនួន ១៨ និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុដែលបានចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជាចំនួន ២៦ ។ ក្រៅពីនេះ អង្គការក្រៅរដ្ឋាភិបាលប្រមាណ ៦០ កំពុងធ្វើប្រតិបត្តិការផ្តល់សេវាហិរញ្ញវត្ថុជនបទក្រៅផ្លូវការ ។

ការប្រព្រឹត្តិទៅនៃប្រព័ន្ធធនាគារនៅកម្ពុជាបានបង្ហាញឱ្យឃើញថា ជាទូទៅធនាគារមានស្ថានភាពល្អប្រសើរ ដោយមានអនុបាតសាធនភាពក្នុងកម្រិត ២៧,៧% ខ្ពស់ជាងការតម្រូវដោយប្រកាសដែលកំណត់ត្រឹម ១៥% រីឯឥណទានមិនដំណើរការស្ថិតនៅក្រោម ៥% ធៀបនឹងឆ្នាំ២០០៧ ។ ប្រព័ន្ធធនាគារទាំងមូលមានសាច់ប្រាក់ងាយស្រួលចំនួន ៨១,៣% នៅខែ ធ្នូ ឆ្នាំ ២០០៨ ។ ការផ្តល់ឥណទានសរុបរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានកំណើនពី ៦.៣៣៦ ពាន់លានរៀល ដល់ ៩.៧៤៤ ពាន់លានរៀល ដែលស្មើនឹង ៥៣,៨% និងប្រាក់បញ្ញើសរុបកើនឡើងពី ៩.៩២២ ពាន់លានរៀល ដល់ ១០.២៨៧ ពាន់លានរៀល ដែលស្មើនឹងចំនួន ៣,៧% បើធៀបនឹងឆ្នាំ២០០៧ ។ ប៉ុន្តែក្នុងត្រីមាសទី ៣ ឆ្នាំ២០០៨ ល្បឿនកំណើនប្រាក់បញ្ញើរបស់អតិថិជនសរុបបានថយចុះ បើធៀបទៅនឹងរយៈពេលដូចគ្នានៃឆ្នាំមុន ដែលជាបឋមបណ្តាលមកពីវិបត្តិសេដ្ឋកិច្ចពិភពលោក ។

ក្នុងឆ្នាំ២០០៨ ស្ថានភាពមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទបានផ្តល់ឥណទានសរុបប្រមាណ ១.១៦១ ពាន់លានរៀល ដល់អ្នកខ្ចីប្រាក់ចំនួន ៨៥២.០៩០ នាក់ កើនឡើងចំនួន ៨១% និង ៣៦% រៀងគ្នា បើធៀបនឹងឆ្នាំ២០០៧ ។ ចំពោះប្រាក់បញ្ញើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងប្រតិបត្តិករឥណទានជនបទប្រមូលប្រាក់សន្សំបានប្រមាណ ២៦ ពាន់លានរៀល ពីអ្នកផ្ញើប្រាក់ចំនួន ១៥៥.២៩១ នាក់ កើនឡើង ៧% និង ៥% រៀងគ្នា បើប្រៀបធៀបនឹងគ្រាដូចគ្នានៃឆ្នាំ២០០៧ ។ កំណើននេះបង្ហាញឱ្យឃើញពីការរីកលូតលាស់នៃវិស័យសេដ្ឋកិច្ចជនបទ ជំនឿទុកចិត្តពីវិនិយោគិននានា និងដោយអាស្រ័យលើស្ថិរភាពសេដ្ឋកិច្ច និងនយោបាយផងដែរ ។

ដើម្បីពង្រឹងការអនុវត្តការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពនិងតម្លាភាព ព្រមទាំងពិនិត្យតាមដានការអនុវត្ត ប្រកាស បទបញ្ជា សារាចរណែនាំ ដែលបានចេញផងដែរ ។ ធនាគារជាតិនៃកម្ពុជានៅតែបន្តសហការជាមួយស្ថាប័នជាតិនិងអន្តរជាតិដើម្បីជំរុញការបណ្តុះបណ្តាល កសាង និងអភិវឌ្ឍសមត្ថភាពដល់មន្ត្រីបុគ្គលិក និងជំរុញការពិនិត្យឡើងវិញ និងដាក់ចេញនូវបទប្បញ្ញត្តិថ្មី ដោយអនុលោមទៅតាមបទពិសោធន៍ និងការអនុវត្តល្អៗពីបណ្តាប្រទេសនានា ជាពិសេសផ្អែកលើគោលការណ៍គ្រឹះនៃការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព ។

ក្នុងឆ្នាំ២០០៨ ធនាគារក្នុងស្រុកចំនួន ៤ : ធនាគារកាណាឌីយ៉ា ក.អ ធនាគារសហពាណិជ្ជ ក.អ សាជីវកម្មធនាគារសិង្ហបុរី និងធនាគារមេគង្គមហាជនទទួលខុសត្រូវមានកម្រិត មានគំនិតផ្តួចផ្តើមនិងសហការដាក់ឱ្យដំណើរការប្រើប្រាស់សេវាកម្មធនាគារថ្មី ដើម្បីងាយស្រួលដកសាច់ប្រាក់តាមម៉ាស៊ីនស្វ័យប្រវត្តិ (ATM) រួមគ្នា និងការប្រើប្រាស់សេវាកម្មធនាគារតាមរយៈអ៊ីនធើណែតនៅកម្ពុជា ។ បច្ចុប្បន្ន ក្នុងប្រព័ន្ធធនាគារមានម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ ៣៣៨ កន្លែង នៅទូទាំងរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត-ក្រុងមួយចំនួន ។

ធនាគារជាតិនៃកម្ពុជានឹងចេញផ្សាយ "របាយការណ៍ត្រួតពិនិត្យធនាគារប្រចាំឆ្នាំ២០០៨" (Annual Report Banking Supervision 2008) ដែលបានបង្ហាញអំពីតួលេខសរុបមួយចំនួនរបស់ប្រព័ន្ធធនាគារនៅកម្ពុជាសម្រាប់ជាប្រយោជន៍ដល់សាធារណជនទូទៅ ដើម្បីបង្ហាញពីតម្លាភាព និងភាពគួរឱ្យជឿជាក់បាននៃប្រព័ន្ធធនាគារ ដើម្បីជួយដល់សាធារណជនក្នុងការជ្រើសរើសធនាគាររបស់ខ្លួនដោយត្រឹមត្រូវ ។

## ៥.១. ការត្រួតពិនិត្យលើឯកសារ

ការត្រួតពិនិត្យសកម្មភាពប្រតិបត្តិការរបស់ធនាគារត្រូវបានអនុវត្តជាប្រចាំ ដើម្បីពិនិត្យលើការអនុវត្តរបស់ធនាគារឱ្យស្របតាមច្បាប់ បទបញ្ញាប្រុងប្រយ័ត្ន តាមរយៈការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ COBRA ដើម្បីរកឱ្យឃើញនូវសកម្មភាពប្រតិបត្តិការណាដែលមានភាពមិនប្រក្រតី ដើម្បីមានវិធានការកែតម្រូវជាបន្ទាន់ ព្រមាន និងដាក់ពិន័យ ។ ការត្រួតពិនិត្យត្រូវបានយកចិត្តទុកដាក់ ជាពិសេសទៅលើភាពគ្រប់គ្រាន់នៃដើមទុន គុណភាពនៃទ្រព្យសកម្ម ស្ថានភាពប្រាក់ចំណេញ និងការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល ។

ពិនិត្យជារួម គ្រឹះស្ថានធនាគារភាគច្រើនមានស្ថានភាពហិរញ្ញវត្ថុល្អគួរឱ្យកត់សម្គាល់ ។ ទោះជាយ៉ាងនេះក្តី ក៏នៅមានធនាគារមួយចំនួនតូចពុំទាន់អនុវត្តបានទាំងស្រុងស្របតាមច្បាប់ និងបទបញ្ញាប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជា ដូចជាៈ ឱនភាពមូលនិធិផ្ទាល់សុទ្ធ ឥណទានមានហានិភ័យធំ ការកាន់កាប់អចលនទ្រព្យលើសកម្រិតកំណត់ និងអនុបាតសាច់ប្រាក់ងាយស្រួលជាដើម ។ រាល់ចំណុចខ្វះខាតទាំងនេះត្រូវបានចាត់វិធានការ និងធ្វើការកែតម្រូវជាបន្តបន្ទាប់ឱ្យស្របតាមបញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ។

ទន្ទឹមនឹងនេះដែរ ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន (Credit Information Sharing) បច្ចុប្បន្នដែលគ្រឹះស្ថានធនាគារកំពុងតែប្រើប្រាស់ ដើម្បីចែករំលែកព័ត៌មានឥណទានអវិជ្ជមានរវាងគ្រឹះស្ថានទាំងនោះ បាននិងកំពុងធ្វើការកែលំអឡើងវិញដើម្បីបង្កឱ្យអ្នកប្រើប្រាស់មានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មានរបស់អតិថិជន ដើម្បីវាយតម្លៃការផ្តល់ឥណទានឱ្យកាន់តែមានប្រសិទ្ធភាព ។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាមួយធនាគារពិភពលោក ដើម្បីសិក្សាលើប្រព័ន្ធចែករំលែកព័ត៌មានឥណទានបច្ចុប្បន្ន និងសិក្សាពីលទ្ធភាពបង្កើតការិយាល័យឥណទានឯកជននៅកម្ពុជា ។

## ៥.២. ការត្រួតពិនិត្យដល់ទីកន្លែង

ក្នុងឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានសម្រេចដាក់ចេញនូវផែនការត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារពាណិជ្ជចំនួន ១២ និងធនាគារឯកទេសចំនួន ៣ ។

យោងតាមផែនការដែលបានដាក់ចេញ ធនាគារជាតិនៃកម្ពុជាបានបញ្ចប់ការត្រួតពិនិត្យដល់ទីកន្លែងដោយជោគជ័យចំពោះធនាគារពាណិជ្ជចំនួន ១៤ (ក្នុងនោះ មានការត្រួតពិនិត្យតាមវិសាលភាពពេញលេញចំនួន ៨ ការ

ត្រួតពិនិត្យតាមមុខសញ្ញាចំនួន ៣ និងការត្រួតពិនិត្យពិសេសចំនួន ៣) និងធនាគារឯកទេសចំនួន ៣ (រួមមាន ការត្រួតពិនិត្យពេញលេញចំនួន ២ និងការត្រួតពិនិត្យតាមមុខសញ្ញាចំនួន ១) ។ ការអនុវត្តការត្រួតពិនិត្យដល់ទីកន្លែង គឺដើម្បីតាមដាន និងពិនិត្យពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ព្រមទាំងធ្វើការវាយតម្លៃពីភាពពិតប្រាកដ និងត្រឹមត្រូវជាក់លាក់នៃប្រតិបត្តិការទាំងនោះ ។ ទន្ទឹមនឹងនោះ ការត្រួតពិនិត្យដល់ទីកន្លែងក៏បានពិនិត្យនិងតាមដានការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិប្រុងប្រយ័ត្ននានារបស់ធនាគារ ដើម្បីគ្រប់គ្រង និងបង្ការហានិភ័យនានាដែលអាចកើតមាន ។

ផ្អែកតាមលទ្ធផលនៃការត្រួតពិនិត្យដល់ទីកន្លែងសម្រាប់ឆ្នាំ២០០៨ ស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្ម ការអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិ និងការគ្រប់គ្រងរបស់ធនាគារ មានស្ថានភាពល្អប្រសើរជាងឆ្នាំ២០០៧ ។ ប៉ុន្តែ នៅមានធនាគារខ្លះពុំទាន់បានអនុវត្តទាំងស្រុង ស្របតាមផែនការអាជីវកម្មដែលខ្លួនបានដាក់ចេញ និងមានធនាគារមួយចំនួនតូចពុំទាន់អនុវត្តបានទាំងស្រុង ស្របតាមច្បាប់ និងបទប្បញ្ញត្តិប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជា ដែលរួមមាន ការចាត់ថ្នាក់ឥណទាន និងការធ្វើសំវិធានធន ឱនភាពមូលនិធិផ្ទាល់សុទ្ធ ការគណនាមូលនិធិផ្ទាល់សុទ្ធ និងការគណនាអនុបាតសាធនភាព ។ រាល់បណ្តាចំណុចខ្វះខាតដែលបានរកឃើញក្នុងពេលចុះត្រួតពិនិត្យដល់ទីកន្លែង ធនាគារជាតិនៃកម្ពុជាបានផ្តល់ជាអនុសាសន៍ដល់សាមីគ្រឹះស្ថានធនាគារដើម្បីកែតម្រូវ ហើយធនាគារភាគច្រើនអនុវត្តបានតាមអនុសាសន៍ដែលបានដាក់ចេញ និងបានធ្វើឱ្យស្ថានភាពធនាគារទាំងនោះប្រសើរឡើងវិញ ។

## ៥.៣. ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

វិស័យហិរញ្ញវត្ថុជនបទនៅកម្ពុជាមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស ទាំងវិសាលភាពនិងទំហំប្រតិបត្តិការ ។ ឥណទានរបស់វិស័យមីក្រូហិរញ្ញវត្ថុមានកំណើនគួរឱ្យកត់សម្គាល់ ដែលបានរួមចំណែកដល់ការអភិវឌ្ឍអាជីវកម្មធុនតូច មធ្យម និងវិស័យកសិកម្មនៅកម្ពុជា ។

ផ្អែកលើការត្រួតពិនិត្យជាទូទៅបានបង្ហាញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានដំណើរការអាជីវកម្មនិងស្ថានភាពហិរញ្ញវត្ថុល្អប្រសើរ ។ ក្នុងឆ្នាំ២០០៨ នេះ ក្រៅពីការអនុវត្តការត្រួតពិនិត្យលើឯកសារជាប្រចាំ ដើម្បីតាមដានប្រតិបត្តិការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងវិភាគរបាយការណ៍ ធនាគារជាតិនៃកម្ពុជាបានធ្វើការចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១០ ប្រតិបត្តិករឥណទានជនបទចំនួន ៦ សំដៅពិនិត្យសកម្មភាពអាជីវកម្ម និងត្រួតពិនិត្យជាប្រចាំផងដែរ ដើម្បីធានាថាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទអនុវត្តតាមច្បាប់ បទប្បញ្ញត្តិ និងបទបញ្ជានានារបស់ធនាគារជាតិនៃកម្ពុជា ។ ដើម្បីរក្សាបានស្ថិរភាពនៃកំណើន និងនិរន្តរភាពចំពោះវិស័យមីក្រូហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជានៅតែបន្តត្រួតពិនិត្យ តាមដាន និងដាក់ចេញបទបញ្ជានានា ដែលអនុលោមតាមស្តង់ដារ និងការអនុវត្តជាអន្តរជាតិ ដើម្បីឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានមូលដ្ឋានច្បាស់លាស់ក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួននៅក្នុងទីផ្សារប្រកួតប្រជែងស្មើភាព ។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបន្តពង្រឹងសមត្ថភាពមន្ត្រីត្រួតពិនិត្យ និងបន្តធ្វើកិច្ចសហប្រតិបត្តិការជាមួយភ្នាក់ងារជាតិ និងអន្តរជាតិនានា ដើម្បីកៀងគរការវិនិយោគបន្ថែមទៀតសម្រាប់បម្រើឱ្យវិស័យមីក្រូហិរញ្ញវត្ថុ និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុជនបទនៅកម្ពុជាឱ្យកាន់តែទូលំទូលាយ និងរួមចំណែកលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន និងការកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ទន្ទឹមនេះដែរ ការពង្រឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឱ្យកាន់តែមានប្រសិទ្ធភាព និងឈានទៅទទួលបានប្រាក់បញ្ញើពីសាធារណជនដោយការផ្តល់អាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដូចជា :

- ផ្តល់ជំនួយបច្ចេកទេសដើម្បីធ្វើបច្ចុប្បន្នកម្មប្លង់គណនីឯកភាពថ្មី សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាប័ណ្ណ និងបន្តការផ្តល់ជំនាញការសម្រាប់តាមដានការអនុវត្តតាមប្លង់គណនី
- ផ្តល់ជំនាញការដែលមានបទពិសោធន៍ តាមរយៈជំនួយបច្ចេកទេស សម្រាប់បណ្តុះបណ្តាលមន្ត្រីបុគ្គលិកអំពីការងារត្រួតពិនិត្យលើឯកសារ និងត្រួតពិនិត្យដល់ទីកន្លែង
- ផ្តល់ជំនួយបច្ចេកទេសសម្រាប់ការចុះអង្កេតយកព័ត៌មាន ចំពោះអង្គការក្រៅរដ្ឋាភិបាលដែលកំពុងធ្វើប្រតិបត្តិការហិរញ្ញវត្ថុក្រៅផ្លូវការ ក្នុងគោលបំណងស្វែងយល់អំពីតម្រូវការសេវាមីក្រូហិរញ្ញវត្ថុ និងសកម្មភាពប្រតិបត្តិការសេវាមីក្រូហិរញ្ញវត្ថុ ។

## ៥.៤. ការជម្រះបញ្ជីធនាគារ

ក្នុងឆ្នាំ២០០៨ នេះ ធនាគារជាតិនៃកម្ពុជាបានបញ្ចប់ការជម្រះបញ្ជីធនាគារក្រៅប្រទេសទី ១ ប្រកបដោយជោគជ័យ រីឯការជម្រះបញ្ជីធនាគារផ្សេងទៀត ធនាគារជាតិនៃកម្ពុជាបន្តដំណើរការរៀបចំឯកសារ និងប្តឹងទៅតុលាការ ។

ចំពោះធនាគារ វីអាយភី ដែលបានទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្មនៅខែមករា ឆ្នាំ២០០៨ បានដាក់ពាក្យស្នើសុំជម្រះបញ្ជីដោយស្ម័គ្រចិត្តនោះ ត្រូវបានធនាគារជាតិនៃកម្ពុជាចេញប្រកាស និងដកហូតអាជ្ញាប័ណ្ណនៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០០៨ ។

## ៥.៥. ការងាររៀបចំបទបញ្ញា

ក្នុងឆ្នាំ២០០៨នេះ ធនាគារជាតិនៃកម្ពុជាបានពិនិត្យឡើងវិញនូវប្រកាស បទប្បញ្ញត្តិ បទបញ្ជា និងសារាចរណែនាំនានា ដែលបានដាក់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្ត និងបានធ្វើវិសោធនកម្មប្រកាស និងបទប្បញ្ញត្តិទាំងឡាយណាដែលពុំសមស្របនិងអនុលោមតាមការអភិវឌ្ឍនៃវិស័យហិរញ្ញវត្ថុ ។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានចេញផ្សាយប្រកាសថ្មីៗមួយចំនួនដើម្បីឱ្យធនាគារអនុវត្តស្របតាមស្តង់ដារអន្តរជាតិ ។ ធនាគារជាតិនៃកម្ពុជាបានចេញ និងធ្វើវិសោធនកម្មប្រកាស បទប្បញ្ញត្តិ បទបញ្ជា និងសារាចរណែនាំនានាដូចខាងក្រោម:

- ប្រកាសស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ
- ប្រកាសស្តីពី ភតិសន្យាហិរញ្ញវត្ថុ
- ប្រកាសស្តីពីការកំណត់ជាថ្មីនូវដើមទុនចុះបញ្ជី និងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារ
- សារាចរណែនាំស្តីពីការកំណត់ពិដានឥណទានចំពោះវិស័យអចលនទ្រព្យ
- ប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ប្រកាសស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្របសម្រាប់បុគ្គលដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ។

### ៥.៦. អាជ្ញាប័ណ្ណ និងការចុះបញ្ជី

ធនាគារជាតិនៃកម្ពុជា មានភារកិច្ចទទួលខុសត្រូវលើការផ្តល់ព័ត៌មាន ពិនិត្យ និងសិក្សារាល់សំណុំឯកសារដែលពាក់ព័ន្ធក្នុងការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណសំរាប់បើកគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

ក្នុងឆ្នាំ២០០៨ នេះ ធនាគារជាតិនៃកម្ពុជាបានសម្រេចផ្តល់អាជ្ញាប័ណ្ណជូនធនាគារពាណិជ្ជថ្មីចំនួន ៦ គឺ ធនាគារ វី អាយ ភី ធនាគារ ប៊ូយ៉ុងខ្មែរ ធនាគារ ខ្មែរយូញៀន ធនាគារ ភ្នំពេញពាណិជ្ជ ធនាគារ អង្គរកាពីតាល និងធនាគារ អូ អេស ខេ ឥណ្ឌូនេស៊ី និងធនាគារឯកទេសចំនួន១ គឺធនាគារឯកទេសប៊ែស ។ លើសពីនេះទៅទៀត ធនាគារជាតិនៃកម្ពុជាក៏បានផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុថ្មីចំនួន ២ និងបានផ្តល់វិញ្ញាបនប័ត្រចុះបញ្ជីជាប្រតិបត្តិករឥណទានជនបទដល់សមាគមអង្គការក្រៅរដ្ឋាភិបាលចំនួន២ ។

## ៦. ការផ្គត់ផ្គង់សេវាធនាគារកណ្តាល

### ៦.១. សេវាផ្នែកគណនី

ធនាគារជាតិនៃកម្ពុជាគ្រប់គ្រងគណនីស្ថាប័នរដ្ឋ អង្គភាពរដ្ឋបាលកណ្តាល គណនីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលទទួលបានការអនុញ្ញាតឱ្យធ្វើអាជីវកម្ម និងគណនីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ។ សរុបគណនីទាំងអស់មានចំនួន ១.៣០២ គណនី ដែលជារូបិយវត្ថុជាតិ និងប្រាក់ដុល្លារអាមេរិក ។ ចំនួនគណនីមានការថយចុះ ១៤% អាស្រ័យដោយគណនីមួយចំនួនត្រូវបានបិទ ។

#### ៦.១.១. សេវាផ្នែកគណនីចំពោះស្ថាប័នរដ្ឋ

ធនាគារជាតិនៃកម្ពុជាក៏បានរួមចំណែកក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើនប្រសិទ្ធភាពកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយទទួលបើកគណនីជូនស្ថាប័នរដ្ឋបាលកណ្តាលគ្រប់គ្រង និងចាត់សម្រួលសាច់ប្រាក់តាមរយៈការបង្វែរប្រាក់រតនាគារជាតិ និងបើកប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ។

ការបង់ពន្ធដារនិងពន្ធគយដោយផ្ទាល់នៅធនាគារជាតិនៃកម្ពុជាពីសំណាក់អ្នកជាប់ពន្ធបានប្រព្រឹត្តទៅដោយរលូនមានបរិមាណ ៣.៣១៦ ពាន់លានរៀល ក្នុងនោះរួមទាំងការផ្ទេរទៅបង់ពន្ធគយនៅក្រុងព្រះសីហនុចំនួន ១.០៤៦ ពាន់លានរៀលផងដែរ (គិតទាំងចំណូលជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក) ។

ធនាគារជាតិនៃកម្ពុជាបានទិញប្រាក់ដុល្លារអាមេរិកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន ៣០,២៤ លានដុល្លារ និងលក់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន ១៤៦,២៦ លានដុល្លារ ។

### ៦.១.២. សេវាផ្នែកគណនីចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

គណនីដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបើកនៅធនាគារជាតិនៃកម្ពុជារួមមាន គណនីចរន្ត គណនីប្រាក់បញ្ញើមានកាលកំណត់ គណនីប្រាក់បញ្ញើធានាលើដើមទុន និងគណនីប្រាក់បម្រុងកាតព្វកិច្ច ។ សមតុល្យប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជារៀលមានចំនួនសរុប ១៤០,៦ ពាន់លានរៀល ជាដុល្លារអាមេរិកមានចំនួន ៩៤៤,១ លានដុល្លារអាមេរិក ។

## ៦.២. សេវាផាត់ទាត់

ប្រតិបត្តិការទូទាត់តាមរយៈសភាផាត់ទាត់បានដំណើរការប្រកបដោយប្រសិទ្ធភាព និងមានប្រតិបត្តិការជារៀងរាល់ថ្ងៃធ្វើការទាំងការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀលនិងជាប្រាក់ដុល្លារអាមេរិក ។

ការប្រើប្រាស់មូលប្បទានប័ត្រមាននិន្នាការកើនជាបណ្តើរៗជាពិសេសក្នុងមជ្ឈដ្ឋានធនាគារពាណិជ្ជ និងអង្គភាពរដ្ឋ ។ ការកំណត់ឱ្យប្រើមូលប្បទានប័ត្រដើម្បីបង់ពន្ធគ្រប់ប្រភេទបានធ្វើឱ្យចំនួននៃការប្រើប្រាស់មូលប្បទានប័ត្រមានកំណើន ។

### ៦.២.១. ការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល

សភាផាត់ទាត់មូលប្បទានប័ត្រជាប្រាក់រៀលមានសមាជិកចំនួន ២៤ ដែលរួមមាន ធនាគារពាណិជ្ជចំនួន ២១ រតនាគារជាតិ ធនាគារឯកទេស ១ និងធនាគារជាតិនៃកម្ពុជា ។

ក្នុងឆ្នាំ២០០៨ នេះការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀលបានដំណើរការចំនួន ២៣៨ ថ្ងៃ មានមូលប្បទានប័ត្រចំនួន ៣២.៤៨៤ សន្លឹក ដែលមានប្រាក់សរុបចំនួន ១.៣៧៩ ពាន់លានរៀល ។ សកម្មភាពផាត់ទាត់មានកំណើនទាំងចំនួនមូលប្បទានប័ត្រ និងចំនួនទឹកប្រាក់ បើធៀបទៅនឹងការផាត់ទាត់ឆ្នាំ២០០៧ គឺមូលប្បទានប័ត្រកើន ៣៧% និងចំនួនទឹកប្រាក់កើន ៦០% ។

### ៦.២.២. ការផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់ដុល្លារអាមេរិក

សភាផាត់ទាត់មូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិកមានសមាជិកចំនួន ២៧ ដែលជាធនាគារពាណិជ្ជចំនួន ២៣ ធនាគារឯកទេស ៣ និងធនាគារជាតិនៃកម្ពុជា ។

សកម្មភាពនៃការផាត់ទាត់ក្នុងឆ្នាំ២០០៨ បានដំណើរការចំនួន ២៣៨ ថ្ងៃ ធ្វើការផាត់ទាត់លើមូលប្បទានប័ត្រចំនួន ៤១១.៨១៥ សន្លឹក មានចំនួនប្រាក់ ៧.៤៨០ លានដុល្លារអាមេរិក ។ សកម្មភាពផាត់ទាត់មានកំណើនទាំងចំនួនមូលប្បទានប័ត្រ និងចំនួនប្រាក់ បើធៀបទៅនឹងការផាត់ទាត់ឆ្នាំ២០០៧ ពោលគឺចំនួនមូលប្បទានប័ត្រកើន ២៤% និងចំនួនប្រាក់កើន ៥១% ។

## ៦.៣. ការងារឥណទាន

ក្នុងឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានផ្តល់ឥណទាន និងប្រមូលបំណុលដូចខាងក្រោម :

- គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ : សមតុល្យដើមគ្រា ៧១.៨០០ លានរៀល ឱ្យខ្ចីក្នុងគ្រា ១៧៩.៣២០ លានរៀល ប្រមូលបំណុល ១៦២.០០០ លានរៀល សមតុល្យនៅសល់ ៨៩.១២០ លានរៀល
- ឥណទានចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់សងបំណុល ODA ( Official Development Assistance ) ជប៉ុន សមតុល្យ ៣៧៨លានយ៉េន ប្រមូលបំណុល ៣៧៨ លានយ៉េន បានទូទាត់សព្វគ្រប់នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ។

## ៦.៤. ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីរាជរដ្ឋាភិបាល

### ក. ហិរញ្ញប្បទានឥតសំណងពីរាជរដ្ឋាភិបាលជប៉ុន

#### ក.១. ហិរញ្ញប្បទានឥតសំណងក្នុងគម្រោង

ក្នុងឆ្នាំ២០០៨ រដ្ឋាភិបាលជប៉ុនបានផ្តល់ហិរញ្ញប្បទានឥតសំណងដល់រាជរដ្ឋាភិបាលកម្ពុជាចំនួន ៣ គម្រោងគឺ គម្រោងអាហារូបករណ៍អភិវឌ្ឍធនធានមនុស្ស (SCHOLARSHIP 0811) មានទឹកប្រាក់ ៣៦៤ លានយ៉េន គម្រោងអភិវឌ្ឍមន្ទីរពេទ្យខេត្តកំពង់ចាម (HOSPITAL 0810) មានទឹកប្រាក់ ១.០៣៩ លានយ៉េន និងគម្រោងពង្រីកកម្មវិធីទូរទស្សន៍ជាតិកម្ពុជាមានទឹកប្រាក់ ៣៩ លានយ៉េន ។ ជាមួយគ្នានេះដែរ ធនាគារជាតិនៃកម្ពុជានៅតែបន្តធ្វើការទូទាត់គម្រោងមុនៗ ក្នុងនោះ មាន ៥ គម្រោងដែលអនុវត្តមិនទាន់ចប់នៅឡើយគឺ :

១- គម្រោងការពារទឹកជំនន់ និងកែលំអប្រព័ន្ធប្រឡាយលូក្នុងរាជធានីភ្នំពេញ ដំណាក់កាលទី២ (FLOOD 0709) មានទឹកប្រាក់ ២.៥៩៥ លានយ៉េន សម្រាប់អនុវត្តរហូតដល់ឆ្នាំ២០១០

២- គម្រោងពង្រីកផ្លូវជាតិលេខ១ មានទឹកប្រាក់ ៤.៧៤៦ លានយ៉េន សម្រាប់អនុវត្តរហូតដល់ឆ្នាំ២០០៩

៣- គម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស (SCHOLARSHIP 0710) មានទឹកប្រាក់ ៣៦៤ លានយ៉េន សម្រាប់អនុវត្តរហូតដល់ខែវិច្ឆិកា ឆ្នាំ២០១១

៤- គម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍ឧបករណ៍បោសសំអាតមីនដំណាក់កាលទី ២ មានទឹកប្រាក់ ៤៨៤ លានយ៉េន សម្រាប់អនុវត្តរហូតដល់ឆ្នាំ២០០៩

៥- គម្រោងអភិវឌ្ឍន៍មន្ទីរពេទ្យខេត្តកំពង់ចាម (HOSPITAL 2007) មានទឹកប្រាក់ ៦០ លានយ៉េន សម្រាប់អនុវត្តរហូតដល់ខែធ្នូ ឆ្នាំ២០០៨ ។

រីឯគម្រោងដែលបានបញ្ចប់ក្នុងឆ្នាំ២០០៨ នេះវិញ មានគម្រោងវារីអគ្គិសនីភាវូបនីយកម្មខ្នាតតូចនៅតំបន់ដាច់ស្រយាលខេត្តមណ្ឌលគិរីមានទឹកប្រាក់ចំនួន ១.០៦៦ លានយ៉េន គម្រោងការពារទឹកជំនន់និងកែលំអប្រព័ន្ធប្រឡាយ លូ ក្នុងរាជធានីភ្នំពេញមានទឹកប្រាក់ ៤៩ លានយ៉េន (សម្រាប់ផ្នែកគំនូរនិងប្លង់លំអិត) គម្រោងផ្គត់ផ្គង់ទឹកស្អាតតំបន់ដាច់ស្រយាលខេត្តកំពង់ចាមមានទឹកប្រាក់ ៤៣១ លានយ៉េន គម្រោងកែលំអបរិក្ខារសន្តិសុខនិងសម្ភារៈសំខាន់ៗសម្រាប់កំពង់ផែអន្តរជាតិ មានទឹកប្រាក់ ៩២៧ លានយ៉េន និងគម្រោងស្តារស្ពានសំខាន់ៗ មានទឹកប្រាក់ចំនួន ៨៤៤ លានយ៉េន ។

### ក.២. ហិរញ្ញប្បទានឥតសំណងក្រៅគម្រោង

ក្នុងឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខា Banking Arrangement សម្រាប់ជំនួយឥតសំណងក្រៅគម្រោងចំនួន ២ គម្រោង គឺគម្រោង Capital Assistance មានទឹកប្រាក់ ចំនួន ១.៤០០ លានយ៉េន និងគម្រោងសម្រាប់ជួយដល់កសិករ (Underprivileged farmers) មានទឹកប្រាក់សរុបចំនួន ៦០០ លានយ៉េន ។

### ខ. កម្ចីសម្បទានរាជរដ្ឋាភិបាលជប៉ុន

ក្នុងឆ្នាំ២០០៨ រដ្ឋាភិបាលជប៉ុនបានផ្តល់ប្រាក់កម្ចីសម្បទានដល់រាជរដ្ឋាភិបាលកម្ពុជាចំនួន ៣.៦៥១ លានយ៉េនបន្ថែមទៀត សម្រាប់អនុវត្តគម្រោងអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ។ ចំពោះគម្រោងដែលបានផ្តល់មុនៗ និងកំពុងអនុវត្តជាបន្តបន្ទាប់មាន :

- គម្រោងកម្មវិធីប្រតិបត្តិការដើម្បីកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ច (Poverty Reduction and Growth Operation (L/A No.CP-C1) ) មានទឹកប្រាក់ចំនួន ១.០០០ លានយ៉េន (ចុះហត្ថលេខា ឆ្នាំ២០០៧)
- គម្រោងអភិវឌ្ឍន៍ខ្សែបណ្តាញថាមពលអគ្គិសនីមហាអនុតំបន់ទន្លេមេគង្គ (Greater Mekong Power Network Development (Loan No.CP-P7) ) មានទឹកប្រាក់ចំនួន ២.៦៣២ លានយ៉េន (ចុះហត្ថលេខា ឆ្នាំ២០០៧)
- គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ ( SihanoukVille Port SEZ Development Project (Loan No.CP-P6) )មានទឹកប្រាក់ចំនួន ៣១៨ លានយ៉េន (ចុះហត្ថលេខា ឆ្នាំ២០០៦)
- គម្រោងបង្កើតបណ្តាញទូរគមនាគមន៍មហាអនុតំបន់ទន្លេមេគង្គ ( Greater Mekong Telecommunication Backbone Network Project (Loan No.CP-P5) ) មានទឹកប្រាក់ចំនួន ៣.០២៩ លានយ៉េន (ចុះហត្ថលេខា ឆ្នាំ២០០៥)

- គម្រោងអភិវឌ្ឍន៍កំពង់ផែក្រុងព្រះសីហនុ (Sihanoukville Port Urgent Expansion Project (Loan No.CP-P4) ) ដែលមានទឹកប្រាក់ចំនួន ៤.៣១៣ លានយ៉េន ( ចុះហត្ថលេខា ឆ្នាំ២០០៥) ។

## ៧. ការគ្រប់គ្រងចរាចរណ៍ធនបត្រ

បច្ចុប្បន្នចរន្តលំហូរចូល-ចេញនៃសាច់ប្រាក់តាមរយៈប្រព័ន្ធគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឆ្លងកាត់បេឡាប្រតិបត្តិការរបស់ធនាគារជាតិនៃកម្ពុជាមានកំណើនជាលំដាប់ ។ ជាក់ស្តែងក្នុងឆ្នាំ២០០៨ ចំណូលសាច់ប្រាក់រៀលតាមបេឡាប្រតិបត្តិការមានចំនួន ៧.៣០៥,៥ ពាន់លានរៀល បើធៀបនឹងឆ្នាំ២០០៧ កើនឡើង ៣៤% ។ ក្នុងនោះចំណូលពីឃ្លាំងសម្របសម្រួលបោះផ្សាយកើនឡើងចំនួន ៨៣២,២ ពាន់លានរៀល (៣៨%) ចំណូលពន្ធដារ-ពន្ធគយកើនឡើង ៧៨,៥ ពាន់លានរៀល (៨,២៩%) ប្រាក់បញ្ញើចរន្តកើនឡើង ៦៥៨,២ ពាន់លានរៀល (៤៥,១%) ប្រាក់បញ្ញើអគ្គិសនីកម្ពុជាកើនចំនួន ១៣០,១ ពាន់លានរៀល (៣០,១%) ចំណូលពីការលក់ប្រាក់ដុល្លារកើនឡើងចំនួន ២២,៤ ពាន់លានរៀល (៩១១%) ចំណូលពីការប្រមូលបំណុលថយចុះចំនួន ២១,៩ លានរៀល (៥៦,៤%) ចំណូលពីសាខាធនាគារជាតិនៃកម្ពុជាកើនឡើង ១៣៧,៥ ពាន់លានរៀល (៣៣%) និងចំណូលសាច់ប្រាក់ផ្សេងៗកើនឡើង ៣៤៦,៥ លានរៀល (២១,១%) បើធៀបនឹងឆ្នាំ២០០៧ ។

រីឯចំណាយសាច់ប្រាក់តាមបេឡាប្រតិបត្តិការវិញ មានចំនួន ៧.៣០៥,៥ ពាន់លានរៀល បើធៀបនឹងឆ្នាំ២០០៧ កើនឡើង ៣៤,១% ។ ក្នុងនោះ ចំណាយបញ្ចូលទៅឃ្លាំងសម្របសម្រួលបោះផ្សាយកើនឡើងចំនួន ១.១២០ ពាន់លានរៀល (៦៤%) សាច់ប្រាក់ចំណាយឱ្យរតនាគារជាតិកើនឡើង ១២២,៨ ពាន់លានរៀល (១០,៤%) ចំណាយលើការដកប្រាក់បញ្ញើចរន្តកើនចំនួន ៣៣៣,៩ ពាន់លានរៀល (៥៩,៥%) ចំណាយលើការដកប្រាក់បញ្ញើអគ្គិសនីកម្ពុជាថយចុះចំនួន ១២៦,៥ ពាន់លានរៀល (៣០,៨%) ចំណាយទិញរូបិយប័ណ្ណបរទេសកើនចំនួន ១៥៣,៦ ពាន់លានរៀល (១៨,៥%) ចំណាយឱ្យសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុងកើនចំនួន ២៤៣,៩ ពាន់លានរៀល (៣៦,១%) និងចំណាយផ្សេងៗកើនចំនួន ៧,៣ ពាន់លានរៀល (១៩,១%) បើធៀបនឹងឆ្នាំ២០០៧ ។

រីឯសកម្មភាពទទួលប្រាក់ដុល្លារអាមេរិកតាមបេឡាប្រតិបត្តិការវិញមានចំនួន ២.១៥៣,៨ លានដុល្លារអាមេរិក បើធៀបនឹងឆ្នាំ២០០៧ កើនឡើង ៨១១,៨ លានដុល្លារអាមេរិក (៦០,៥%) ។ ចំណែកឯចំណាយតាមរយៈបេឡាប្រតិបត្តិការវិញមានចំនួន ១.២៥៨ លានដុល្លារអាមេរិក គឺកើនឡើង ៤១០,១ លានដុល្លារអាមេរិក (៤៨%) បើធៀបនឹងឆ្នាំ២០០៧ ។

ធនាគារជាតិនៃកម្ពុជាបានបញ្ចេញក្រដាសប្រាក់ថ្មីសម្រាប់ដូរយកក្រដាសប្រាក់ចាស់ៗខូចគុណភាពពីទីផ្សារមកវិញ ដើម្បីធ្វើឱ្យក្រដាសប្រាក់ក្នុងចរាចរណ៍មានលក្ខណៈថ្មីស្អាតល្អ និងកាន់តែជំរុញឱ្យសាធារណជនមានជំនឿមុតមាំមកលើប្រាក់រៀល ។ ក្រដាសប្រាក់ចាស់ៗដែលដូរបាន ធនាគារជាតិនៃកម្ពុជាបានធ្វើការរាប់-ស្រាល់ជ្រើសយ៉ាងហ្មត់ចត់ និងធ្វើការកាត់កម្ទេច និងដុតបំផ្លាញចោលតាមនីតិវិធីត្រឹមត្រូវ ។ មិនតែប៉ុណ្ណោះ នៅក្នុងឆ្នាំ២០០៨ នេះ ធនាគារជាតិនៃកម្ពុជាបានបោះផ្សាយក្រដាសប្រាក់ថ្មីប្រភេទ ២០០០៛ ស៊េរីឆ្នាំ២០០៧ និងប្រភេទ ២០០០០៛ ស៊េរីឆ្នាំ២០០៨ ផងដែរ ។

ធនាគារជាតិនៃកម្ពុជាបានសហការជានិច្ចជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទប់ស្កាត់ការប្រើប្រាស់ក្រដាសប្រាក់ក្លែងក្លាយក្នុងចរាចរណ៍ ។

## ៨. ការអភិវឌ្ឍប្រព័ន្ធទូទាត់ជាតិ

ដោយមានជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី នៅចុងឆ្នាំ២០០៧ ផែនទីមគ្គុទ្ទេសក៍ និងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍប្រព័ន្ធទូទាត់ជាតិត្រូវបានកសាងឡើង ដោយមានការគាំទ្រពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតាមរយៈការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ ។

ជំហានដំបូងនៃការអភិវឌ្ឍប្រព័ន្ធទូទាត់ គឺការរៀបចំកែលំអប្រព័ន្ធផាត់ទាត់តាមរយៈការកំណត់ឱ្យប្រើមូលប្បទានប័ត្រស្តង់ដារ ដែលមានលេខកូដជាស្តង់ដារ ដើម្បីធានាឱ្យដំណើរការផាត់ទាត់ប្រព្រឹត្តទៅកាន់តែមានប្រសិទ្ធភាព និងធានាបានសុវត្ថិភាពខ្ពស់ ។ ក្នុងខែកញ្ញា ឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានចេញផ្សាយប្រកាសស្តីពីមូលប្បទានប័ត្រស្តង់ដារព្រមទាំងសេចក្តីណែនាំស្តីពីលក្ខណៈស្តង់ដារនៃមូលប្បទានប័ត្រដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ និងប្រកាសស្តីពីការកំណត់លេខអត្តសញ្ញាណនៃធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។ ប្រកាសនេះតម្រូវឱ្យធនាគារពាណិជ្ជទាំងអស់ដែលជាសមាជិកសភាផាត់ទាត់ រៀបចំបោះពុម្ពមូលប្បទានប័ត្រថ្មី ដែលត្រូវចូលជាធរមានក្នុងខែមីនា ឆ្នាំ២០០៩ ដើម្បីជំនួសមូលប្បទានប័ត្រដែលកំពុងប្រើ ។

ទន្ទឹមនេះ ជាមួយនឹងការរីកចម្រើននៃសេដ្ឋកិច្ច និងប្រព័ន្ធធនាគារ ធនាគារពាណិជ្ជចំនួន ៤ បានសហការគ្នារៀបចំការទូទាត់តាមរយៈការប្រើប្រាស់សេវាសាច់ប្រាក់ងាយស្រួល (Easy Cash) ដែលបានសម្ពោធនៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០០៨ ។ រីឯសេវាទូទាត់តាមទូរស័ព្ទចល័ត ដែលប្រើបច្ចេកវិទ្យាព័ត៌មានុសាស្ត្រ និងការកើតឡើងថ្មីៗនៃប្រព័ន្ធទូរគមនាគមន៍ក៏កំពុងតែមានការចាប់អារម្មណ៍ផងដែរចំពោះវិស័យធនាគារ ។

## ៩. ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

ព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិករបស់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG) នៅខែមិថុនា ឆ្នាំ២០០៤ នៅក្នុងពេលប្រជុំមហាសន្និបាតប្រចាំឆ្នាំលើកទី៧ ដែលបានរៀបចំនៅទីក្រុងសេអ៊ូលនៃសាធារណរដ្ឋកូរ៉េ ។ ក្នុងនាមជាសមាជិកពេញសិទ្ធិ ប្រទេសកម្ពុជាត្រូវអនុវត្តកាតព្វកិច្ចដូចមានចែងនៅក្នុងអនុសញ្ញា សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលពាក់ព័ន្ធនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងអនុសាសន៍៤០+៩ ស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF) ។

### ៩.១. ការអភិវឌ្ឍក្របខ័ណ្ឌច្បាប់

ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG) បានតម្រូវឱ្យគ្រប់ប្រទេសជាសមាជិកត្រូវមានវិធានការ និងបង្កើតយន្តការក្នុងការរុករក ទប់ស្កាត់រាល់សកម្មភាពទាំងឡាយ ដែលពាក់ព័ន្ធនឹងការសម្អាតប្រាក់ និង

នៅថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាដែលជាអាជ្ញាធរត្រួតពិនិត្យបុគ្គលរាយការណ៍ជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានចេញផ្សាយប្រកាសស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម សម្រាប់គ្រឹះស្ថានទាំងនេះ ។ ប្រកាសថ្មីនេះបានកំណត់ពីវិធានការលម្អិតដែលត្រូវប្រកាន់យកដោយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ រួមមាន វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ការរក្សាទុកឯកសារ ការត្រួតពិនិត្យប្រតិបត្តិការ យន្តការរាយការណ៍ប្រតិបត្តិការសង្ស័យ និងសាច់ប្រាក់ ការបង្កើនការយល់ដឹង និងការត្រួតពិនិត្យផ្ទៃក្នុង ។

## ៩.២. យន្តការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ រាជរដ្ឋាភិបាលបានបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលមានតួនាទីចម្បងក្នុងការទទួលរបាយការណ៍ប្រតិបត្តិការសង្ស័យ និងព័ត៌មានផ្សេងៗពីបុគ្គលរាយការណ៍ យកមកវិភាគ និងបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីស៊ើបអង្កេត ។ អង្គភាពនេះមានទីតាំងនៅធនាគារជាតិនៃកម្ពុជា និងមានលេខាធិការដ្ឋានអចិន្ត្រៃយ៍ដើម្បីធ្វើប្រតិបត្តិការប្រចាំថ្ងៃក្រោមឱវាទរបស់ក្រុមប្រឹក្សាភិបាល ដែលមានធនាគារជាតិនៃកម្ពុជាជាប្រធាន និងទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ជាសមាជិក ។ បច្ចុប្បន្ន ក្រុមប្រឹក្សាភិបាលរបស់អង្គភាពនេះបានប្រារព្ធកិច្ចប្រជុំរបស់ខ្លួនចំនួនពីរលើករួចមកហើយ ។ ដោយឡែក អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបាននឹងកំពុងទទួលរបាយការណ៍ប្រតិបត្តិការសង្ស័យពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុយកមកធ្វើការវិភាគ ដោយក្នុងនោះ មានករណីមួយចំនួនត្រូវបានបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីស៊ើបអង្កេត ។

## ៩.៣. ការបណ្តុះបណ្តាល និងការបង្កើនការយល់ដឹង

ក្នុងឆ្នាំ២០០៨ នេះ ដោយមានកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលប្រទេសម៉ាឡេស៊ី ការិយាល័យអង្គការសហប្រជាជាតិសម្រាប់ត្រួតពិនិត្យគ្រឿងញៀន និងបទឧក្រិដ្ឋ (UNODC) ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងធនាគារពិភពលោក (World Bank) អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានរៀបចំសិក្ខាសាលាស្តីពីការបង្កើតយុទ្ធសាស្ត្រ និងផែនការជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម សម្រាប់ប្រទេសកម្ពុជាចាប់ពីថ្ងៃទី ២៦-២៨ ខែសីហា ឆ្នាំ២០០៨ ដែលមានសិក្ខាកាមមកពីស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ និងសិក្ខាសាលាស្តីពីកាតព្វកិច្ចរាយការណ៍របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី ១៤-១៧ ខែតុលា ឆ្នាំ២០០៨ ដែលមានសិក្ខាកាមមកពីធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

## II- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

### ១. សមាសភាពក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជានាពេលបច្ចុប្បន្នមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| - ឯកឧត្តម ជា ចាន់តូ | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ជាប្រធាន |
| - លោកជំទាវ នាវ ច័ន្ទថាណា | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | ជាសមាជិក |
| - ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន | តំណាងប្រមុខរាជរដ្ឋាភិបាល | ជាសមាជិក |
| - ឯកឧត្តម អ៊ីវ ចុង | តំណាងមជ្ឈដ្ឋានឧត្តមសិក្សា | ជាសមាជិក |
| - ឯកឧត្តម ជូ គឹមឡេង | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| - លោក ឡាយ ម៉េងស៊ុន | តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច | ជាសមាជិក |
| - លោកស្រី ម៉ៅ សុន | តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា | ជាសមាជិក ។ |

ក្នុងឆ្នាំ២០០៨ នេះ ក្រុមប្រឹក្សាភិបាលបានប្រជុំចំនួន ៦ លើក ដើម្បីពិភាក្សា និងអនុម័តលើការងារមួយចំនួនដូចខាងក្រោម ៖

- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៦៦ នាថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ២០០៨ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យធនាគារជាតិនៃកម្ពុជាសម្រាប់ការិយបរិច្ឆេទឆ្នាំ២០០៧
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៦៧ នាថ្ងៃទី ៣ ខែ មីនា ឆ្នាំ២០០៨ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្តីពី ស្ថានភាពថវិកាធនាគារជាតិនៃកម្ពុជា ឆ្នាំ២០០៧ និងផែនការថវិកាឆ្នាំ២០០៨
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៦៨ នាថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០០៨ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០០៨ របស់ធនាគារជាតិនៃកម្ពុជា
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៦៩ នាថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០០៨ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ចំណូល-ចំណាយថវិកា ឆមាសទី ១ និងទិសដៅឆមាសទី ២ ឆ្នាំ២០០៨ របស់ធនាគារជាតិនៃកម្ពុជា
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៧០ នាថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០០៨ ពិនិត្យ និងអនុម័តលើរបាយការណ៍ស្តីពី គម្រោងផ្តល់សេវាទូទាត់តាមទូរស័ព្ទចល័តរបស់ក្រុមហ៊ុន Wing
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៧១ នាថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០០៨ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០០៨ និងទិសដៅការងារឆ្នាំ២០០៩ របស់ធនាគារជាតិនៃកម្ពុជា ។

## ២. ការអភិវឌ្ឍធនធានមនុស្ស

### ២.១. ស្ថិតិមន្ត្រីបុគ្គលិក

- ក្របខ័ណ្ឌធនាគារជាតិនៃកម្ពុជា(ទីស្នាក់ការកណ្តាល)ក្នុងឆ្នាំ ២០០៨ នេះ មានចំនួន ៧៨០រូប ( ប្រុស ៤៣៨ រូប ស្រី ៣៤២ រូប) ដោយឡែកមន្ត្រីបុគ្គលិកក្រៅក្របខ័ណ្ឌមានចំនួន២៥ រូប ( ប្រុស ១៩ រូប ស្រី ៦ រូប)
- មន្ត្រីរក្សាក្របខ័ណ្ឌមានចំនួន២រូប ( ប្រុស១ រូប ស្រី១ រូប)
- ក្របខ័ណ្ឌសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង មានចំនួន ៣៥៩រូប ( ប្រុស២០៦ រូប ស្រី ១៥៣រូប)

ដូច្នេះ សរុបក្របខ័ណ្ឌមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេសនៅក្នុងឆ្នាំ២០០៨នេះ មានចំនួន ១.១៤១រូប ( ប្រុស ៦៤៥ រូប ស្រី ៤៩៦ រូប) បើប្រៀបធៀបជាមួយក្របខ័ណ្ឌចុងខែធ្នូ ឆ្នាំ២០០៧ ដែលមានចំនួន ១១២៧រូប ( ប្រុស ៦៤១ រូប ស្រី ៤៨៦ រូប) គឺមានការប្រែប្រួលដូចតទៅ :

+ ទីស្នាក់ការកណ្តាល កើនចំនួន១៨រូប ( ចូល ៤១ រូប ចេញ ២៣ រូប)
+ មន្ត្រីរក្សាក្របខ័ណ្ឌថយចំនួន ១រូប
+ សាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុង ថយចំនួន ៣ រូប ( ចូល ៨ រូប ចេញ ១១ រូប) ។

### ២.២. ការខារបណ្តុះបណ្តាល

ឈរលើស្មារតីលើកកម្ពស់ការកសាងសមត្ថភាពធនធានមនុស្សក្នុងឆ្នាំ២០០៨ នេះ ធនាគារជាតិនៃកម្ពុជាបានបើកវគ្គណែនាំប្រតិបត្តិការសម្រាប់មន្ត្រីបុគ្គលិកសាខាធនាគារជាតិនៃកម្ពុជាជំនាន់ទី១២ មួយវគ្គ ( មានមន្ត្រីបុគ្គលិកចូលរួមចំនួន ៣៤រូប) វគ្គសុក្រឹតការជំនាន់ទី ៩ សម្រាប់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាមួយវគ្គ ( មានមន្ត្រីបុគ្គលិកចូលរួមចំនួន ៩០ រូប ក្នុងនោះមន្ត្រីបុគ្គលិកទីស្នាក់ការកណ្តាលចំនួន ៤៩ រូប និងមន្ត្រីបុគ្គលិកសាខាធនាគារជាតិនៃកម្ពុជាចំនួន ៤១ រូប) វគ្គបណ្តុះបណ្តាលភាសាអង់គ្លេសនៅតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជាចំនួន ៥ ( មានមន្ត្រីបុគ្គលិកចូលរួមសរុបចំនួន ៧៣ រូប) និងភាសាថៃ ១ ថ្នាក់ នៅសាខាធនាគារជាតិនៃកម្ពុជាខេត្តកោះកុង ( មានមន្ត្រីបុគ្គលិកចូលរួមចំនួន ៨ រូប) ព្រមទាំងបានរៀបចំសិក្ខាសាលាចំនួន ៦ លើក នៅធនាគារជាតិនៃកម្ពុជា មានមន្ត្រីបុគ្គលិកចូលរួមសរុបចំនួន ១២៨រូប ។

ម្យ៉ាងវិញទៀត ធនាគារជាតិនៃកម្ពុជាក៏បានចាត់បញ្ជូនមន្ត្រីបុគ្គលិកឱ្យទៅចូលរួមរៀនសូត្ររយៈពេលវែងចំនួន ៣វគ្គ ដែលមានមន្ត្រីបុគ្គលិកចូលរួមចំនួន ៤រូប។

ក្រៅពីការបើកវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាខាងលើនេះ ធនាគារជាតិនៃកម្ពុជាក៏បានចាត់បញ្ជូនមន្ត្រីបុគ្គលិកទៅចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំផ្សេងៗ តាមការអញ្ជើញពីបណ្តាក្រសួង-ស្ថាប័ននានាផងដែរ ។

ទន្ទឹមនឹងការបណ្តុះបណ្តាលក្នុងប្រទេស ធនាគារជាតិនៃកម្ពុជាក៏បានបន្តបង្កើនសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សនៅក្រៅប្រទេស ដោយបានចាត់បញ្ជូនមន្ត្រីបុគ្គលិកទៅចូលរួមសិក្ខាសាលាចំនួន ៨២ លើក ( មានមន្ត្រីបុគ្គលិកចូលរួមចំនួន ១២១ រូប) ទស្សនកិច្ចសិក្សាចំនួន ៥ លើក ( មានមន្ត្រីបុគ្គលិកចូលរួមចំនួន ១៨ រូប) វគ្គសិក្សារយៈពេលខ្លីចំនួន ៧ លើក ( មានមន្ត្រីបុគ្គលិកចូលរួមចំនួន ២០ រូប) វគ្គសិក្សារយៈពេលវែងថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ចំនួន ៦ លើក ( មានមន្ត្រីបុគ្គលិកចូលរួមចំនួន ១១ រូប) និងកិច្ចប្រជុំនានាចំនួន ៥០ លើក ( មានមន្ត្រីបុគ្គលិកចូលរួមចំនួន ១១៥ រូប) តាមការអញ្ជើញ និងឧបត្ថម្ភរបស់ប្រទេស និងស្ថាប័នអន្តរជាតិ ។

## ៣. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

ក្នុងឆ្នាំ ២០០៨ នេះ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ដោយបានដាក់ចេញនូវប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលនយោបាយត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារជាតិនៃកម្ពុជា និងប្រកាសស្តីពីក្រមសីលធម៌សម្រាប់មន្ត្រីបុគ្គលិកអគ្គាធិការដ្ឋាន ព្រមទាំងបានរៀបចំប្រកាសចំនួន ២ ទៀត រួមមាន ប្រកាសស្តីពីលក្ខន្តិកៈនៃគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យរបស់ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និងប្រកាសស្តីពីមុខងារ-ភារកិច្ចរបស់មន្ត្រីបុគ្គលិកអគ្គាធិការដ្ឋាន ។

បន្ទាប់ពីបានរៀបចំកែសម្រួលរចនាសម្ព័ន្ធ និងកំណត់នូវតួនាទី និងភារកិច្ចរបស់មន្ត្រីបុគ្គលិកជាសវនករនិងមន្ត្រីអធិការកិច្ចមក ការងារបណ្តុះបណ្តាលក៏បានធ្វើឡើងដើម្បីបំពាក់បំប៉នសមត្ថភាព តាមរយៈការបណ្តុះបណ្តាលជាទ្រឹស្តី និងហ្វឹកហាត់ធ្វើការងារជាក់ស្តែងដល់ទីកន្លែងជាមួយជំនាញការមូលនិធិរូបិយវត្ថុអន្តរជាតិ និងការបញ្ជូនទៅបណ្តុះបណ្តាលនៅក្រៅប្រទេស ។

ក្រោយពីទទួលបាននូវបទពិសោធន៍ពីការហ្វឹកហាត់ការងារធ្វើសវនកម្មនៅនាយកដ្ឋាន និងសាខាមួយចំនួនតាមការណែនាំរបស់ជំនាញការមក នៅឆ្នាំ២០០៨នេះ មន្ត្រីសវនកម្មបានចុះធ្វើសវនកម្មដោយខ្លួនឯងផ្ទាល់នៅនាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា ការិយាល័យគ្រប់គ្រងសាច់ប្រាក់ ការិយាល័យរាប់-ស្រាល់ជ្រើស ការិយាល័យឃ្លាំង ដោយបានតាមដានការចុះបញ្ជីនៅការិយាល័យបេឡា ការិយាល័យគណនេយ្យជំនួយ និងនាយកដ្ឋានគណនេយ្យ និងបានចុះស្រង់ព័ត៌មាននៅនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ ព្រមទាំងបានចុះធ្វើសវនកម្មនៅសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពត កោះកុង កំពង់ឆ្នាំង កំពង់ចាម ស្វាយរៀង កំពង់ធំ និងខេត្តតាកែវ ។

បន្ទាប់ពីការធ្វើសវនកម្ម របាយការណ៍សវនកម្មដែលរួមមានអនុសាសន៍មួយចំនួនផង ត្រូវបានដាក់ចេញដើម្បីធ្វើការកែលំអ ។

ក្រោយពីបានចុះធ្វើសវនកម្មនៅនាយកដ្ឋាន និងសាខាធនាគារជាតិនៃកម្ពុជាខាងលើរួចមក សៀវភៅនីតិវិធីសវនកម្មសម្រាប់នាយកដ្ឋាន និងសាខាធនាគារជាតិនៃកម្ពុជា ត្រូវបានរៀបចំនិងកែសម្រួលជាបន្តបន្ទាប់ ដើម្បីធ្វើឱ្យនីតិវិធីទាំងនេះអាចតម្រូវតាមស្ថានភាពបច្ចុប្បន្នរបស់នាយកដ្ឋាននិងអង្គភាពទាំងនោះ និងឈានទៅដល់ការមានក្រឹត្យក្រមច្បាស់លាស់សម្រាប់ធ្វើសវនកម្ម ។

ចំពោះការងារអធិការកិច្ចវិញ ត្រូវបានដំណើរការយ៉ាងសកម្មតាមរយៈការចុះឆ្នក់ត្រួតពិនិត្យដោយមិនជូនដំណឹងមុនចំនួន ១០ លើក លើគ្រប់សាខាធនាគារជាតិនៃកម្ពុជាដែលសាខាភាគច្រើនបានធ្វើអធិការកិច្ចចំនួនពីរលើក និងបានផ្តោតជាសំខាន់លើការងារធានាសុវត្ថិភាពឃ្លាំង និងការងារគ្រប់គ្រងសាច់ប្រាក់ ព្រមទាំងពង្រឹងគុណវុឌ្ឍិ និងវិន័យការងាររបស់មន្ត្រីបុគ្គលិកនៅតាមសាខាឱ្យបានកាន់តែប្រសើរឡើង ជាពិសេសបានណែនាំដល់មន្ត្រីថ្នាក់ដឹកនាំនាយកដ្ឋាននិងបណ្តាសាខាធនាគារជាតិនៃកម្ពុជា អំពីការរៀបចំបង្កើតនិងការអនុវត្តការងារត្រួតពិនិត្យផ្ទៃក្នុងឱ្យបានជាប្រចាំ នៅតាមអង្គភាពទាំងឡាយនោះ ស្របតាមគោលនយោបាយត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារជាតិនៃកម្ពុជា ។

### ៤. ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា

នៅក្នុងឆ្នាំ២០០៨ សកម្មភាពគ្រប់គ្រងសាខាតាមខេត្ត-ក្រុងរបស់ធនាគារជាតិនៃកម្ពុជា បានផ្តោតជាសំខាន់លើការពង្រឹង និងពង្រីកតួនាទីជាដៃគូរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងកិច្ចសហការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលនៅដំណាក់កាលទី ២ ជាមួយអាជ្ញាធររដ្ឋបាលនៅគ្រប់ខេត្ត-ក្រុងថែមទៀត ។ ក្នុងគោលដៅនេះ ធនាគារជាតិនៃកម្ពុជាសម្រេចបានយ៉ាងរលូននូវការបើកប្រាក់បៀវត្សជូនអង្គភាពរដ្ឋជុំវិញខេត្ត-ក្រុង កងកម្លាំងប្រដាប់អាវុធ និងក្រុមប្រឹក្សាឃុំ-សង្កាត់ និងត្រៀមលក្ខណៈបច្ចេកទេសគ្រប់យ៉ាងជាស្រេចបន្ទាប់ពីបានជ្រើសរើស បណ្តុះបណ្តាល និងផ្គត់ផ្គង់ធនធានមនុស្ស ជាមួយលិខិតបទដ្ឋានបច្ចេកទេសល្អិតល្អន់ដើម្បីទទួលនិងរាប់ប្រាក់ចំណូលពន្ធដារ-ពន្ធគយដោយផ្ទាល់ពីអ្នកជាប់ពន្ធ ។ ទន្ទឹមនោះ សាខាខេត្ត-ក្រុងមួយចំនួនរួមមាន សាខាខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប ក្រុងព្រះសីហនុ និងខេត្តស្វាយរៀង បានបើកគណនីសម្រាប់ទទួលប្រាក់បញ្ញើតាមអាណត្តិប្រៃសណីយ៍អន្តរជាតិរួចហើយ ដើម្បីសហការបម្រើអតិថិជនរបស់អង្គភាពប្រៃសណីយ៍ប្រចាំតំបន់ទាំងនោះ ។

## III. ទំនាក់ទំនងអន្តរជាតិ

### ១. ទំនាក់ទំនងពហុភាគី

#### ១.១. ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ

ក្នុងអំឡុងឆ្នាំ២០០៨នេះ បេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិបានមកធ្វើការងារនៅប្រទេសកម្ពុជាចំនួនបីលើក ។ ក្នុងនោះបេសកកម្មមាត្រាទី៤ មានចំនួនពីរលើក ដែលលើកទីមួយធ្វើឡើងពីថ្ងៃទី២៥ ដល់ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០៨ និងលើកទីពីរ ពីថ្ងៃទី ២៣ ខែតុលា ដល់ថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ២០០៨ ។ ឯបេសកកម្មពីថ្ងៃទី ២៨ ខែឧសភា ដល់ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៨ ជាបេសកកម្មជំនួយបច្ចេកទេសនៃនាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក ។ បេសកកម្មមាត្រាទី ៤ លើកទីពីរ នៃគណៈប្រតិភូមូលនិធិរូបិយវត្ថុអន្តរជាតិបានព្យាករថាសេដ្ឋកិច្ចកម្ពុជានឹងមានកំណើនប្រមាណ ៦,៥% នៅឆ្នាំ២០០៨ និង ៤,៨% នៅឆ្នាំ២០០៩ ។ ចំពោះស្ថានភាពរូបិយវត្ថុ មូលនិធិរូបិយវត្ថុអន្តរជាតិយល់ឃើញថា

ការអនុវត្តគោលនយោបាយរូបិយវត្ថុរឹតត្បិតនាពេលបច្ចុប្បន្ន តាមរយៈការបង្កើនទុនបម្រុងកាតព្វកិច្ចដល់ ១៦% លើប្រាក់បញ្ញើជារូបិយប័ណ្ណ គឺជាវិធានការសមស្រប ប៉ុន្តែនៅពេលណាមានសភាពការណ៍តឹងតែងលើបញ្ហាកង្វះសាច់ប្រាក់ងាយស្រួល អាជ្ញាធរគួរបន្ធូរបន្ថយវិធានការវិញខ្លះដែរ ។ ទន្ទឹមនោះ បេសកកម្មក៏បានសម្តែងក្តីសង្ឃឹមថា សម្ពាធអតិផរណាអាចថយចុះរហូតដល់ ១៥,៨% នៅដំណាច់ឆ្នាំ២០០៨ និង ៧,៥% នៅឆ្នាំ២០០៩ បន្ទាប់ពីបានកើនឡើងយ៉ាងខ្លាំងក្នុងអំឡុងពាក់កណ្តាលឆ្នាំ២០០៨ ដែលជាលទ្ធផលនៃការឡើងថ្លៃប្រេងលើសកលលោក ការធ្លាក់ចុះនៃតម្លៃប្រាក់ដុល្លារ និងកំណើនតម្រូវការក្នុងស្រុក ។

ចំពោះការគ្រប់គ្រងប្រព័ន្ធធនាគារវិញ នៅចំពោះមុខការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យនេះ បេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិបានផ្តល់អនុសាសន៍មួយចំនួនដល់ធនាគារជាតិនៃកម្ពុជាក្នុងគោលបំណងពង្រឹងប្រព័ន្ធធនាគារជាបន្ថែមទៀត ដែលមានជាអាទិ៍ អនុសាសន៍ក្នុងការពង្រឹងការផ្តល់អាជ្ញាប័ណ្ណ ការលើកកម្ពស់ការត្រួតពិនិត្យធនាគារ ការវាយតម្លៃឡើងវិញនៅលើប្រាតិភោគ ការធ្វើឱ្យប្រសើរឡើងនូវការធ្វើចំណាត់ថ្នាក់ឥណទានរបស់ធនាគារ និងការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់ធនាគារជាដើម ។

ធនាគារជាតិនៃកម្ពុជាបានធ្វើការសិក្សាលើអនុសាសន៍ទាំងឡាយនោះរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ និងបានអនុវត្តតាមការចាំបាច់ ។

ដូចបណ្តាឆ្នាំមុនៗដែរ មូលនិធិរូបិយវត្ថុអន្តរជាតិនៅតែបានបន្តផ្តល់ជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា ដើម្បីពង្រឹងសវនកម្មផ្ទៃក្នុងនិងការត្រួតពិនិត្យធនាគារពាណិជ្ជដល់ទីកន្លែង ។ លើសពីនោះទៀត នៅក្នុងអំឡុងពេលនៃបេសកកម្មលើកទី១ ក្នុងឆ្នាំ២០០៨ នេះ តំណាងបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិបានធ្វើបទបង្ហាញមួយចំនួនដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យធនាគារ និងការអនុវត្តគោលនយោបាយរូបិយវត្ថុនៅក្នុងប្រទេសដែលមានដុល្លារូបនីយកម្មខ្ពស់ ដូចជាក្នុងករណីប្រទេសប៉េរូ (Peru) ជាដើម ជូនមន្ត្រីធនាគារជាតិនៃកម្ពុជាដើម្បីជាចំណេះដឹងបន្ថែម ។

## ១.២. ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី

បន្ទាប់ពីបានបញ្ចប់កម្មវិធីឥណទានអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទីមួយនៅឆ្នាំ២០០៦មក រាជរដ្ឋាភិបាលកម្ពុជាបានបន្តសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ីអនុវត្តកម្មវិធីឥណទានអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទីពីរទៀត ដែលជាកម្មវិធីឥណទានទ្រទ្រង់កំណែទម្រង់ដូចមានចែងនៅក្នុងឯកសារ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥" ។ កម្មវិធីឥណទាននេះមានទឹកប្រាក់ ៤០ លានដុល្លារអាមេរិក ដែលត្រូវបែងចែកជា ៤ អនុកម្មវិធី ។ ក្នុងនោះ អនុកម្មវិធីទីមួយមានទឹកប្រាក់ចំនួន ១០ លានដុល្លារអាមេរិក ដែលបានបើកផ្តល់រួចហើយនៅឆ្នាំ២០០៧ បន្ទាប់ពីបានបំពេញលក្ខខណ្ឌដែលមានចែងនៅក្នុងអនុកម្មវិធីទីមួយជាស្ថាពរ ។

ក្នុងឆ្នាំ២០០៨ នេះ ធនាគារជាតិនៃកម្ពុជាដែលជាភ្នាក់ងារប្រតិបត្តិគម្រោង បានសហការជាមួយបណ្ដាក្រសួងពាក់ព័ន្ធ និងធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីបន្តអនុវត្តការងារកំណែទម្រង់នៅក្នុងអនុកម្មវិធីទីពីរទៀត ដែលកម្មវិធីនេះក៏ត្រូវបានទ្រទ្រង់ដោយឥណទានចំនួន ១០,៣ លានដុល្លារអាមេរិកផងដែរ ដែលមានអត្រាការប្រាក់ ១% ក្នុងមួយឆ្នាំ ក្នុងរយៈពេលអនុគ្រោះ និង ១,៥% ក្នុងមួយឆ្នាំក្នុងរយៈពេលបន្ទាប់ ។ កំណត់ហេតុនៃកិច្ចចរចាឥណទានរវាងរដ្ឋាភិបាលកម្ពុជានិងធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់អនុវត្តអនុកម្មវិធីទីពីរនៃកម្មវិធីឥណទានអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទីពីរនេះ ត្រូវបានចុះហត្ថលេខាដោយធនាគាជាតិនៃកម្ពុជា នៅថ្ងៃទី ២ ខែតុលា ឆ្នាំ២០០៨ ហើយកិច្ចព្រមព្រៀងឥណទានត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៨ ។ អនុកម្មវិធីទីពីរនេះក្រសោបនូវកំណែទម្រង់ ១៤ ចំណុច ក្នុងនោះការងារពាក់ព័ន្ធនឹងធនាគារជាតិកម្ពុជាមានចំនួន ១០ ចំណុច ។

ក្រៅពីនេះ ចំពោះការងារពាក់ព័ន្ធនឹងការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ក្រុមប្រតិបត្តិប្រព័ន្ធចែករំលែកព័ត៌មានឥណទានរបស់ធនាគារជាតិនៃកម្ពុជា បានសហការជាមួយក្រុមហ៊ុន Conical Hat និងជំនាញការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីដើម្បីធ្វើការពិនិត្យលើបញ្ហាប្រឈមដែលមានពីមុន និងស្វែងរកដំណោះស្រាយសំដៅធ្វើឱ្យប្រព័ន្ធរបាយការណ៍មានភាពត្រឹមត្រូវតាមតម្រូវការ និងមានប្រសិទ្ធភាព ។ ដំណើរការនៃប្រព័ន្ធនេះនឹងស្ថិតក្រោមការតាមដានជាប្រចាំ ។

ចំណែកសេចក្ដីព្រាងច្បាប់ស្ដីពីភតិសន្យាហិរញ្ញវត្ថុ កំពុងរង់ចាំការអនុម័តពីគណៈរដ្ឋមន្ត្រី រួចបញ្ជូនទៅរដ្ឋសភាដើម្បីពិនិត្យនិងសម្រេច ។

## ១.៣. ទំនាក់ទំនងជាមួយអាស៊ាន

ក្នុងឆ្នាំ២០០៨នេះ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងកិច្ចសហប្រតិបត្តិការថែមទៀតជាមួយបណ្ដាប្រទេសអាស៊ាន ។ គណប្រតិភូជាន់ខ្ពស់នៃធនាគារជាតិនៃកម្ពុជាបានចូលរួមកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្ដាលអាស៊ានលើកទី៤ កិច្ចប្រជុំថ្នាក់ទេសាភិបាលរងនៃធនាគារកណ្ដាលនិងកិច្ចប្រជុំថ្នាក់អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី១៦ និងកិច្ចប្រជុំពាក់ព័ន្ធផ្សេងៗទៀត ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ានទាំង១០ និងកិច្ចសហប្រតិបត្តិការអាស៊ាន+៣ (ចិន ជប៉ុន កូរ៉េ) ។ ក្នុងឆ្នាំនេះ សហប្រតិបត្តិការក្នុងអាស៊ាន ១០ បានផ្ដោតជាពិសេសលើការអភិវឌ្ឍចក្ខុវិស័យសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC Blueprint) ឆ្ពោះទៅការប្រែក្លាយតំបន់អាស៊ានឱ្យមានចលនាទំនិញ សេវាកម្ម ការវិនិយោគ និងចលនាដើមទុនដោយសេរីដោយផ្អែកលើទីផ្សារ និងមូលដ្ឋានផលិតកម្មតែមួយ ។ ផែនការនេះ តម្រូវឱ្យបណ្ដាប្រទេសអាស៊ានធ្វើសេរីភាវូបនីយកម្មសេវាកម្មហិរញ្ញវត្ថុឱ្យបានដល់កម្រិតខ្ពស់មួយនៅឆ្នាំ២០១៥ ដោយក្រសោបនូវសមាហរណកម្មលើវិស័យពាក់ព័ន្ធចំនួនបួនគឺ សមាហរណកម្ម - វិស័យហិរញ្ញវត្ថុឆ្ពោះទៅរកការអភិវឌ្ឍទីផ្សារទុន សេរីភាវូបនីយកម្មគណនីដើមទុន សេរីភាវូបនីយកម្មទៅលើ

ពាណិជ្ជកម្មនៃសេវាកម្មហិរញ្ញវត្ថុនៅក្នុងតំបន់អាស៊ាន និងការសិក្សាលើលទ្ធភាពធ្វើហិរញ្ញប្បទានហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនៅក្នុងអាស៊ាន ។ ក្រៅពីនេះ ដើម្បីបង្កើនលទ្ធភាពរារាំងការកើតមានឡើងនៃវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រទេសអាស៊ានបានចូលរួមក្នុងដំណើរការតាមដានស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងតំបន់ ដែលជាយន្តការដ៏សំខាន់មួយសំដៅដល់ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃការតាមដានស្ថានភាពសេដ្ឋកិច្ច ។

ដោយឡែក ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអាស៊ាន+៣ ធនាគារជាតិនៃកម្ពុជា បានបន្តចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំ “ពហុភាគីនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ ” សំដៅជួយដោះស្រាយភាពលំបាកនៃកង្វះសាច់ប្រាក់ងាយស្រួលក្នុងតំបន់ និងផ្តល់លទ្ធភាពឱ្យមានឥណទានសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចពេលមានវិបត្តិហិរញ្ញវត្ថុក្រោមរូបភាពជាស្វប់ពហុភាគីក្នុងចំណោមអាស៊ាន+៣ ។ សមិទ្ធផលសំខាន់ៗលើកិច្ចពិភាក្សាពីពហុភាគីនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ សម្រាប់ឆ្នាំ ២០០៨ នេះ រួមមាន ការឯកភាពជាបឋមលើទឹកប្រាក់សរុបនៃកញ្ចប់មូលនិធិចំនួន ៨០ ពាន់លានដុល្លារ ការបែងចែកវិភាគទានតាមក្រុមប្រទេសជាពីរក្រុមគឺ ក្រុមអាស៊ាន ១០ និងក្រុមប្រទេស"+៣" ក្នុងសមាមាត្រ ២០:៨០ ការពង្រឹងយន្តការតាមដានស្ថានភាពសេដ្ឋកិច្ច/ហិរញ្ញវត្ថុតំបន់ និងនីតិវិធីក្នុងការជ្រើសរើសប្រទេសធ្វើជាអ្នកសម្របសម្រួល (Coordinating Countries) សម្រាប់គ្រប់គ្រងពហុភាគីនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ ។ ទន្ទឹមនោះ ចំណុចមួយចំនួនទៀតកំពុងស្ថិតក្នុងការពិភាក្សាជាបន្តនៅឡើយ រួមមាន នីតិវិធីក្នុងការធ្វើសេចក្តីសម្រេចចិត្តលើលក្ខខណ្ឌនៃការប្រើប្រាស់ទុនរួម រូបភាពនៃការដាក់ទុនរួមនិងការជ្រើសរើសអ្នកគ្រប់គ្រងទុនរួម លក្ខខណ្ឌក្នុងការខ្ចី ការបែងចែកហានិភ័យឥណទាន និងវិភាគទានរបស់សមាជិកនីមួយៗនៅក្នុងកញ្ចប់ទឹកប្រាក់នៃប្រទេសចូលរួម ។

លើសពីនេះ ប្រទេសសមាជិកអាស៊ាន+៣ បានយកចិត្តទុកដាក់កាន់តែខ្លាំងឡើងចំពោះការងារក្រោមក្របខ័ណ្ឌ “គំនិតផ្តួចផ្តើមទីផ្សារសញ្ញាប័ណ្ណអាស៊ី” ក្នុងគោលបំណងពង្រឹងប្រព័ន្ធហិរញ្ញវត្ថុក្នុងតំបន់ តាមរយៈការអភិវឌ្ឍទីផ្សារសញ្ញាប័ណ្ណអាស៊ីឱ្យកាន់តែមានភាពស៊ីជម្រៅ និងមានលក្ខណៈងាយក្លាយជាសាច់ប្រាក់ងាយស្រួល ដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រាក់សន្សំនៅតំបន់អាស៊ី សម្រាប់ការវិនិយោគនៅអាស៊ីឱ្យកាន់តែប្រសើរឡើង ។

## ១.៤. ទំនាក់ទំនងជាមួយ SEACEN

បន្ទាប់ពីបានចូលជាសមាជិកពេញសិទ្ធចាប់តាំងពីខែមេសាឆ្នាំ២០០៦មក កិច្ចសហប្រតិបត្តិការរវាងធនាគារជាតិនៃកម្ពុជាជាមួយសមាគម SEACEN មានសកម្មភាពយ៉ាងប្រសើរជាពិសេសផ្នែកបណ្តុះបណ្តាលនិងស្រាវជ្រាវសេដ្ឋកិច្ចដែលទាក់ទងនឹងសកម្មភាពប្រតិបត្តិការរបស់ធនាគារកណ្តាលនៅបណ្តាប្រទេសអាស៊ីប៉ាស៊ីហ្វិក ។

ក្នុងអំឡុងឆ្នាំ ២០០៨ ធនាគារជាតិនៃកម្ពុជាបានទៅចូលរួមសន្និសីទថ្នាក់ទេសាភិបាលលើកទី ៤៣ ស្តីពីការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ស្ថិរភាពរូបិយវត្ថុ និងចីរភាពកំណើនសេដ្ឋកិច្ច និងកិច្ចប្រជុំលើកទី ២៧ របស់ក្រុម

ប្រឹក្សាទេសាភិបាលនៃសមាគម SEACEN ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី ២០-២៣ ខែមីនា ឆ្នាំ២០០៨ នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូណេស៊ី ។ កិច្ចប្រជុំនេះបានពិភាក្សានិងសម្រេចលើការងារមួយចំនួនដូចខាង ក្រោម :

១- ផ្តល់អាហារូបករណ៍ដល់ប្រទេសជាសមាជិក SEACEN ដែលមាន ផ.ស.ស ក្នុងមនុស្ស ១នាក់ ទាបជាង ១.៥០០ ដុល្លារអាមេរិក ចំនួន ៧រូប ដោយផ្តល់ឱ្យក្នុងម្នាក់ៗចំនួន ២.០០០ ដុល្លារអាមេរិក សម្រាប់ឆ្នាំប្រតិបត្តិការ ២០០៨-២០០៩ ។ ចំពោះធនាគារជាតិនៃកម្ពុជា នាឆ្នាំប្រតិបត្តិការ ២០០៨-២០០៩ នឹងទទួលបានអាហារូបករណ៍ចំនួន ៣រូប ។

២- សម្រេចឱ្យ SEACEN centre ចូលជាសមាជិករបស់ Irving Fisher Commitee ស្តីពីប្រព័ន្ធស្ថិតិធនាគារកណ្តាល ។

ទន្ទឹមនឹងនោះដែរ ធនាគារជាតិនៃកម្ពុជាបានទៅចូលរួមកិច្ចប្រជុំលើកទី ៦ របស់គណៈកម្មាធិការប្រតិបត្តិនៃសមាគម SEACEN (the 6th EXCO Meeting) និងសិក្ខាសាលាស្តីពីការកសាងជំនឿទុកចិត្តលើធនាគារកណ្តាលសម្រាប់អនុវត្តគោលនយោបាយរូបិយវត្ថុដែលមានប្រសិទ្ធភាព ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ២៤-២៦ ខែមករា ឆ្នាំ២០០៨ នៅខេត្តភូកេត ប្រទេសថៃ និងកិច្ចប្រជុំមួយចំនួនទៀតដែលទាក់ទងនឹងការងារត្រួតពិនិត្យប្រព័ន្ធទូទាត់ ស្រាវជ្រាវសេដ្ឋកិច្ចនិងបណ្តុះបណ្តាល និងក្រុមជំនាញការផ្នែកលំហូរមូលធន ។ ក្រៅពីនោះ ធនាគារជាតិនៃកម្ពុជាសហការជាមួយមជ្ឈមណ្ឌល SEACEN រៀបចំសិក្ខាសាលាចំនួនពីរ និងកិច្ចប្រជុំមួយនៅខេត្តសៀមរាប គឺសិក្ខាសាលាស្តីពីការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង កាលពីថ្ងៃទី ២៦-៣០ ខែឧសភា ឆ្នាំ២០០៨ សិក្ខាសាលាស្តីពីកំណើនលំហូរមូលធន កាលពីថ្ងៃទី ២-៥ ខែធ្នូ ឆ្នាំ២០០៨ និងកិច្ចប្រជុំក្រុមជំនាញការ ស្តីពីលំហូរមូលធនក្នុងបណ្តាប្រទេស SEACEN កាលពីថ្ងៃទី ៥-៦ ខែធ្នូ ឆ្នាំ២០០៨ ។

ក្នុងឆ្នាំ ២០០៨ នេះដែរ ធនាគារជាតិនៃកម្ពុជាបានចូលជាសមាជិកពេញសិទ្ធិក្នុងក្រុមជំនាញការ ស្តីពីលំហូរមូលធននៅក្នុងសមាគម SEACEN ។

## ២. ទំនាក់ទំនងទ្វេភាគី

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងទំនាក់ទំនងទ្វេភាគីជាមួយបណ្តាប្រទេសជាមិត្ត ទាំងនៅក្នុងតំបន់អាស៊ីក៏ដូចជានៅអឺរ៉ុប អូស្ត្រាលី លើគោលការណ៍នៃសហប្រតិបត្តិការជំនាញដូចជា ការផ្លាស់ប្តូរព័ត៌មាន ការលើកកម្ពស់ប្រព័ន្ធទូទាត់ និងការបណ្តុះបណ្តាលជាដើម ។

ប្រតិភូជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជា បន្តជួបប្រជុំជាមួយធនាគារកណ្តាលថៃក្នុងក្របខ័ណ្ឌសហប្រតិបត្តិការទ្វេភាគី កាលពីថ្ងៃទី ២៥-២៧ ខែមេសា ឆ្នាំ២០០៨ នៅទីក្រុងប៉ាតាយ៉ា ប្រទេសថៃ ។ ក្រៅពីកម្មវត្ថុនៃសហប្រតិបត្តិការជាទូទៅ ដូចជាការផ្លាស់ប្តូរព័ត៌មានស្តីពីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ភាគីទាំងពីរបានជំរុញឱ្យមានការសម្របសម្រួល

ប្រតិបត្តិការទូទាត់ពាណិជ្ជកម្មឆ្លងដែន ដោយប្រើរូបិយវត្ថុជាតិនៃប្រទេសទាំងពីរតាមរយៈការចាត់ឱ្យមានធនាគារពាណិជ្ជចូលរួម ។

ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយធនាគាររដ្ឋវៀតណាម ប្រតិភូជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជាដឹកនាំដោយឯកឧត្តមទេសាភិបាល បានអញ្ជើញទៅធ្វើទស្សនកិច្ចនៅសាខាធនាគាររដ្ឋវៀតណាម ខេត្តប៊ិញធ្វន់ និងខេត្តតៃនិញ ប្រទេសវៀតណាម កាលពីថ្ងៃទី ៤-៦ ខែមេសា ឆ្នាំ២០០៨ ។ ក្នុងដំណើរទស្សនកិច្ចនេះ ឯកឧត្តមទេសាភិបាលធនាគារជាតិនៃកម្ពុជាបានជួបជាមួយឯកឧត្តមទេសាភិបាលធនាគាររដ្ឋវៀតណាម ដើម្បីពិភាក្សាផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមកលើការងារគ្រប់គ្រងសាខា ។

ក្នុងកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលឡាវ ធនាគារជាតិនៃកម្ពុជាបានផ្តល់ការបណ្តុះបណ្តាលផ្នែករោងពុម្ពដល់មន្ត្រីមកពីធនាគារកណ្តាលឡាវ ។

ម្យ៉ាងវិញទៀត កិច្ចសហប្រតិបត្តិការរវាងធនាគារជាតិនៃកម្ពុជា និង ធនាគារកណ្តាលលុចហ្សំបួរ ត្រូវបានពង្រឹងថែមទៀតដោយ គណៈប្រតិភូជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជាដឹកនាំដោយឯកឧត្តមទេសាភិបាលបានអញ្ជើញទៅចូលរួមពិធីបុណ្យខួបលើកទី ១០ នៃការបង្កើតធនាគារលុចហ្សំបួរ កាលពីថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ២០០៨ និងបានជួបពិភាក្សា និងចុះហត្ថលេខាជាមួយសហភាគី លើកិច្ចសន្យាទទួលជំនួយផ្នែកបណ្តុះបណ្តាល ដោយធនាគារកណ្តាលលុចហ្សំបួរបានផ្តល់អាហារូបករណ៍ថ្នាក់អនុបណ្ឌិតដល់មន្ត្រីធនាគារជាតិនៃកម្ពុជាទៅសិក្សានៅសកលវិទ្យាល័យលុចហ្សំបួរ ។

ចំពោះកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលនៃសាធារណរដ្ឋកូរ៉េ ធនាគារជាតិនៃកម្ពុជាបានទទួលយកមន្ត្រីជំនាញការមកពីធនាគារកណ្តាលកូរ៉េចំនួនពីររូបដែលមកសហការជាមួយធនាគារជាតិនៃកម្ពុជាផ្នែកប្រព័ន្ធទូទាត់ និងទីផ្សាររូបិយវត្ថុនៅកម្ពុជា ។

## សន្និដ្ឋាន

ឆ្នាំ២០០៨ គឺជាឆ្នាំពោរពេញដោយបញ្ហាប្រឈមសម្រាប់សេដ្ឋកិច្ចពិភពលោក ។ ហានិភ័យជាទូទៅចំពោះស្ថិរភាពហិរញ្ញវត្ថុនៅតែមាននៅឡើយ ដោយសារតែឥទ្ធិពលអវិជ្ជមានពីវិបត្តិហិរញ្ញវត្ថុបានរាលដាលទៅលើសេដ្ឋកិច្ចរូបវ័ន្ត ហើយវិសាលភាពនិងជម្រៅនៃវិបត្តិឥណទាននៅតែមិនទាន់មានភាពច្បាស់លាស់ ។

ទោះជាយ៉ាងនេះក្តី ប្រព័ន្ធធនាគារកម្ពុជាមិនបានទទួលរងឥទ្ធិពលពីភាពចលាចលជាសកលនេះទេ ដែលមួយផ្នែកបណ្តាលមកពីការពឹងផ្អែកដ៏ខ្ពស់របស់ប្រព័ន្ធធនាគារលើប្រាក់បញ្ញើអតិថិជនសម្រាប់ប្រត្តិបត្តិការឥណទាន និងម៉្យាងទៀតដោយសារអវត្តមាននៃទីផ្សារហិរញ្ញវត្ថុដែលជាប្រភពនៃភាពងាយរងគ្រោះ ប្រសិនពុំមានការគ្រប់គ្រងសមស្រប ។ កម្រិតដ៏ទាបនៃផលប៉ះពាល់ដោយផ្ទាល់ពីវិបត្តិនៅសហរដ្ឋអាមេរិក និងនៅទីផ្សារឥណទានផ្សេងៗទៀតទៅលើធនាគារបរទេសដែលមានសាខានៅកម្ពុជា ក៏ជាកត្តាដ៏សំខាន់មួយចំពោះអវត្តមាននៃវិបត្តិហិរញ្ញវត្ថុនៅកម្ពុជាផងដែរ ។ ក្រៅពីនេះ ប្រព័ន្ធធនាគារក្នុងស្រុកបានពង្រឹងភាពរឹងមាំរបស់ខ្លួនតាមរយៈការបង្កើនដើមទុន និងការកាត់បន្ថយឥណទានមិនដំណើរការឱ្យមានកម្រិតទាប ។ ប្រព័ន្ធត្រួតពិនិត្យធនាគារបានប្រព្រឹត្តទៅដោយរលូនហើយទំហំនៃប្រតិបត្តិការរបស់ធនាគារមានកំណើនជាបន្តបន្ទាប់ ។ វិស័យហិរញ្ញវត្ថុកាន់តែមានភាពស៊ីជម្រៅជាងមុន ហើយកំណើននៃសេវាហិរញ្ញវត្ថុ ក៏ត្រូវបានជំរុញដោយកំណែទម្រង់ជាបន្តបន្ទាប់ ដូចមានចែងក្នុង "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥" ។

ធនាគារជាតិនៃកម្ពុជាតែងយកចិត្តទុកដាក់ជានិច្ច លើតួនាទីចម្បងរបស់ខ្លួនក្នុងការទ្រទ្រង់មូលដ្ឋានគ្រឹះសម្រាប់កំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍ ។ ជារួម ក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាបានខិតខំរួមគ្នាក្នុងការជំរុញអនុវត្តកំណែទម្រង់ផ្សេងៗ ដោយបានចាត់វិធានការជាជំហាន និងតាមលំដាប់លំដោយ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់ធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តភារកិច្ចឱ្យកាន់តែមានប្រសិទ្ធភាព ។

ជាការពិត ប្រសិទ្ធភាពនិងជោគជ័យរបស់ធនាគារជាតិនៃកម្ពុជា បានមកពីជំនឿទុកចិត្តរបស់សាធារណជន ។ ដូច្នេះសកម្មភាពរបស់ធនាគារជាតិនៃកម្ពុជាក្នុងអំឡុងឆ្នាំនេះ ដែលមានគោលបំណងសំដៅធ្វើឱ្យប្រសើរឡើងនូវសមាសភាគសំខាន់ៗមួយចំនួន ជាអាទិ៍ ការអនុវត្តដោយហ្មត់ចត់នូវមុខងាររបស់ធនាគារជាតិនៃកម្ពុជា ក្នុងការធានាម៉ាក្រូសេដ្ឋកិច្ចនិងការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុ ការពង្រឹងនិងការធ្វើកំណែទម្រង់ប្រព័ន្ធធនាគារ ការបង្កើនប្រសិទ្ធភាពប្រព័ន្ធទូទាត់ ការផ្គត់ផ្គង់ក្រដាសប្រាក់ ការងារសវនកម្មផ្ទៃក្នុង និងការកសាងសមត្ថភាពជាដើម គឺជាការព្យាយាមដើម្បីបង្កើនជំនឿទុកចិត្តរបស់សាធារណជន ។ ទង្វើទាំងអស់នេះនៅតែជាអាទិភាពរបស់ធនាគារជាតិនៃកម្ពុជា ដែលត្រូវបន្តតាំងចិត្តនិងខិតខំប្រឹងប្រែងថែមទៀតដើម្បីពង្រឹងជំនឿទុកចិត្តនោះ ។

ទោះបីជាប្រព័ន្ធធនាគារនៅក្នុងប្រទេសបន្តមានភាពរឹងមាំល្អក្តី ក៏កម្ពុជាមិនអាចគេចផុតទាំងស្រុងពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុជាសកលឡើយ ជាពិសេសក្នុងទិដ្ឋភាពនៃទំនាក់ទំនងរវាងម៉ាក្រូសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុដែលអាចធ្វើឱ្យកំណើនសេដ្ឋកិច្ចកម្ពុជាមានកម្រិតថយចុះ ។

ដូច្នេះ ធនាគារជាតិនៃកម្ពុជានឹងប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីចូលរួមរក្សាស្ថិរភាព និងភាពគត់មត់នៃម៉ាក្រូសេដ្ឋកិច្ច ពិសេសតាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុសមស្រប និងវិធានការចាំបាច់នានា សំដៅធានាភាពពេញលេញមិនរង្គោះរង្គើរបស់ប្រព័ន្ធធនាគារនៅកម្ពុជា ដែលជួយសម្រួលឱ្យអន្តរការីយកម្មធនាគារបន្តប្រព្រឹត្តទៅបានដោយលូន និងប្រកបដោយប្រសិទ្ធភាព ដែលជាមូលដ្ឋានគ្រឹះជួយគាំទ្រដល់កំណើនសេដ្ឋកិច្ច និងវិនិយោគ ។

# ខ. ទិសដៅការងារឆ្នាំ២០០៩

## ទិសដៅការងារឆ្នាំ២០០៩

ការខិតខំបន្តអនុវត្តកំណែទម្រង់គ្រប់ជ្រុងជ្រោយរបស់រាជរដ្ឋាភិបាល នៅឆ្នាំ២០០៨ នេះ ត្រូវបានរំពឹងថានឹងជួយទ្រទ្រង់មូលដ្ឋានគ្រឹះនៃខឿនសេដ្ឋកិច្ចកម្ពុជា ដើម្បីទប់ទល់នឹងផលប៉ះពាល់អវិជ្ជមាននានាពីភាពរង្គោះរង្គើនៃស្ថានភាពសេដ្ឋកិច្ចពិភពលោកនាពេលបច្ចុប្បន្ន ពិសេសវិបត្តិហិរញ្ញវត្ថុ ។ អាស្រ័យហេតុនេះ នៅឆ្នាំ២០០៩ សេដ្ឋកិច្ចកម្ពុជាគ្រោងថា នឹងមានកំណើនមួយសមរម្យក្នុងកម្រិតប្រមាណ ៥% ។ ការវាយតម្លៃដោយប្រយ័ត្នប្រយែងរបស់ស្ថាប័នអន្តរជាតិមួយចំនួនបានបង្ហាញថា ដើម្បីចូលរួមចំណែកធានាឱ្យបាននូវនិរន្តរភាពនៃកំណើនសេដ្ឋកិច្ចនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តផ្តោតលើកំណែទម្រង់ចាំបាច់ផ្សេងៗជាអាទិភាពដូចមានចែងក្នុង "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥" ។ ដើម្បីចូលរួមចំណែកសម្រេចនូវទិសដៅសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល នៅចំពោះមុខហានិភ័យជាសក្តានុពលទាំងឡាយ គឺជាបញ្ហាប្រឈមសម្រាប់វិស័យធនាគារ ដែលទាមទារនូវការប្រឹងប្រែងគ្រប់គ្រងឱ្យបានសមស្រប ដោយធនាគារជាតិនៃកម្ពុជាអនុវត្តវិធានការចំពោះមុខ និងវិធានការរយៈកាលមធ្យមផ្សេងៗប្រកបដោយភាពប្រុងប្រយ័ត្ន ដើម្បីកាត់បន្ថយសម្ពាធអតិផរណា ។ នៅក្នុងបរិការណ៍នេះ អត្រាអតិផរណាប្រចាំឆ្នាំត្រូវបានរំពឹងថា នឹងមានកម្រិតប្រមាណ ៧,៤% ហើយអត្រាប្តូរប្រាក់នឹងមានស្ថិរភាពសមស្របសម្រាប់សម្របសម្រួលដល់សកម្មភាពសេដ្ឋកិច្ច ។ ផ្អែកតាមលទ្ធផលដែលសម្រេចបានក្នុងឆ្នាំ២០០៨ នេះ ទិសដៅទាំងឡាយត្រូវបានពិនិត្យឡើងវិញ និងកែសម្រួលដើម្បីអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាអាចបន្តអនុវត្តគោលនយោបាយរូបិយវត្ថុ និងប្តូរប្រាក់ ប្រកបដោយភាពប្រុងប្រយ័ត្ននិងទន់ភ្លន់ទៅតាមការវិវត្តជាក់ស្តែងនៃសេដ្ឋកិច្ច ក្នុងគោលបំណងរក្សាស្ថិរភាពថ្លៃ និងបង្កើតនូវបរិយាកាសសមស្របសម្រាប់ទ្រទ្រង់នូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ព្រមទាំងកំណត់ទិសដៅការងារថ្មីសម្រាប់ឆ្នាំ២០០៩ លើផ្នែកសំខាន់ៗ ដូចខាងក្រោម :

### ១. ការងាររូបិយវត្ថុ (បម្រែបម្រួលជាភាគរយប្រចាំឆ្នាំ)

| | |
|---|---|
| - រូបិយវត្ថុទូទៅ (M2) | ៦,១% |
| - រូបិយវត្ថុក្នុងចរាចរណ៍ | ២០% |
| - ប្រាក់បញ្ញើជារូបិយប័ណ្ណ | ២,៦% |
| - ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា | ២៥,៥% |
| - ឥណទានសុទ្ធចំពោះរដ្ឋាភិបាលពីវិស័យធនាគារ | - ៤,៥% |
| - ទុនបម្រុងផ្លូវការសុទ្ធ | - ៤,៧% ។ |

### ២. ការងារប្តូរប្រាក់

- បន្តតាមដានការវិវត្តនៃអត្រាប្តូររូបិយប័ណ្ណ និងស្ថានភាពទីផ្សារអន្តរជាតិ
- បន្តសិក្សាស្វែងយល់អំពីសេវារក្សាមូលប័ត្រ
- បន្តរៀបចំសេចក្តីព្រាងប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតសម្រាប់សេវាប្តូររូបិយប័ណ្ណ

- ធ្វើការសិក្សាអំពីការវិនិយោគលើសញ្ញាប័ណ្ណរយៈពេលវែង
- បន្តពង្រីកការគ្រប់គ្រងទុនបម្រុងអន្តរជាតិស្របតាមសភាពការណ៍ទីផ្សារពិភពលោក ។

## ៣. ការងារអភិវឌ្ឍប្រព័ន្ធទូទាត់

- បន្តអនុវត្តគម្រោងអភិវឌ្ឍប្រព័ន្ធទូទាត់ជាតិស្របតាមផែនទីមគ្គុទេសក៍
- រៀបចំសេចក្តីព្រាងប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណសម្រាប់សេវាផ្ទេរប្រាក់
- បន្តពង្រឹង និងបណ្តុះបណ្តាលមន្ត្រីបុគ្គលិកក្រុមការងារគោលនយោបាយទូទាត់
- ត្រៀមរៀបចំសេចក្តីព្រាងប្រកាសដែលពាក់ព័ន្ធនឹងការទូទាត់តាមរយៈការប្រើប្រាស់ឧបករណ៍ទូទាត់ថ្មីៗ ។

## ៤. ការងារត្រួតពិនិត្យ

- ពង្រឹងការអនុវត្តច្បាប់ បទបញ្ជាប្រុងប្រយ័ត្ន
- បន្តការអនុវត្តត្រួតពិនិត្យដល់ទីកន្លែងលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមវិសាលភាពពេញលេញ និងតាមមុខសញ្ញា
- បន្តការសិក្សាស្រាវជ្រាវ ពិនិត្យឡើងវិញនូវបទប្បញ្ញត្តិដែលមានជាធរមាននិងដាក់ចេញបទប្បញ្ញត្តិថ្មីៗស្របតាមស្តង់ដារនិងការអនុវត្តជាអន្តរជាតិ ជាពិសេសអនុលោមតាមគោលការណ៍គ្រឹះនៃការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព
- ពង្រឹងការអនុវត្តប្រព័ន្ធចែករំលែកព័ត៌មានឱ្យកាន់តែទូលំទូលាយនិងមានប្រសិទ្ធភាពនិងសិក្សាអំពីលទ្ធភាពបង្កើតការិយាល័យឥណទានឯកជន
- បន្តជំរះបញ្ជីធនាគារដែលបានបិទទ្វារ នឹងខិតខំប្រមែប្រមូលបំណុលដើម្បីទូទាត់សងប្រាក់បញ្ញើអតិថិជន ។

## ៥. ការងារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ

- បង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិសម្រាប់ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- កសាងយុទ្ធសាស្ត្រផែនការសកម្មភាពអនុវត្តអនុសាសន៍របស់ក្រុមការងារវាយតំលៃអញ្ញមញ្ញ
- រៀបចំអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- រៀបចំប្រកាសស្តីពីក្រមសីលធមិ និងបទបញ្ជាផ្ទៃក្នុងរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- រៀបចំសិក្ខាសាលាទាក់ទងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

- រៀបចំយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈទាក់ទងនឹងការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- ការសម្របសម្រួលជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេសក្នុងការដោះដូរព័ត៌មាន ។

## ៦. ការងារគណនេយ្យ

- បន្តអនុវត្តគម្រោងកំណែទម្រង់ការងារគណនេយ្យ និងកែសម្រួលកម្មវិធីគណនេយ្យក្នុងប្រព័ន្ធកុំព្យូទ័រដែលកំពុងប្រើប្រាស់ឱ្យកាន់តែល្អប្រសើរ
- បូកសរុប និងធ្វើការវិភាគរបាយការណ៍គណនេយ្យឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា ។

## ៧. ការងារប្រតិបត្តិការ

- ពង្រឹងនិងត្រួតពិនិត្យការអនុវត្តការងារផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ដើម្បីធានាគុណភាពទូទាត់ក្នុងប្រព័ន្ធធនាគារទាំងមូល
- បង្កើនកិច្ចសហការជាមួយអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ និងនាយកដ្ឋានពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តឱ្យកាន់តែប្រសើរឡើងនូវប្រតិបត្តិការគ្រប់គ្រងគណនី និងត្រៀមទទួលការអនុវត្តប្រព័ន្ធ CBS
- ពង្រឹងសុវត្ថិភាពការថតចម្លងទិន្នន័យចូល Flash សម្រាប់ការងារសភាផាត់ទាត់ និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធការពារវីរុសធានាសុវត្ថិភាពក្នុងប្រព័ន្ធ
- រៀបចំបោះពុម្ពមូលប្បទានប័ត្រស្តង់ដារ ជំនួសឱ្យមូលប្បទានប័ត្រចាស់របស់ធនាគារជាតិនៃកម្ពុជា ។

## ៨. ការងារបោះផ្សាយ-ឃ្លាំងបេឡា

- បន្តពង្រឹងការងារបម្រើអតិថិជនក្នុងការបើក-បង់ប្រាក់នៅបញ្ជរបេឡា និងគណនេយ្យជំនួយឱ្យបានលឿន និងកាន់តែប្រសើរឡើង
- បន្តពង្រឹងការដឹកជញ្ជូនធនប័ត្រ និងធានាឱ្យមានសុវត្ថិភាព
- បន្តចុះត្រួតពិនិត្យសាច់ប្រាក់ ណែនាំអំពីការងារគ្រប់គ្រងសាច់ប្រាក់ ការថែរក្សាការពារឃ្លាំងប្រាក់ ព្រមទាំងតាមដានជាប្រចាំនូវសមតុល្យសាច់ប្រាក់ និងតម្រូវការសាច់ប្រាក់របស់សាខាធនាគារជាតិនៃកម្ពុជា
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច រាំងខ្ទប់ចរាចរណ៍ប្រាក់ក្លែងក្លាយ
- ពង្រឹងការងាររាប់-ស្រាវជ្រើស ការងារកាត់កំទេច និងដុតបំផ្លាញចោលក្រដាសប្រាក់ចាស់ទក់រំហែក
- បង្កើនការប្រមូលក្រដាសប្រាក់ចាស់ៗដែលពិបាកធ្វើចរាចរណ៍ ដោយបញ្ចេញក្រដាសប្រាក់ថ្មីសម្រាប់ដូរតាមប្រភេទឱ្យបានសមស្របទៅនឹងចរាចរលើទីផ្សារ ។

## ៩. ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

- បន្តធ្វើសវនកម្មនៅនាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ នាយកដ្ឋានរោងពុម្ព និងចុះធ្វើសវនកម្មនៅសាខាធនាគារជាតិនៃកម្ពុជាចំនួន ៧
- បន្តចុះពង្រឹងការងារ និងធ្វើអធិការកិច្ចនៅសាខាធនាគារជាតិនៃកម្ពុជាឱ្យបានញឹកញាប់ជាងឆ្នាំមុនៗ ។

## ១០. ការបណ្តុះបណ្តាល

- បន្តអភិវឌ្ឍបណ្ណាល័យ និងឯកសារ
- បើកវគ្គណែនាំប្រតិបត្តិការសម្រាប់មន្ត្រីបុគ្គលិកសាខាធនាគារជាតិនៃកម្ពុជាជំនាន់ទី ១៣
- បើកវគ្គសុក្រឹតការសម្រាប់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាជំនាន់ទី ១០
- បន្តពង្រឹងគុណភាពមណ្ឌលសិក្សាតាមរយៈការពង្រឹងសមត្ថភាពមន្ត្រីបុគ្គលិក សាស្ត្រាចារ្យ និងវិន័យដល់និស្សិតជាប្រចាំ
- រៀបចំស្រាវជ្រាវ កែសម្រួលកម្មវិធីសិក្សា
- រៀបចំធ្វើទំនើបកម្មសៀវភៅតាមមុខវិជ្ជា
- រៀបចំជ្រើសរើសនិស្សិតថ្មី ជំនាន់ទី ១៩ ។

✧✧✧✧✧✧✧✧

# ឧបសម្ព័ន្ធ

# តារាង ១ : ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវា

| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (គិតជាមធ្យម) | ធ្នូ ២០០៦ | ធ្នូ ២០០៧ | ២០០៨ មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **មុខទំនិញគ្រប់មុខ** | **១២១,៤៦** | **១៣៤,៥៧** | **១៣៧,៩៦** | **១៤០,៤១** | **១៤៧,០២** | **១៥៣,០២** | **១៥៦,០១** | **១៥៨,០៨** | **១៥៨,៣១** | **១៥៨,៦៨** | **១៥៨,៤៨** | **១៥៨,៤៣** | **១៥៤,៩៧** | **១៥២,៦៩** |
| ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ | ១២៤,១៦ | ១៤៨,៧១ | ១៥១,៦៦ | ១៥៦,១៩ | ១៦៩,៤៨ | ១៨២,៦១ | ១៨៨,១៦ | ១៩១,០៣ | ១៩០,៨២ | ១៩២,៣៣ | ១៩២,៣៧ | ១៩៣,២៨ | ១៨៧,១៤ | ១៨៣,២៨ |
| សម្លៀកបំពាក់និងស្បែកជើង | ៩៣,៦៩ | ៩៨,០១ | ៩៥,៩៦ | ៩៤,០៩ | ៩៤,១០ | ៩៥,៦៨ | ៩៥,៦៨ | ៩៦,៨០ | ៩៧,០៥ | ៩៧,២៨ | ៩៧,៥១ | ៩៨,៦៥ | ៩៨,៤១ | ៩៨,៥០ |
| ផ្ទះសំបែង និងការប្រើប្រាស់ | ១២០,៦១ | ១២២,៩៨ | ១២៧,២០ | ១២៧,៦៩ | ១២៨,៨០ | ១២៩,០២ | ១២៩,៩០ | ១៣០,៥៧ | ១៣០,៩៩ | ១៣០,៧៤ | ១៣០,៧៦ | ១៣០,៥៩ | ១៣០,៤៤ | ១២៩,៧០ |
| គ្រឿងសង្ហារឹមនិងសំភារៈប្រើប្រាស់ | ៩៧,២០ | ១០២,៤៨ | ១២១,៣៥ | ១២៣,៦៣ | ១២៤,៩៧ | ១២៦,២៥ | ១២៧,២៧ | ១២៧,៨៨ | ១២៧,៨៦ | ១២៨,៤៩ | ១២៨,៩១ | ១២៩,៥៣ | ១២៨,៩៩ | ១២៩,២៣ |
| ការថែទាំសុខភាព | ១០៤,៦២ | ១១០,៤ | ១១៣,១២ | ១២២,៩១ | ១២២,៦៨ | ១២២,៩៥ | ១២២,២៤ | ១២១,៩៤ | ១២១,៨៦ | ១២១,៩៨ | ១២២,០៥ | ១២២,២៣ | ១២២,២០ | ១២២,១១ |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ១៣៧,០៣ | ១៥៤,៩១ | ១១៩,៧១ | ១៦០,១៤ | ១៦៦,៤៤ | ១៦៩,៥០ | ១៧៣,១៩ | ១៧៩,៥២ | ១៨១,៧២ | ១៧៩,០៥ | ១៧៥,២៥ | ១៧០,៩២ | ១៦១,២៣ | ១៥៦,៩៤ |
| ការកំសាន្តនិងការអប់រំ | ១១១,៧៥ | ១១២,៧១ | ១៥៦,៣១ | ១១២,០១ | ១១១,៦៣ | ១១១,៩៨ | ១១១,៩១ | ១១២,០៧ | ១១២,២៤ | ១១២,៤៣ | ១១២,៨២ | ១១៣,៣១ | ១១៣,៥១ | ១១៣,៧១ |
| ការថែទាំខ្លួននិងសេវាកម្មផ្ទាល់ខ្លួន | ១១៣,៧៦ | ១១៤,១៨ | ១១២,៤០ | ១១៤,០៨ | ១១៥,២៨ | ១១៥,៩៣ | ១១៦,៣៣ | ១១៦,៦៩ | ១១៧,០២ | ១១៧,៦២ | ១១៨,៦០ | ១១៩,៥២ | ១១៩,៨៤ | ១២០,២៤ |
| **បម្រែបម្រួលជាភាគរយ** | | | | | | | | | | | | | | |
| **មុខទំនិញគ្រប់មុខ** | **-០,៦៥** | **០,៥០** | **២,៤៨** | **១,៨១** | **៤,៧១** | **៤,០៨** | **១,៩៥** | **១,៣៣** | **០,១៥** | **០,២៣** | **-០,១៦** | **០,០០** | **-២,១៩** | **-១,៤៧** |
| ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ | -១,៣៦ | ០,៤០ | ១,៩៨ | ២,៩៩ | ៨,៥១ | ៧,៧៥ | ៣,០៤ | ១,៥៣ | -០,១១ | ០,៧៩ | ០,០២ | ០,៤៧ | -៣,១៨ | -២,០៦ |
| សម្លៀកបំពាក់និងស្បែកជើង | -១,៤៩ | -០,៤៣ | -២,០៩ | -១,៩៥ | ០,០១ | ១,៦៨ | ០,០០ | ១,១៧ | ០,២៦ | ០,២៤ | ០,២៤ | ១,១៧ | -០,២៤ | ០,០៩ |
| ផ្ទះសំបែង និងការប្រើប្រាស់ | ០,០១ | ០,៥៣ | ៣,៧៧ | ០,៣៩ | ០,៨៧ | ០,១៧ | ០,៦៨ | ០,៥២ | ០,៣២ | -០,១៩ | ០,០២ | -០,១៣ | -០,១១ | -០,៥៧ |
| គ្រឿងសង្ហារឹមនិងសំភារៈប្រើប្រាស់ | ០,០៨ | -០,៦៧ | ១៨,៤១ | ១,៨៨ | ១,០៨ | ១,០២ | ០,៨១ | ០,៤៨ | -០,០២ | ០,៤៩ | ០,៣៣ | ០,៤៨ | -០,៤២ | ០,១៩ |
| ការថែទាំសុខភាព | ០,០១ | ០,១៣ | ២,៤៦ | ៨,៣០ | ០,១៤ | ០,២២ | -០,៥៨ | -០,២៥ | -០,០៧ | ០,១០ | ០,០៦ | ០,១៥ | -០,០២ | -០,០៧ |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ០,១៤ | ១,៨៤ | -២២,៧២ | ៣៣,៧៧ | ៣,៩៣ | ១,៨៤ | ២,១៨ | ៣,៨៩ | ១,០០ | -១,៤៧ | -២,១២ | -២,៧០ | -៥,៤៥ | -២,៩១ |
| ការកំសាន្តនិងការអប់រំ | -០,៦០ | -០,៥៣ | ៣៨,៦៨ | -២៨,៣៤ | -០,៣៤ | -០,០៤ | ០,៣០ | ០,១៤ | ០,១៥ | ០,១៧ | ០,៣៥ | ០,៤៣ | ០,១៨ | ០,១៨ |
| ការថែទាំខ្លួននិងសេវាកម្មផ្ទាល់ខ្លួន | ០,១៩ | ០,២៣ | -១,៥៦ | ១,៤៩ | ១,០៥ | ០,២២ | ០,៦៩ | ០,៣១ | ០,២៨ | ០,៥១ | ០,៨៣ | ០,៧៨ | ០,២៧ | ០,៣៣ |
| **បម្រែបម្រួលជាភាគរយឆ្នាំលើឆ្នាំ** | | | | | | | | | | | | | | |
| **មុខទំនិញគ្រប់មុខ** | **២,៨១** | **១០,៧៩** | **១៣,៧៣** | **១៥,៤៩** | **២០,២៩** | **២៤,២០** | **២៥,៧២** | **២៥,០៦** | **២២,៣០** | **២២,៥៦** | **២០,២៧** | **១៨,១២** | **១៥,៧៤** | **១៣,៤៧** |
| ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ | ១,៩៩ | ១៩,៧៧ | ២២,២៤ | ២៥,៦០ | ៣៤,៨៧ | ៤៣,២៩ | ៤៥,៨០ | ៤២,១៩ | ៣៦,៨៤ | ៣៦,៨៧ | ៣២,១៩ | ២៨,៧១ | ២៦,៣៤ | ២៣,២៩ |
| សម្លៀកបំពាក់និងស្បែកជើង | ២,៥៥ | ៤,៦១ | ២,៣០ | -១,១៧ | -១,៤០ | -០,០៤ | ០,៨៣ | ២,២១ | ១,២៨ | ០,៧៧ | -០,០៧ | ០,២០ | -០,០២ | ០,៥០ |
| ផ្ទះសំបែង និងការប្រើប្រាស់ | ៣,១០ | ១,៦៣ | ៥,៣១ | ៥,៦២ | ៦,៥១ | ៦,៤៩ | ៧,២១ | ៨,២៤ | ៨,០៦ | ៧,៩២ | ៧,៧៤ | ៧,៣៦ | ៦,៩៨ | ៥,៨១ |
| គ្រឿងសង្ហារឹមនិងសំភារៈប្រើប្រាស់ | ១,៩០ | ៥,៤៣ | ២៤,៦០ | ២៦,៧៧ | ២៧,៧២ | ២៨,២៩ | ២៩,១៤ | ២៩,៩៦ | ២៧,៣០ | ២៧,៤៣ | ២៧,៥២ | ២៦,៩២ | ២៥,០៣ | ២៦,១០ |
| ការថែទាំសុខភាព | ២,៣៤ | ៥,៥២ | ៨,០៧ | ១៧,០៣ | ១៧,១៨ | ១៧,៣២ | ១៦,៥២ | ១៤,៧៩ | ១៦,២៣ | ១១,១៩ | ១១,៦២ | ១១,០៧ | ១០,៨៣ | ១០,៦១ |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ៧,៤១ | ១៣,០៥ | -១០,៩៤ | ១៧,៩៦ | ២១,៩៩ | ២២,៩៨ | ២៣,៣៧ | ២៦,៩០ | ២៧,០៩ | ២៥,៨៣ | ២៣,៣១ | ១៧,៦០ | ៦,០០ | ១,០៥ |
| ការកំសាន្តនិងការអប់រំ | ០,៧៨ | ០,៨៦ | ៣៩,៨៤ | ០,២១ | -០,២៦ | -០,៣០ | -០,០១ | -០,៦៥ | -៨,១១ | -០,៤៨ | -០,៥៧ | -១,២៨ | ០,១៨ | ០,៨៩ |
| ការថែទាំខ្លួននិងសេវាកម្មផ្ទាល់ខ្លួន | ១,៤៨ | ០,៣៧ | -១,៤២ | ០,០០ | ០,៧៧ | ០,៧៨ | ១,៣៩ | ២,០៦ | ២,៣៣ | ២,១៨ | ២,៧៨ | ៥,៣១ | ៥,២០ | ៥,៣១ |
| **ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញមធ្យម ៣ខែ** | | | | | | | | | | | | | | |
| **មុខទំនិញគ្រប់មុខ** | **១២២,៣៨** | **១៣៤,២០** | **១៣៥,៤៦** | **១៣៧,៦៣** | **១៤១,៧៨** | **១៤៦,៨២** | **១៥២,០២** | **១៥៥,៧០** | **១៥៧,៤៧** | **១៥៨,៣៦** | **១៥៨,៤៧** | **១៥៨,៥១** | **១៥៧,២៨** | **១៥៥,៣៦** |
| បំម្រែបម្រួលជាភាគរយប្រចាំឆ្នាំ | ៣,៣៩ | ៩,៦៦ | ១១,៣៥ | ១៣,៣៤ | ១៦,៥១ | ២០,០១ | ២៣,៤២ | ២៥,០០ | ២៤,៣៤ | ២៣,៣០ | ២១,៧០ | ២០,២៩ | ១៨,០៣ | ១៥,៧៧ |
| **ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញមធ្យមរំកិល ១២ខែ** | | | | | | | | | | | | | | |
| **មុខទំនិញគ្រប់មុខ** | **១២០,៦២** | **១២៧,៦៧** | **១២៩,០៥** | **១៣០,៦២** | **១៣២,៦៩** | **១៣៥,១៧** | **១៣៧,៨៣** | **១៤០,៤៧** | **១៤២,៨៨** | **១៤៥,៣១** | **១៤៧,៩៤** | **១៤៩,៥៦** | **១៥១,៣២** | **១៥២,៨៣** |
| បំម្រែបម្រួលជាភាគរយប្រចាំឆ្នាំ | ៤,៧១ | ៥,៨៤ | ៦,៧៧ | ៧,៨១ | ៩,២១ | ១០,៨៩ | ១២,៧០ | ១៤,៣៤ | ១៥,៦៨ | ១៧,១៥ | ១៨,៣១ | ១៩,០៨ | ១៩,៥៩ | ១៩,៧១ |

# តារាង ២ : សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ឆ្នាំ ២០០៤-២០០៨

( គ្រាគោល : កក្កដា - ធ្នូ ២០០០=១០០)

| **សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់** | **ធ្នូ ២០០៤** | **ធ្នូ ២០០៥** | **ធ្នូ ២០០៦** | **ធ្នូ ២០០៧** | **ធ្នូ ២០០៨** |
|---|---|---|---|---|---|
| **មុខទំនិញគ្រប់មុខ** | **១១០,៧៦** | **១១៨,១៤** | **១២១,៤៦** | **១៣៤,៥៧** | **១៥២,៦៩** |
| ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ | ១០៩,៥៤ | ១២១,៧៤ | ១២៤,១៦ | ១៤៨,៧១ | ១៨៣,២៨ |
| សម្លៀកបំពាក់និងស្បែកជើង | ៨៧,០២ | ៩១,៣៦ | ៩៣,៦៩ | ៩៨,០១ | ៩៨,៥០ |
| ផ្ទះសំបែង និងការប្រើប្រាស់ | ១១៤,១៥ | ១១៦,៩៨ | ១២០,៦១ | ១២២,៥៨ | ១២៩,៧០ |
| គ្រឿងសង្ហារឹមនិងសំភារៈប្រើប្រាស់ | ៩៤,៣៩ | ៩៥,៣៩ | ៩៧,២០ | ១០២,៤៨ | ១២៩,២៣ |
| ការថែទាំសុខភាព | ១០២,១៩ | ១០២,២៣ | ១០៤,៦២ | ១១០,៤ | ១២២,១១ |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ១១៦,៩៨ | ១២៧,៥៨ | ១៣៧,០៣ | ១៥៤,៩១ | ១៥៦,៥៤ |
| ការកំសាន្តនិងការអប់រំ | ១០៩,៧៣ | ១១០,៨៩ | ១១១,៧៥ | ១១២,៧១ | ១១៣,៧១ |
| ការថែទាំខ្លួននិងសេវាកម្មផ្ទាល់ខ្លួន | ១០៥,៧៦ | ១១២,១០ | ១១៣,៧៦ | ១១៤,១៨ | ១២០,២៤ |
| | **បម្រែបម្រួលភាគរយប្រចាំខែ** | | | | |
| **មុខទំនិញគ្រប់មុខ** | **-០,២៣** | **-០,២៤** | **-០,៦៥** | **០,៥០** | **-១,៤៧** |
| ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ | -០,៧៣ | -០,៤៧ | -១,៣៦ | ០,៤០ | -២,០៦ |
| សម្លៀកបំពាក់និងស្បែកជើង | -០,២៤ | ០,០៩ | -១,៤៩ | -០,៤៣ | ០,០៩ |
| ផ្ទះសំបែង និងការប្រើប្រាស់ | ០,០៧ | ០,០០ | ០,០១ | ០,៥៣ | -០,៥៧ |
| គ្រឿងសង្ហារឹមនិងសំភារៈប្រើប្រាស់ | ០,១២ | ០,២១ | ០,០៨ | -០,៦៧ | ០,១៩ |
| ការថែទាំសុខភាព | ០,១២ | ០,០២ | ០,០១ | ០,១៣ | -០,០៧ |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ០,៣៥ | -០,៥៤ | ០,១៤ | ១,៨៤ | -២,៩១ |
| ការកំសាន្តនិងការអប់រំ | ០,១៧ | ០,១២ | -០,៦០ | -០,៥៣ | ០,១៨ |
| ការថែទាំខ្លួននិងសេវាកម្មផ្ទាល់ខ្លួន | ០,៤៣ | ០,៤៩ | ០,១៩ | ០,២៣ | ០,៣៣ |
| | **បម្រែបម្រួលជាភាគរយធៀបនិងខែដូចគ្នានៃឆ្នាំមុន** | | | | |
| **មុខទំនិញគ្រប់មុខ** | **៥,៦២** | **៦,៦៦** | **២,៨១** | **១០,៧៩** | **១៣,៤៧** |
| ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ | ៨,៥៥ | ១១,១៤ | ១,៩៩ | ១៩,៧៧ | ២៣,២៥ |
| សម្លៀកបំពាក់និងស្បែកជើង | ០,១៣ | ៤,៩៩ | ២,៥៥ | ៤,៦១ | ០,៥០ |
| ផ្ទះសំបែង និងការប្រើប្រាស់ | ២,២២ | ២,៤៨ | ៣,១០ | ១,៦៣ | ៥,៨១ |
| គ្រឿងសង្ហារឹមនិងសំភារៈប្រើប្រាស់ | -០,៩៧ | ១,០៦ | ១,៩០ | ៥,៤៣ | ២៦,១០ |
| ការថែទាំសុខភាព | -០,០៦ | ០,០៤ | ២,៣៤ | ៥,៥២ | ១០,៦១ |
| ដឹកជញ្ជូននិងទូរគមនាគមន៍ | ១៤,៧៣ | ៩,០៦ | ៧,៤១ | ១៣,០៥ | ១,០៥ |
| ការកំសាន្តនិងការអប់រំ | ០,៥៦ | ១,០៦ | ០,៧៨ | ០,៨៦ | ០,៨៩ |
| ការថែទាំខ្លួននិងសេវាកម្មផ្ទាល់ខ្លួន | ១,៧៩ | ៥,៩៩ | ១,៤៨ | ០,៣៧ | ៥,៣១ |
| | **ការវិវត្តន៍នៃសន្ទស្សន៍ថ្លៃទំនិញមធ្យមរំកិល ៣ខែ** | | | | |
| **មុខទំនិញគ្រប់មុខ** | **១១១,០៧** | **១១៨,៣៧** | **១២២,៣៨** | **១៣៤,២០** | **១៥៥,៣៦** |
| បំរែបម្រួលជាភាគរយប្រចាំឆ្នាំ | ៥,៨០ | ៦,៥៧ | ៣,៣៩ | ៩,៦៦ | ១៥,៥៥ |
| | **ការវិវត្តន៍នៃសន្ទស្សន៍ថ្លៃទំនិញមធ្យមរំកិល ១២ខែ** | | | | |
| **មុខទំនិញគ្រប់មុខ** | **១០៨,៩០** | **១១៥,២០** | **១២០,៦២** | **១២៧,៦៧** | **១៥២,៨៣** |
| បំរែបម្រួលជាភាគរយប្រចាំឆ្នាំ | ៣,៨៧ | ៥,៧៨ | ៤,៧១ | ៥,៨៤ | ១៩,៧១ |

## តារាង៣ : ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ

(រៀលក្នុង ១ឯកតានៃរូបិយប័ណ្ណ)

| រូបិយប័ណ្ណ | ២០០៧ ធ្នូ | ២០០៨ | | | | | | | | | | | | បំរែបំរួល % ធ្នូ ២០០៨ ធៀប នឹង ធ្នូ ២០០៧ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | |
| អេសដេអ៊ែរ | ៦.៣១៩ | ៦.៣៦៧ | ៦.៤០២ | ៦.៥៨២ | ៦.៥២១ | ៦.៥៣៦ | ៦.៦៧៦ | ៦.៦៦២ | ៦.៤៦២ | ៦.៤៨១ | ៦.១៣០ | ៦.០៨១ | ៦.៣១៧ | -០,០៣ |
| **អាស៊ី** | | | | | | | | | | | | | | |
| ដុល្លារ-អូស្ត្រាលី | ៣.៥១៨ | ៣.៥៩៧ | ៣.៧៧៣ | ៣.៥៦៤ | ៣.៧២៦ | ៣.៨៤៤ | ៣.៩៣៨ | ៣.៨៧៦ | ៣.៥៤៣ | ៣.៤៤១ | ២.៧៧៨ | ២.៦៦៦ | ២.៨១៥ | -១៩,៩៨ |
| ដុល្លារ-ហុងកុង | ៥១៣ | ៥១២ | ៥១៣ | ៥១៣ | ៥១៣ | ៥១៥ | ៥២៤ | ៥២៦ | ៥២៦ | ៥២៩ | ៥៣០ | ៥២៤ | ៥២៦ | ២,៥៣ |
| យ៉េន-ជប៉ុន | ៣៥.៦៣ | ៣៧,៤៩ | ៣៨,០៥ | ៣៩,៩៤ | ៣៨,៤២ | ៣៨,០៥ | ៣៨,៤៧ | ៣៧,៩៨ | ៣៧,៥៦ | ៣៨,៨៣ | ៤១,៩០ | ៤២,៥៩ | ៤៥,១២ | ២៦,៦៣ |
| វ៉ូន-កូរ៉េ | ៤.២៧ | ៤,២៣ | ៤,២៦ | ៤,៣៣ | ៣,៩៨ | ៣,៩២ | ៣,៩២ | ៤,០៦ | ៣,៧៧ | ៣,៥៦ | ៣,០៤ | ២,៧៨ | ៣,០១ | -២៩,៥១ |
| ដុល្លារ-ញ៉ូស៊ីឡែន | ៣.១០៣ | ៣.១២៣ | ៣.២៤៧ | ៣.១៦៣ | ៣.០៩២ | ៣.១៣៨ | ៣.១២០ | ៣.០១៣ | ២.៨៨៧ | ២.៨២៧ | ២.៤១៥ | ២.២៤០ | ២.៣៩២ | -២៤,២០ |
| យ៉ន់ ចិន | ៥៤៧ | ៥៥៦ | ៥៦១ | ៥៧០ | ៥៧២ | ៥៨០ | ៥៩៦ | ៦០២ | ៦០២ | ៦០៣ | ៦០០ | ៥៥៥ | ៥៩៧ | ៩,១៤ |
| ដុល្លារ-តៃវ៉ាន់ | ១២៣ | ៥៥៦ | ៥៦១ | ៥៧០ | ៥៧២ | ៥៨០ | ៥៩៦ | ៦០២ | ៦០២ | ៦០៣ | ១២៣ | ១២២ | ១២៤ | ០,៨១ |
| **អាស៊ាន** | | | | | | | | | | | | | | |
| រូពី-ឥណ្ឌូណេស៊ី | ០,៤២៥ | ០,៤២៩ | ០,៤៣៩ | ០,៤៣២ | ០,៤៣៣ | ០,៤៣២ | ០,៤៤៤ | ០,៤៥ | ០,៤៤៩ | ០,៤៣៨ | ០,៣៧៧ | ០,៣២៧ | ០,៣៦៨ | -១៣,៤១ |
| រីងហ្គីត-ម៉ាឡេស៊ី | ១.២០៧ | ១.២៣៦ | ១.២៥១ | ១.២៥២ | ១.២៦៧ | ១.២៣៨ | ១.២៥៣ | ១.២៥៩ | ១.២១០ | ១.១៩៨ | ១.១៥៧ | ១.១២៥ | ១.១៧៥ | -២,៦៥ |
| ប៉េសូ-ហ្វីលីពីន | ៩៦,៨៣ | ៩៨,០៦ | ៩៨,៧៩ | ៩៥,៤១ | ៩៤,៧២ | ៩១,៦២ | ៩១,៣០ | ៩៣,០០ | ៩០,០២ | ៨៨,៥១ | ៨៣,៥២ | ៨៣,២៣ | ៨៥,៩០ | -១១,២៩ |
| ដុល្លារ-សាំងហ្គាពួរ | ២.៧៦៨ | ២.៨១៦ | ២.៨៦៦ | ២.៨៩២ | ២.៩៣៦ | ២.៩៤៣ | ៣.០០៨ | ២.៩៩៨ | ២.៨៩៦ | ២.៨៩១ | ២.៧៧៧ | ២.៦៩៥ | ២.៨២៩ | ២,២០ |
| បាត-ថៃ | ១៣១ | ១២៧ | ១៣៥ | ១២៧ | ១២៦ | ១២៤ | ១២២ | ១២៣ | ១២០ | ១២១ | ១១៨ | ១១៥ | ១១៧ | -១០,៦៩ |
| ដុង-វៀតណាម | ០,២៤៩ | ០,២៥០ | ០,២៥០ | ០,២៤៨ | ០,២៤៨ | ០,២៤៨ | ០,២៤៣ | ០,២៤៥ | ០,២៤៨ | ០,២៤៧ | ០,២៤៤ | ០,២៤០ | ០,២៣៣ | -៦,៤៣ |
| **អឺរ៉ុប** | | | | | | | | | | | | | | |
| អឺរ៉ូ | ៥.៨៩៣ | ៥.៩៣៣ | ៦.០៦២ | ៦.២៩៨ | ៦.២២៣ | ៦.២៤១ | ៦.៤៦២ | ៦.៣៩៨ | ៦.០៤០ | ៦.០៣៣ | ៥.៣៦៥ | ៥.២៣៧ | ៥.៧៦២ | -២,២២ |
| **ផ្សេងៗ** | | | | | | | | | | | | | | |
| ផោន-អង់គ្លេស | ៧.៩៨៦ | ៧.៩៣៨ | ៧.៩៣៩ | ៧.៩៦៧ | ៧.៨៦៣ | ៧.៩៣៩ | ៨.១៦០ | ៨.១៣១ | ៧.៥១១ | ៧.៥៨០ | ៦.៧៥៤ | ៦.២៤៩ | ៥.៨៩០ | -២៦,២៥ |

# តារាង ៤ : ស្ថានភាពរូបិយវត្ថុ

( គិតជាពាន់លានរៀល )

| | ធ្នូ-២០០៤ | ធ្នូ-២០០៥ | ធ្នូ-២០០៦ | ធ្នូ-២០០៧ | ធ្នូ-២០០៨ |
|---|---|---|---|---|---|
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **៤.៧៩៧** | **៥.៤៧៥** | **៧.២២៤** | **១០.៧៣៥** | **១០.៣៤៦** |
| **ទ្រព្យសកម្មបរទេស** | ៥.៤៨២ | ៦.១៤២ | ៧.៦៥០ | ១១.៨៩០ | ១២.៨៨៦ |
| **ទ្រព្យអកម្មបរទេស** | -៦៨៥ | -៦៦៧ | -៤២៦ | -១.១៥៦ | -២.៥៤០ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **-៤៦៧** | **-៤៥០** | **-២៨២** | **៥៧៦** | **១.៥១៣** |
| **ឥណទានក្នុងស្រុក** | **១.៦០៨** | **១.៩៧២** | **២.៦៧៧** | **៤.៥៧០** | **៦.៩០៧** |
| **ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល** | **-២០៩** | **-៤២១** | **-៩៥៣** | **-១.៨១៦** | **-២.៩៨៧** |
| ឥណទេយ្យរាជរដ្ឋាភិបាល | ៣៦០ | ៣២៧ | ២៨៧ | ២៩៧ | ២៧០ |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល | -៥៦៩ | -៧៤៨ | -១.២៤០ | -២.១១៣ | -៣.២៥៧ |
| **ឥណទានផ្នែកមិនមែនរាជរដ្ឋាភិបាល** | **១.៨១៧** | **២.៣៩៤** | **៣.៦៣០** | **៦.៣៨៦** | **៩.៨៩៤** |
| សហគ្រាសរដ្ឋ | ០ | ០ | ២ | ១ | ០,៦ |
| ផ្នែកឯកជន | ១.៨១៧ | ២.៣៩៤ | ៣.៦២៨ | ៦.៣៨៥ | ៩.៨៩៣ |
| ក្នុងនោះ : រូបិយប័ណ្ណបរទេស | ១.៦៩៧ | ២.២៧៥ | ៣.៤៧៦ | ៦.១៦១ | ៩.៦០៣ |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | **-២.០៧៥** | **-២.៤២៣** | **-២.៩៥៩** | **-៣.៩៩៤** | **-៥.៣៩៤** |
| ប្រាក់បញ្ញើហាមឃាត់ | -១០២ | -១២៣ | -១៥៥ | -២៥៣ | -២៨៨ |
| មូលធននិងធនបម្រុង | -២.១៩២ | -២.៦៤០ | -៣.២៤១ | -៤.៣១៤ | -៥.៧៧៦ |
| ផ្សេងៗ | ២១៨ | ៣៤១ | ៤៣៨ | ៥៧២ | ៦៧០ |
| **រូបិយវត្ថុទូទៅ (M2)** | **៤.៣២៩** | **៥.០២៥** | **៦.៩៤២** | **១១.៣១១** | **១១.៨៥៩** |
| **រូបិយវត្ថុ (M1)** | ១.១៥៣ | ១.៣២៣ | ១.៦៥៨ | ២.០៥២ | ២.៤០០ |
| រូបិយវត្ថុក្រៅធនាគារ | ១.១១៥ | ១.២៨២ | ១.៦០០ | ១.៩៩០ | ២.២៩៥ |
| ប្រាក់បញ្ញើចរន្ត | ៣៨ | ៤១ | ៥៨ | ៦២ | ១០៥ |
| **រូបិយវត្ថុផ្សេងៗ** | **៣.១៧៦** | **៣.៧០២** | **៥.២៨៥** | **៩.២៥៩** | **៩.៤៥៩** |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | ៩៧ | ១១៣ | ៨៩ | ១២១ | ១៨៥ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ៣.០៧៩ | ៣.៥៨៩ | ៥.១៩៦ | ៩.១៣៨ | ៩.២៧៤ |
| **អនុស្សរណៈ:** | | | | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** (ជាពាន់លានដុល្លារ) | **១.១៩០** | **១.៣៣០** | **១.៧៧៩** | **២.៦៨២** | **២.៥៣៥** |
| ធនាគារជាតិនៃកម្ពុជា | ១.០២១ | ១.០៧៧ | ១.៤១១ | ២.១៤៣ | ២.៦៤១ |
| ធនាគារពាណិជ្ជ | ១៦៩ | ២៥៣ | ៣៦៨ | ៥៣៨ | -១០៦ |
| **វង្វិលជុំនៃរូបិយវត្ថុ** | **៥,៤** | **៥,៤** | **៤,៩** | **៣,៩** | **៣,២** |

# តារាង ៥ : ស្ថានភាពរូបិយវត្ថុ

(បម្រែបម្រួលប្រចាំខែជាភាគរយ)

| | ធ្នូ-២០០៤ | ធ្នូ-២០០៥ | ធ្នូ-២០០៦ | ធ្នូ-២០០៧ | ធ្នូ-២០០៨ |
|---|---|---|---|---|---|
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **១៩,១** | **១៤,១** | **៣១,៩** | **៤៨,៥៩** | **-៣,៦២** |
| **ទ្រព្យសកម្មបរទេស** | ១៥,៦ | ១២,១ | ២៤,៥ | ៥៥,៤៣ | ៨,៣៧ |
| **ទ្រព្យអកម្មបរទេស** | -៤,០ | -២,៦ | -៣៦,២ | ១៧១,៤៦ | ១១៩,៨០ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **៣៣,១** | **៣,៧** | **៣៧,៤** | **៣០៤,៥១** | **១៦២,៧៣** |
| **ឥណទានក្នុងស្រុក** | **៣៣,០** | **២២,៧** | **៣៥,៧** | **៧០,៧២** | **៥១,១៤** |
| **ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល** | **-៦៣,១** | **-១០១,៨** | **-១២៦,៤** | **-៩០,៤៨** | **៦៤,៤៩** |
| ឥណទេយ្យរាជរដ្ឋាភិបាល | -០,១ | -៩,៣ | -១២,២ | ៣,៦០ | -៨,៩៣ |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល | ១៦,៥ | ៣១,៥ | ៦៥,៨ | ៧០,៣៩ | ៥៤,១៧ |
| **ឥណទានផ្នែកមិនមែនរាជរដ្ឋាភិបាល** | **៣៥,៩** | **៣១,៨** | **៥១,៦** | **៧៥,៩៣** | **៥៤,៩៤** |
| សហគ្រាសរដ្ឋ | -១០០,០ | ០,០ | ០,០ | -៤៣,៥៥ | -៤៩,៧៩ |
| ផ្នែកឯកជន | ៣៥,៩ | ៣១,៨ | ៥១,៦ | ៧៦,០០ | ៥៤,៩៥ |
| ក្នុងនោះ : រូបិយប័ណ្ណបរទេស | ៣៩,៩ | ៣៤,១ | ៥២,៨ | ៧៧,២៦ | ៥៥,៨៥ |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | **-៨,៨** | **-១៦,៨** | **-២២,១** | **-៣៥,០០** | **៣៥,០៥** |
| ប្រាក់បញ្ញើហាមឃាត់ | ៦,៧ | ២១,០ | ២៦,១ | ៦២,៩៤ | ១៣,០៥ |
| មូលធននិងធនបម្រុង | ៤,៩ | ២០,៥ | ២២,៨ | ៣៣,០៩ | ៣៣,៩៦ |
| ផ្សេងៗ | -២៤,៩ | ៥៥,៩ | ២៨,៥ | ៣០,៧៦ | ១៧,០៦ |
| **រូបិយវត្ថុទូទៅ (M2)** | **៣០,០** | **១៦,១** | **៣៨,២** | **៦២,៩៣** | **៤,៨៥** |
| **រូបិយវត្ថុ (M1)** | **២៣,០** | **១៤,៧** | **២៥,៣** | **២៣,៧៩** | **១៦,៩៤** |
| រូបិយវត្ថុក្រៅធនាគារ | ២២,៧ | ១៥,០ | ២៤,៨ | ២៤,៣៩ | ១៥,៣៣ |
| ប្រាក់បញ្ញើចរន្ត | ៣០,៤ | ៦,៦ | ៤៣,០ | ៧,១១ | ៦៨,២៩ |
| **រូបិយវត្ថុផ្សេងៗ** | **៣២,៨** | **១៦,៦** | **៤២,៧** | **៧៥,២០** | **២,១៧** |
| ប្រាក់បញ្ញើមានកាលកំនត់និងសន្សំ | ១៨,៩ | ១៥,៨ | -២១,៤ | ៣៦,៥៩ | ៥២,៧៤ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ៣៣,៣ | ១៦,៦ | ៤៤,៨ | ៧៥,៨៦ | ១,៥០ |
| | | | **អនុស្សរណៈ** | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** (ជាពាន់លានដុល្លារ) | **១៧,៦១** | **១១,៧៩** | **៣៣,៧៣** | **៥០,៧៤** | **-៥,៤៧** |
| ធនាគារជាតិនៃកម្ពុជា | ១៦,២៨ | ៥,៥៤ | ៣០,៩៦ | ៥១,៩៣ | ២៣,២៣ |
| ធនាគារពាណិជ្ជ | ២៦,៣៥ | ៤៩,៤៩ | ៤៥,៥៦ | ៤៦,២២ | -១១៩,៦៨ |
| **រង្វិលជុំនៃរូបិយវត្ថុ** | **-១២,៩០** | **0** | **-៩,៨៥** | **-២០,៥៦** | **-១៧,២៥** |

# តារាង ៦ : តារាងគណនីវិភាគធនាគារជាតិនៃកម្ពុជា

| | ធ្នូ-២០០៤ | ធ្នូ-២០០៥ | ធ្នូ-២០០៦ | ធ្នូ-២០០៧ | ធ្នូ-២០០៨ |
|---|---|---|---|---|---|
| | (គិតជាពាន់លានរៀល ) | | | | |
| **រូបិយវត្ថុបម្រុង** (Reserve Money) | **២.៦៦៥** | **២.៦៣៧** | **៣.៣៨៣** | **៥.០១៨** | **៦.១០០** |
| **រូបិយវត្ថុក្រៅធនាគារ** | ១.១១៥ | ១.២៨២ | ១.៦០០ | ១.៩៩០ | ២.២៩៥ |
| **បេឡាធនាគារពាណិជ្ជ** | **២៦** | **២៧** | ៣០ | ៤៧ | ៩០ |
| **ប្រាក់បញ្ញើធនាគារ** | **១.៥១៩** | **១.៣២២** | **១.៧៣៦** | **២.៩៦៨** | **៣.៦៨៨** |
| ប្រាក់បម្រុងកាតព្វកិច្ច | ២៤៤ | ៣០២ | ៤២៨ | ៧៧៨ | ១.៦៣២ |
| ប្រាក់បញ្ញើផ្សេងៗ | ១.២៧៥ | ១.០២០ | ១.៣០៨ | ២.១៩១ | ២.០៥៥ |
| **ផ្សេងៗ** | **៥** | **៦** | **១៧** | **១៣** | **២៨** |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **៤.១១៤** | **៤.៤៣៤** | **៥.៧២៩** | **៨.៥៧៩** | **១០.៧៧៦** |
| **ទ្រព្យសកម្មបរទេស** | ៤.៥០៦ | ៤.៧៦៨ | ៥.៧២៩ | ៨.៥៧៩ | **១០.៧៧៦** |
| **ទ្រព្យអកម្មបរទេស** | -៣៩២ | -៣៣៤ | ០ | ០ | ០ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **-១.៤៥០** | **-១.៧៩៧** | **-២.៣៤៦** | **-៣.៥៦១** | **-៤.៦៧៦** |
| **ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល** | **-២៥៦** | **-៤០៧** | **-៨០៧** | **-១.៦៣២** | **-២.៦៩៦** |
| ឥណទេយ្យរាជរដ្ឋាភិបាល | ២៧០ | ២៧០ | ២៨៦ | ២៩៧ | ២៧០ |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល | -៥២៦ | -៦៧៧ | -១.០៩៣ | -១.៩២៩ | -២.៩៦៦ |
| **ឥណទានចំពោះធនាគារពាណិជ្ជ** | **-៨៤** | **-១០១** | **-៩២** | **-១៤៩** | **-១៩៤** |
| **ឥណទានចំពោះផ្នែកឯកជន** | **៣** | **២** | **២** | **២** | **២** |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | **-១.១១០** | **-១.២៨៩** | **-១.៤៤៩** | **-១.៧៧៩** | **-១.៧៨៨** |
| | (បម្រែបម្រួលប្រចាំឆ្នាំជាភាគរយ ) | | | | |
| **រូបិយវត្ថុបម្រុង** (Reserve Money) | **២៣,៩** | **-១,០** | **២៨,៣** | **៤៨,៣** | **២១,៥៦** |
| **រូបិយវត្ថុក្រៅធនាគារ** | ២២,៧ | ១៥,០ | ២៤,៨ | ២៤,៤ | ១៥,៣២ |
| **បេឡាធនាគារពាណិជ្ជ** | -៥៦,៣ | ៣,២ | ១០,៦ | ៥៨,៨ | ៩០,៧៦ |
| **ប្រាក់បញ្ញើធនាគារ** | **២៨,៥** | **-១៣,០** | **៣១,៣** | **៧២** | **២៤,២៣** |
| ប្រាក់បម្រុងកាតព្វកិច្ច | ២៦,៣ | ២៣,៨ | ៤១,៦ | ៨១,៧ | ១០៩,៨៣ |
| ប្រាក់បញ្ញើផ្សេងៗ | ២៨,៩ | -២០,០ | ២៨,៣ | ៦៧,៥ | -៦,២០ |
| **ផ្សេងៗ** | ០,០ | **២៤,០** | **១៧៨,៦** | **-២៥,៨** | **១១៨,៦១** |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **១៧,៧** | **៧,៨** | **២៩,២** | **៤៩,៧** | **២៥,៦១** |
| **ទ្រព្យសកម្មបរទេស** | ១៥,៤ | ៥,៨ | ២០,២ | ៤៩,៧ | ២៥,៦១ |
| **ទ្រព្យអកម្មបរទេស** | -៤,៨ | -១៤,៨ | -១០០,០ | ០,០ | ០,០ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **-៧,៨** | **-២៣,៩** | **-៣០,៦** | **-៥១,៨** | **-៣១,៣០** |
| **ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល** | -១៧,០ | -៥៩,០ | -៩៨,៤ | -១០២,៣ | -៦៥,១៧ |
| ឥណទេយ្យរាជរដ្ឋាភិបាល | ០,១ | ០,២ | ៥,៩ | ៣,៦ | -៨,៨៥ |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល | ៧,៧ | ២៨,៨ | ៦១,៥ | ៧៦,៤ | ៥៣,៧៨ |
| **ឥណទានចំពោះធនាគារពាណិជ្ជ** | -៧,២ | ២០,៧ | -៩,១ | ៦៤,៦ | ២៨,០៦ |
| **ឥណទានចំពោះផ្នែកឯកជន** | ០,០ | -៥,២ | -១១,៨ | -១៤,៩ | -២,២០ |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | -៧,៥ | -១៦,០ | -១២,២ | -២២,៨ | -០,៤៨ |

# តារាង ៧ : តារាងគណនីវិភាគធនាគារពាណិជ្ជ

| | ធ្នូ-២០០៤ | ធ្នូ-២០០៥ | ធ្នូ-២០០៦ | ធ្នូ-២០០៧ | ធ្នូ-២០០៨ |
|---|---|---|---|---|---|
| | (គិតជាពាន់លានរៀល) | | | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **៦៨២** | **១.០៤១** | **១.៤៩៦** | **២.១៥៦** | **-៤៣១** |
| **ទ្រព្យសកម្មបរទេស** | **៩៧៥** | **១.៣៧៤** | **១.៩២១** | **៣.៣១១** | **២.១១០** |
| **ទ្រព្យអកម្មបរទេស** | **-២៩៣** | **-៣៣៣** | **-៤២៦** | **-១.១៥៦** | **-២.៥៤០** |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **៩៥៨** | **១.២៧៥** | **១.៩៦២** | **៤.០២០** | **៥.៩៦២** |
| **ឥណទានក្នុងស្រុកសុទ្ធ** | **១.៨៦៩** | **២.៣៨៥** | **៣.៤៩០** | **៦.១៦០** | **៩.៥៦១** |
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | ៤៧ | -១៤ | -១៤៦ | -១៨៤ | -២៩២ |
| ឥណទានចំពោះសហគ្រាសរដ្ឋ | ០ | ០ | ២ | ១ | ១ |
| ឥណទានចំពោះផ្នែកឯកជន | ១.៨១៤ | ២.៣៩១ | ៣.៦២៦ | ៦.៣៨៣ | ៩.៨៩២ |
| ឥណទានសុទ្ធចំពោះធនាគារជាតិនៃកម្ពុជា | ៨ | ៨ | ៨ | -៤០ | -៤០ |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | **-៩១១** | **-១.១១០** | **-១.៥២៧** | **-២.១៤០** | **-៣.៥៩៨** |
| **ទុនបម្រុង** | **១.៥៦៩** | **១.៤២០** | **១.៨៦៨** | **៣.១៣២** | **៤.០០៥** |
| សាច់ប្រាក់នៅធនាគារពាណិជ្ជ | ២៦ | ២៧ | ៣០ | ៤៧ | ៩០ |
| ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា | ១.៥៤៣ | ១.៣៩៣ | ១.៨៣៨ | ៣.០៨៥ | ៣.៩១៥ |
| **ប្រាក់បញ្ញើ (ទ្រព្យអកម្មក្នុងស្រុក)** | **៣.២១០** | **៣.៧៣៧** | **៤.៣២៥** | **៩.៣០៨** | **៩.៥៣៧** |
| ប្រាក់បញ្ញើចរន្ត | ៣៣ | ៣៤ | ៤១ | ៤៩ | ៧៧ |
| ប្រាក់បញ្ញើមានកាលកំណត់ | ៩៧ | ១១៣ | ៨៩ | ១២១ | ១៨៥ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ៣.០៧៩ | ៣.៥៨៩ | ៥.១៩៦ | ៩.១៣៨ | ៩.២៧៥ |
| **ទ្រព្យសកម្មសរុប ≈ ទ្រព្យអកម្មសរុប** | **៤.៧០៦** | **៥.៥៧៩** | **៧.៩៦៣** | **១៣.៥៤៣** | **១៧.៣០៨** |
| | (បម្រែបម្រួលជាភាគរយប្រចាំឆ្នាំ) | | | | |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **២៨,០** | **៥២,៦** | **៤៣,៦** | **៤៤,១** | **-១១៩,៩៧** |
| **ទ្រព្យសកម្មបរទេស** | ១៦,៨ | ៤១,០ | ៣៩,៨ | ៧២,៣ | -៣៦,២៨ |
| **ទ្រព្យអកម្មបរទេស** | -៣,០ | ១៣,៧ | ២៧,៨ | ១៧១,៥ | ១១៩,៨៣ |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **៧១,៧** | **៣៣,១** | **៥៣,៩** | **១០៤,៩** | **៤៨,៣១** |
| **ឥណទានក្នុងស្រុក** | **៣៦,៥** | **២៧,៦** | **៤៦,៣** | **៧៦,៥** | **៥៥,២១** |
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | -៤៨,០ | -១៣០,៦ | ៩១៥,០ | ២៥,៦ | ៥៨,៥១ |
| ឥណទានចំពោះសហគ្រាសរដ្ឋ | -១០០,០ | ០,០ | ១០០,០ | -៤៣,៥ | -៤៩,០២ |
| ឥណទានចំពោះផ្នែកឯកជន | ៣៥,៧ | ៣១,៨ | ៥១,៦ | ៧៦,០ | ៥៤,៩៧ |
| ឥណទានសុទ្ធចំពោះធនាគារជាតិនៃកម្ពុជា | -១១៤,២ | ២,១ | -១,៣ | -៥៧៩,៧ | ០,០០ |
| **ខ្ទង់ផ្សេងៗ ( សុទ្ធ)** | **-១២,៤** | **-២១,៨** | **-៣៧,៦** | **-៤០,១** | **-៦៨,១៧** |
| **ទុនបម្រុង** | **១៨,០** | **-៩,៥** | **៣១,៥** | **៦៧,៧** | **២៧,៨៦** |
| សាច់ប្រាក់នៅធនាគារពាណិជ្ជ | -៥៦,៣ | ៣,២ | ១០,៦ | ៥៨,៨ | ៩០,៧៦ |
| ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា | ២១,៥ | -៩,៧ | ៣១,៩ | ៦៧,៩ | ២៦,៨៩ |
| **ប្រាក់បញ្ញើ (ទ្រព្យអកម្មក្នុងស្រុក)** | **៣២,៦** | **១៦,៤** | **១៥,៨** | **៧៤,៨** | **២,៤៥** |
| ប្រាក់បញ្ញើចរន្ត | ១៣,២ | ៤,០ | ១៨,៦ | ២១,០ | ៥៦,០៨ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១៨,៩ | ១៥,៨ | -២១,៤ | ៣៦,៦ | ៥២,៧០ |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ | ៣៣,៣ | ១៦,៦ | ៤៤,៨ | ៧៥,៩ | ១,៥០ |
| **ទ្រព្យសកម្មសរុប ≈ ទ្រព្យអកម្មសរុប** | **២១,៤** | **១៨,៥** | **៤២,៧** | **៧០,១** | **២៧,៨០** |

## តារាង ៨ : ឥណទានចំណាត់ថ្នាក់តាមមុខរបរ

(មិនគិតបញ្ចូលសាខាខេត្តរបស់ធនាគារជាតិនៃកម្ពុជា)
(ឯកតា : លានរៀល)

| | កក្កដា-០៨ | សីហា-០៨ | កញ្ញា-០៨ | តុលា-០៨ | វិច្ឆិកា-០៨ | ធ្នូ-០៨ |
|---|---|---|---|---|---|---|
| **១- គ្រឹះស្ថានហិរញ្ញវត្ថុ** | **១០២.២១២** | **១៧៨.៦៨៦** | **១១៥.៥៧៩** | **១២០.៣៤២** | **១៤១.៣១៤** | **១៣៥.៣៨២** |
| ធនាគារជាតិនៃកម្ពុជា | 0 | 0 | 0 | 0 | 0 | 0 |
| គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ២.០៦៦ | ២.០៨០ | ២.០៩៦ | ១.០៧៦ | ៩.២១១ | ៩.២៥៤ |
| គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗទៀត | ១០០.១៤៦ | ១៧៦.៦០៦ | ១១៣.៤៨៣ | ១១៩.២៦៦ | ១៣២.១០៣ | ១២៦.១២៨ |
| **២- គ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ** | **៨.៣២២.៩៥៨** | **៨.៤៣៦.៧០៥** | **៨.៥៩៩.៨៣៧** | **៨.៤៣៦.៩១៧** | **៨.៤០៦.៤៣៧** | **៨.២៩៩.៨៤៦** |
| កសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ | ៤១៩.៦៨៨ | ៤៦៦.៦៥៥ | ៤៧៩.៩៤២ | ៥៣៨.០៤២ | ៥៣៤.៤៧១ | ៥១៦.២៩៧ |
| ឧស្សាហកម្មរ៉ែ | ១០.៦០១ | ៧.៧៥១ | ៩.០៩៣ | ៩.៩៦៣ | ៩.៦៥៤ | ៧.៤៨១ |
| កម្មន្តសាលកម្ម | ៧០៧.០៧១ | ៧៩៧.៦២២ | ៧៤៨.៥៥៣ | ៩៦២.៣៦២ | ៩៦៦.០៥៤ | ៩៨៣.៦៦៤ |
| ការផ្គត់ផ្គង់សេវាសាធារណៈ | ៦៦.៣១៨ | ៨៧.០២២ | ៧៨.២២៥ | ៧៤.៨៦៩ | ៧៤.៣៩៧ | ៧៦.៩៩៨ |
| សំណង់ | ៧១១.៦៨០ | ៧៦៩.៣២១ | ៦៦០.៧១៦ | ៧៩៧.១៩៨ | ៧៨០.៩៧១ | ៧៧៣.៨០៨ |
| ការជួញដូរដុំ | ១.៤៧៨.០៩២ | ១.៤០៤.១៩៩ | ១.២០៧.៩៦១ | ១.៤២០.៣៥០ | ១.៤៤១.៦១៨ | ១.៦១៧.៩៧០ |
| ការជួញដូររាយ | ១.៣៤៥.៨២៦ | ១.៦៨២.២១៨ | ១.៥០៧.៥៤៩ | ១.៣៥១.០៩២ | ១.៣៧៦.៦៤៩ | ១.២៤៥.១៥៣ |
| សណ្ឋាគារនិងភោជនីយដ្ឋាន | ១.០០៧.១១៤ | ១.១៤៧.៥៤៨ | ១.១៩៨.៤០២ | ១.៤៤៥.៥៣៥ | ១.៣៣៩.១៤៨ | ១.២៧៦.៥៦៤ |
| ដឹកជញ្ជូននិងស្តុកបណ្តោះអាសន្ន | ៩៣.១៨៣ | ១៥៣.៩៧៨ | ១៧៤.៨៧៦ | ១៣៦.១៩០ | ១២៧.២៥២ | ១៣៧.៤១០ |
| បណ្តាញព័ត៌មាននិងទូរគមនាគមន៍ | ១៩០.៩០១ | ១៩៤.៨៤៣ | ២០៤.១១១ | ២១៩.២៩៧ | ២១៩.៤៥៥ | ២៤៤.៤៤៩ |
| អាជីវកម្មជួល និងភតិសន្យាប្រតិបត្តិការ | ៤១.០៣៣ | ៥៩.៦៣២ | ៦១.០០៩ | ៥៣.៥៦៧ | ៥៤.៨៤៧ | ២៤.៣០១ |
| ការជួញដូរអចលនទ្រព្យ | ៧៣៣.៨៦៤ | ៧២៨.៦៤៥ | ៧៤៣.៦៩២ | ៧៤៣.២៧៩ | ៧៤៣.៤៤១ | ៧៣៧.៤៤២ |
| សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗទៀត | ១.៥១៧.៥៨៦ | ៩៣៧.២៧១ | ១.៥២៦.១០៧ | ៧២៥.១៧៤ | ៧៣៨.៤៨០ | ៦៥៨.៧១០ |
| **៣- គម្រូវការផ្ទាល់ខ្លួន** | **១.០០៦.៤៤០** | **៨៦៥.៨២៥** | **៩១២.២០៥** | **១.២៤៦.១៣៤** | **១.២១៥.៧៦៥** | **១.៣១៦.១៤៤** |
| ការឱ្យខ្ចីជាបុគ្គល | ៦០០.៣៥៥ | ៤៥៣.៦៣៧ | ៤៩៧.០១១ | ៨៣២.៩៣៤ | ៨០៥.៥៥៥ | ៥៨៣.៩៣៧ |
| ការឱ្យខ្ចីតាមប័ណ្ណឥណទាន | ១៤.៤៩៦ | ១៦.៨០២ | ១៨.៦៧២ | ១៦.៣៦៩ | ១៦.៩៣៦ | ១៥.៩៩១ |
| ការឱ្យខ្ចីទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន | ៣៩១.៥៨៨ | ៣៩៥.៣៨៦ | ៣៩៦.៥២២ | ៣៩៦.៨៣១ | ៣៩៣.២៣៤ | ៧១៦.២១៦ |
| **៤- ឥណទានផ្សេងៗ** | **១០.៨៣៧** | **១០០.៧៩៩** | **១១០.៦២០** | **៩៣.៤៩០** | **៨៥.០២៥** | **៨១.៣១៣** |
| **សរុបឥណទានដុល** | **៩.៤៤២.៤៤៦** | **៩.៥៨២.០១៥** | **៩.៧៣៨.២៤១** | **៩.៨៩៦.៨៨៣** | **៩.៨៤៨.៥៤២** | **៩.៨៣២.៦៨៥** |

## តារាង ៩ : សរុបប្រតិបត្តិការប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ

(មិនគិតបញ្ចូលសាខាខេត្តរបស់ធនាគារជាតិនៃកម្ពុជា)
(ឯកតា : លានរៀល)

| | ធ្នូ-២០០៣ | ធ្នូ-២០០៤ | ធ្នូ-២០០៥ | ធ្នូ-២០០៦ | ធ្នូ-២០០៧ | ធ្នូ-២០០៨ |
|---|---|---|---|---|---|---|
| **ប្រាក់បញ្ញើជារៀល** | | | | | | |
| **ប្រាក់បញ្ញើចរន្ត** | ៣០.៧៩៩ | ៣៧.៨៩១ | ៤០.៧១២ | ៤៩.៩៩១ | ៥៣.៩៦០ | ៩២.៣២១ |
| **ប្រាក់បញ្ញើសន្សំ** | ៤១.១១៩ | ៤៩.១០៩ | ៦២.៧៩៧ | ៩១.៦៨៨ | ១៣៥.០៨៧ | ១៩៣.០៨២ |
| **ប្រាក់បញ្ញើមានកាលកំណត់** | ៤០.៨១៨ | ៤០.៣៧៣ | ៤១.៦៤៣ | ៤២.៦៧៩ | ៤៩.៦៤៩ | ៩៣.៧១១ |
| **ប្រាក់បញ្ញើផ្សេងៗ** | 0,0៩ | ២.៤២១ | ២.៤៣៨ | ១.៣៦០ | ១.២២១ | ១.១៦២ |
| **សរុប** | **១១២.៧៣៦** | **១២៩.៧៩៥** | **១៤៧.៥៩០** | **១៨៥.៧១៩** | **២៣៩.៥១៧** | **៣៨០.២៧៥** |
| **ប្រាក់បញ្ញើជារូបិយប័ណ្ណ** | | | | | | |
| **ប្រាក់បញ្ញើចរន្ត** | ៦៨៧.២៣០ | ៧៩២.៤៦៦ | ៩៥៨.៨០៤ | ១.៣៩៣.៥៣៣ | ២.៣១២.៧៤២ | ២.៤៦២.៧៣៣ |
| **ប្រាក់បញ្ញើសន្សំ** | ១.០៦៧.៣២៩ | ១.៤៧៨.០០៧ | ១.៧០៣.១៥៣ | ២.២២៤.៩៩៤ | ៤.៥១៨.២៥៧ | ៣.៤៦៩.១២៧ |
| **ប្រាក់បញ្ញើមានកាលកំណត់** | ៧៤០.១១៥ | ៨៨១.៦៤៤ | ១.០៧១.៨៦៣ | ១.៨១៣.២៧៩ | ២.៧៦៣.០៦១ | ៣.៩០៨.២៣៦ |
| **ប្រាក់បញ្ញើផ្សេងៗ** | ២.៣៨៦ | ៤៥.៨១៦ | ៤៥.៨១១ | ៦៩.៩១០ | ៨៨.៨៩៤ | ៦៦.៦៤៦ |
| **សរុប** | **២.៤៩៧.០៦១** | **៣.១៩៧.៩៣៣** | **៣.៧៧៩.៦៣១** | **៥.៥០១.៣១៦** | **៩.៦៨២.៩៥៥** | **៩.៩០៦.៧៤២** |
| **សរុបរួម** | **២.៦០៩.៧៩៦** | **៣.៣២៧.៧២៧** | **៣.៩២៧.២២១** | **៥.៦៨៧.០៣៥** | **៩.៩២២.៤៧២** | **១០.២៨៧.០១៨** |

# ជញ្ជីងទូទាត់ប្រទេសកម្ពុជា
## ឆ្នាំ២០០៥-២០០៨

(គិតជាលានដុល្លារអាមេរិក )

| | ២០០៥ | ២០០៦ | ២០០៧ | ២០០៨[ព] |
|---|---|---|---|---|
| **ជញ្ជីងពាណិជ្ជកម្ម** | **-៩៩៣,២** | **-១.០៣៤,១** | **-១.៣៣០,៥** | **-១.៨៥២,១** |
| **នាំចេញ** (FOB) | **២.៩១០,៣** | **៣.៦៩៣,២** | **៤.០៨៨,៥** | **៤.៨០៩,២** |
| នាំចេញផលិតផលក្នុងស្រុក | ២.៧៧២.៨ | ៣.៥៣៧.៨ | ៣.៨៧៣.៩ | ៤.៤៨៩.០ |
| នាំចេញតាមប្រព័ន្ធ GSP (រាប់បញ្ចូល សម្លៀកបំពាក់) | ២.២៦០.៧ | ២.៧២៧.៣ | ២.៩៤២.៣ | ៣.០២៩.៨ |
| នាំចេញផលិតផលក្នុងស្រុកផ្សេងៗ | ៥១២.២ | ៨១០.៥ | ៩៣១.៦ | ១.៤៥៩.២ |
| នាំចេញបន្ត | ១៣៧.៤ | ១៥៥.៤ | ២១៤.៦ | ៣២០.៣ |
| **នាំចូល** (FOB) | **-៣.៩០៣,៥** | **-៤.៧២៧,៤** | **-៥.៤១៩,០** | **-៦.៦៦១,៣** |
| នាំចូលសម្រាប់ប្រើប្រាស់ក្នុងស្រុក | -៣.៧៨៧.៣ | -៤.៥៩២.៨ | -៥.២៣៧.៦ | -៦.៣៩៨.៩ |
| សម្លៀកបំពាក់ | -១.១០២.៣ | -១.២៩៧.៧ | -១.៣៧៦.៦ | -១.៤១១.៥ |
| ប្រេងឥន្ធនៈ | -៨៤១.៦ | -១.១២៣.៤ | -១.៣៤៧.៦ | -១.៩៧២.៩ |
| នាំចូលសម្រាប់ប្រើប្រាស់ក្នុងស្រុកផ្សេងៗ | -១.៨៤៣.៤ | -២.១៧១.៦ | -២.៥១៣.៣ | -៣.០១៤.៤ |
| នាំចូលសម្រាប់នាំចេញបន្ត | -១១៦.១ | -១៣៤.៦ | -១៨១.៤ | -២៦២.៤ |
| **សេវា (សុទ្ធ)** | **៤៨២,៦** | **៥១៥,៨** | **៦៤២,៩** | **៧៤៧,៦** |
| **ចំណូល** | **១.១១៨,១** | **១.២៩៦,៣** | **១.៥៤៧,៥** | **១.៧៧០,២** |
| សេវាដឹកជញ្ជូន | ១២៦.៩ | ១៦៦.៨ | ២០៩.៧ | ២៨២.៤ |
| សេវាធ្វើដំណើរ | ៨៣៩.៥ | ៩៦៣.២ | ១.១៣៤.៨ | ១.២៩៥.១ |
| សេវាផ្សេងៗ | ១៥១.៦ | ១៦៦.៣ | ២០៣.០ | ១៩២.៧ |
| **ចំណាយ** | **-៦៣៥,៥** | **-៧៨០,៥** | **-៩០៤,៧** | **-១.០២២,៦** |
| សេវាដឹកជញ្ជូន | -៣៦០.៣ | -៤៣៦.៥ | -៥០៩.៩ | -៦៤១.៦ |
| សេវាធ្វើដំណើរ | -៩៦.៩ | -១២២.២ | -១២២.៧ | -១១០.៤ |
| សេវាផ្សេងៗ | -១៧៨.៤ | -២២១.៨ | -២៧២.១ | -២៧០.៦ |
| **ប្រាក់ចំណូល (សុទ្ធ)** | **-៣០៦,០** | **-៣២៣,៤** | **-៣៨៨,១** | **-៤២៩,៥** |
| **ចំណូល** | **៦៧,៧** | **៩០,០** | **១១២,២** | **១១៨,២** |
| **ចំណាយ** | **-៣៧៣,៧** | **-៤១៣,៤** | **-៥០០,៣** | **-៥៤៧,៦** |
| **បង្វែរឯកជន (សុទ្ធ)** | **២០៩,៣** | **៣១៤,៨** | **៣៧៤,៤** | **៣៥៤,៧** |
| **សមតុល្យគណនីចរន្ត** (មិនរាប់បញ្ចូលបង្វែរផ្លូវការ) | -៦០៧,៣ | -៥២៧,០ | -៧០១,៣ | -១.១៧៩,២ |
| **បង្វែរផ្លូវការ** | **៣៩៣,៧** | **៤៧៦,១** | **៤៨៤,៥** | **៤៨៦,០** |
| **ចំណូល** | **៣៩៣,៩** | **៤៧៦,៣** | **៤៨៤,៨** | **៤៨៦,២** |
| ក្នុងនោះ : ជំនួយទ្រទ្រង់ថវិការ | ៦,៩ | ៧,០ | ៣៥,២ | ៤៤,៤ |
| ជំនួយជាស្បៀងអាហារ | ១៧,១ | ១៨,៨ | ១៥,៩ | ១៩,៣ |
| ជំនួយតាមគម្រោង | ១១៨,៩ | ២១៦,៧ | ១៩៤,១ | ១៧៦,៩ |
| ជំនួយបច្ចេកទេស | ២៥១,១ | ២៣៣,៨ | ២៣៥,៦ | ២៤៥,៧ |
| **ចំណាយ** | -០,៣ | -០,៣ | -០,៣ | -០,៣ |
| **សមតុល្យគណនីចរន្ត និងបង្វែរដើមទុន** | -២១៣,៦ | -៥០,៩ | -២១៦,៨ | -៦៩៣,២ |
| **គណនីហិរញ្ញវត្ថុ** | ៣០២,៤ | ៣០២,២ | ៦៧៧,១ | ១.៣៥១,៥ |
| **ឥណទេយ្យផ្លូវការ** (មិនរាប់បញ្ចូល IMF) សុទ្ធ* | **១៤៤,០** | **១៤០,៩** | **១៩៩,៦** | **១៦៦,០** |
| **ដកប្រាក់** | **១៥៣,៣** | **១៤៩,៩** | **២០៨,៥** | **១៧៧,២** |
| **ទូទាត់** | **-៩,៣** | **-៩,០** | **-៨,៩** | **-១១,២** |
| **វិនិយោគមិនផ្លូវការ** | **១៥៨,៥** | **១៦១,៣** | **៤៧៧,៥** | **១.១៨៥,៥** |
| **វិនិយោគផ្ទាល់** (សុទ្ធ)* | **៣៧៤,៩** | **៤៧៤,៨** | **៨៦៦,៥** | **៧៨៦,៥** |
| **វិនិយោគលើផលប័ត្រ** (សុទ្ធ)* | **-៧,២** | **-១២,១** | **-១២,៤** | **-១២,៩** |
| **វិនិយោគផ្សេងទៀត** (សុទ្ធ)* | **-២០៩,៣** | **-៣០១,៤** | **-៣៧៦,៧** | **៤១២,០** |
| **កំហុស និង រំលង** | **-១៤,៤** | **-៤៩,៥** | **-៤៧,៤** | **-៧៤,៤** |
| **សមតុល្យរួម** | ៧៤,៤ | ២០១,៩ | ៤១២,៨ | ៥៨៣,៩ |
| **ហិរញ្ញប្បទាន** | **-៧៤,៤** | **-២០១,៩** | **-៤១២,៨** | **-៥៨៣,៩** |
| ទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិ * | -៨៧,១ | -២២០,៧ | -៤២៥,៦ | -៥៩៦,៦ |
| បំរែបំរួលទ្រព្យសកម្មជាទុនបំរុង | -៧៨,៤ | -១៣៨,៦ | -៤២៥,៦ | -៥៩៦,៦ |
| ការប្រើប្រាស់ឥណទានរបស់ IMF | -៨,៨ | -៨២,១ | ០,០ | ០,០ |
| **ហិរញ្ញប្បទានពិសេស** | **១២,៨** | **១៨,៨** | **១២,៨** | **១២,៨** |

* តម្លៃវិជ្ជមានតំណាងឱ្យកំណើនទ្រព្យអកម្មបរទេស ឬថយចុះទ្រព្យសកម្មបរទេស និងតម្លៃអវិជ្ជមានតំណាងឱ្យកំណើនទ្រព្យសកម្មបរទេស ឬការថយចុះទ្រព្យអកម្មបរទេស

**ប្រភព** : ទិន្នន័យត្រូវបានផ្តល់ដោយអាជ្ញាធរកម្ពុជា និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**កំណត់សំគាល់** : - ទិន្នន័យបណ្តោះអាសន្នសម្រាប់ឆ្នាំ២០០៥-២០០៧ (ទិន្នន័យទាំងនេះអាចនឹងកែលម្អឡើងវិញក្នុងពេលអនាគត)

- ព = ព្យាករណ៍ទិន្នន័យសម្រាប់ឆ្នាំ២០០៨